សង្គ្រាមនៅកម្ពុជាកាន់តែធំ អធិបតេយ្យភាព បូរណភាពទឹកដីនៃកម្ពុជាកាន់តែត្រូវបាត់បង់ កាលណាគណបក្សកុំមុយនីស្តកាន់តែមានអំណាច...ដូចនេះប្រសិនបើប្រជារាស្ត្រខ្មែរចង់បានសន្តិភាព ចង់ឱ្យកម្ពុជាមានអធិបតេយ្យភាព និងបូរណភាពទឹកដីពេញលេញ នោះបេសកកម្មទី ១ គឺត្រូវកំទេចក្រុមកុំមុយនីស្តនេះកុំឱ្យមានអំណាចដឹកនាំ និងត្រូវ...

ព្រឹត្តិបត្រសមាគមនិស្សិតខ្មែរ

Khmer Students Association Newsletter

ឆ្នាំទី៤ លេខ០២៩ ខែ មិនា ឆ្នាំ ១៩៩៦

អាស័យដ្ឋានលេខ៧៥ វិថីលេខ១១៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក្រុងភ្នំពេញ

ទូរស័ព្ទលេខ : (855) 23 (3) 66656, (015) 914 332

ទូរសារលេខ : (855)23 26746

មាតិការឿង

~ បទវិចារណកថា : គណបក្សកុំមុយនីស្ត គឺជាប្រភពធ្វើឱ្យកម្ពុជាបាត់បង់នូវអធិបតេយ្យភាព និងបូរណភាពទឹកដី

~ បរិយាយខែនេះ : ៨ មិនា និងស្ថានភាពពិតនៃសិទ្ធិនារីខ្មែរ

~ ទស្សនៈនិស្សិត : បើដំបៅមិនជា រុយនៅតែរោម

: ស្ត្រីខ្មែរ និងពាក្យ "គ្រប់លក្ខណ៍"

~ លិខិតមិត្តអ្នកអាន : និស្សិតខ្មែរ សូមគាំទ្រនយោបាយប្រឆាំងការឈ្លានពានរបស់យួន

~ វេទិកានារី : ការទទួលស្គាល់សិទ្ធិនារីនៅមានកំរិត

~ ទស្សនៈគួរយល់ដឹង : តើបុរសគួរធ្វើអ្វីខ្លះ ដើម្បីសុភមង្គលគ្រួសារ ?

: អត្ថន័យរូបសំណាកបុប្ផាក្រុងកែប

~ និស្សិតយល់ឃើញ

~ អត្ថបទស្រាវជ្រាវ : អំពីចំនួនប្រជាជននៅលើពិភពលោក (តចប់)

~ ទំព័រកំណាព្យ : សំរែកអ្នកក្រ

~ ទំព័រកំសាន្តចិត្ត : អាស្រាចំណាំងក៏ចេះដែរ !

ចែកជូនដោយឥតគិតថ្លៃ

បទវិចារណកថា ៖

គណបក្សកុំមុយនីស្ត គឺជាប្រភពធ្វើឱ្យកម្ពុជា បាត់បង់អធិបតេយ្យភាព និងបូរណភាពទឹកដី

ដោយអ.បុរីឥន្ទ្រ

ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីគឺជាវត្ថុដ៏សែនមានតំលៃផុតលេខសំរាប់មនុស្សជាតិទូទៅនៅលើលោកយើងនេះ ។ ហើយដោយសារតែការចង់ថែរក្សាឱ្យមានភាពគង់វង្សនូវឯករាជ្យភាព អធិប-តេយ្យភាព និងបូរណភាពទឹកដីនេះហើយ ដែលប្រជារាស្ត្រនៅលើពិភពលោកយើងបាននាំគ្នាលះបង់សាច់ស្រស់ឈាមស្រស់ ព្រមទាំងអាយុជីវិត ទ្រព្យសម្បត្តិ និងអ្វីគ្រប់យ៉ាងដើម្បីការពារវា ។

ដោយឡែកចោកតែ ពួកកុំមុយនីស្តខ្មែរមួយក្រុមដែលកំពុងកាន់អំនាចដែលបានមកដោយសារការបង្កើតតំបន់អបគមន៍ គេបែរជានាំគ្នាសំលាប់រាស្ត្រខ្មែរ លក់ធនធានធម្មជាតិខ្មែរ លក់កេតនភណ្ឌជាតិខ្មែរ ពិសេសលក់ទឹកដីខ្មែរ ព្រមទាំងបានស្មោះស្ម័គ្រលក់ទាំងខួរក្បាលឱ្យទៅយួន ព្រោះតែចង់បានអំណាចដ៏សែនឆ្គួតលីលាដោយភ្លេចគិតថាខ្លួនជាជនជាតិខ្មែរដែលធ្លាប់មានកិត្តិយស មានសេចក្តីថ្លៃថ្នូរដ៏ត្រដែតត្រដឹមតាំងពីអតីតកាល ។

ការទទួលស្គាល់ថ្ងៃ ៧ មករា របស់គណបក្សកុំមុយនីស្តដែលទាំងមតិជាតិ និងអន្តរជាតិយល់ឃើញថាគឺជាថ្ងៃរំដោះប្រជារាស្ត្រខ្មែរពីរបបខ្មែរក្រហម ដែលភ្ជាប់ជាមួយដោយខានមិនបាននូវការលុកលុយឈ្លានពានរបស់យួនលើអធិបតេយ្យភាព និងបូរណៈភាពដែនដីនៃកម្ពុជា ។ គឺអ្វីៗទាំងនេះហើយជាភស្តុតាងស្រាប់ក្នុងការបញ្ជាក់ថា តើនរណាជាអ្នកធ្វើឱ្យកម្ពុជាបាត់បង់នូវឯករាជ្យភាព អធិបតេយ្យភាព និងបូរណរភាពទឹកដី ពិសេសអត្ត-សញ្ញាណជាតិ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជាតិ ?

យើងនៅចាំបានថា នៅពេលថ្មីៗកន្លងមកនេះ អតីតមេដឹកនាំរបបអាយ៉ងរដ្ឋកម្ពុជា ហើយជាមេដឹកនាំគណបក្សកុំមុយនីស្ត និងជាប្រមុខដឹកនាំរដ្ឋាភិបាលកម្ពុជា បានស្រែកបញ្ជោសយ៉ាងពេញទំហឹង ដើម្បីឆ្លើយតបទៅនឹងអន្ទះមេដឹកនាំគណបក្សរាជានិយម ក្នុងការប្រឆាំងការឈ្លានពានរបស់យួនមកលើអធិបតេយ្យភាព និងបូរណៈភាពទឹកដី ។ ដែលពេលនោះមេដឹកនាំគណបក្សកុំមុយនីស្តបានសំដែងពីការខ្លាចស្លាប់ចំពោះការធ្វើចំបាំងជាមួយយួនក្នុងការការពារដែនដីខ្មែរ ។

ខ្លឹមសារនៃសំរែករបស់ជនកុំមុយនីស្តអាយ៉ងយួន នាពេលនោះហាក់ដូចជាមានន័យថា ខ្មែរទៅច្បាំងជាមួយយួនប្រាកដជាមិនឈ្នះទេ ហើយលទ្ធផលនៃសង្គ្រាមនោះនឹងធ្វើឱ្យខ្មែរស្លាប់ ដូចជាពាក្យ"ទៅច្បាំងទៅបើស្លាប់ឬពេលស្លាប់ខ្ញុំធ្វើក្ការមឈូសឱ្យ " និង"ចង់ទៅច្បាំងជាមួយយួនទៅខ្លួនឯងទៅខ្ញុំឱ្យកាំភ្លើង" តែខ្ញុំមិនទៅទេ ។ យើងសួរថាហេតុអ្វីបានជាទៅច្បាំងជាមួយយួនពួកកុំមុយនីស្តប្រកែក(SIC)។ ជាមួយយួនមិនទាន់ច្បាំងផងដឹងថាស្លាប់ ចុះបើទៅច្បាំងជាមួយខ្មែរក្រហមដែលជាខ្មែរគ្នាឯង ដឹងថាទៅច្បាំងប្រាកដជាស្លាប់ ហើយជ័យជំនះក៏មិនប្រាកដថានឹងអាចបានទទួលដែរ ហេតុអីក៏សុខចិត្តទៅ ? ហេតុម៉េចបានជាសុខចិត្តយកលុយជាតិ ទៅទិញកាំភ្លើងទុកច្បាំងជាមួយខ្មែរគ្នាឯង ហើយបែរជាព្រងើយកន្តើយជាមួយយួនទៅវិញហ្នឹ អាពួកកុំមុយនីស្ត ?

ជាការពិតណាស់ គឺមានតែគណបក្សកុំមុយនីស្តទេ ដែលយល់ឃើញថា ការបាត់បង់ទឹកដីគឺជារឿងធម្មតា តែអ្វីដែលមិនធម្មតានោះ គឺការបាត់បង់អំណាចរបស់គេឯណោះទេ ។ ហេតុនេះហើយទើបគណបក្សកុំមុយនីស្ត មិនដែលនឹកនាពីការប្រាថ្នាទាមទារឱ្យមានដំណោះស្រាយជាមួយយួនក្នុងការដែលយួនចូលឈ្លានពានទឹកដីខ្មែរឡើយ ។ ប៉ុន្តែផ្ទុយមកវិញ ជានិច្ចកាលគេតែងដឹងគុណយួន គោរពយួន និងឱ្យតំលៃយួនជាងខ្មែរព្រោះគេយល់ថា យួនគឺជាម្ចាស់របស់គេ យួនគឺជាអ្នកដែលបានផ្តល់អំណាចឱ្យគេ ។ ម្ល៉ោះហើយគេមិនហ៊ានប្រឆាំងយួនដែលឈ្លានពានទឹកដីខ្មែរទេ តែគេហ៊ានប្រឆាំង និងមិនអត់ឱនឱ្យជាដាច់ខាតចំពោះខ្មែរទាំងឡាយណាដែលមានគំនិតប្រឆាំងយួនដែលបានឈ្លានពានដីខ្មែរ ។

អ្វីដែលគួរឱ្យឈឺចាប់ជាងនេះទៅទៀតនោះ គឺគណបក្សកុំមុយនីស្តតែងបានប្តេជ្ញាចិត្តក្នុងការអនុគ្រោះឱ្យយួនដែលបានឈ្លានពានកម្ពុជា តែជានិច្ចកាលគណបក្សកុំមុយនីស្តតែងប្តេជ្ញាចិត្តថា នឹងមិនអនុគ្រោះឱ្យខ្មែរណាម្នាក់ឡើយ ។ ជាពិសេសគឺខ្មែរក្រហម និងខ្មែរទាំងឡាយដែលស្នេហាជាតិ គោរពសិទ្ធិមនុស្ស និងគោរពគោលការណ៍ប្រជាធិបតេយ្យដែលបានប្រឆាំងដាច់ខាតចំពោះនយោបាយដឹកនាំតាមបែបកុំមុយនីស្តផ្តាច់ការ ។ ពួកកុំមុយនីស្តសុខចិត្តដាក់ខ្មែរមួយក្រុមដែលមានឈាមជ័រជាខ្មែរពិតៗ ឱ្យនៅក្រៅច្បាប់ សុខចិត្តរុញច្រានឱ្យអ្នកគោរពសិទ្ធិមនុស្ស-ប្រជាធិបតេយ្យនៅក្រៅច្បាប់ តែពួកគណបក្សកុំមុយនីស្តប្តេជ្ញាការពារដាច់ខាតមិនឱ្យដាក់យួនដែលខុសច្បាប់ស្រាប់ ដែលត្រូវនៅក្រៅច្បាប់ស្រាប់ ឱ្យនៅក្រៅច្បាប់របស់កម្ពុជាឡើយ ។

ដោយយោលទៅលើហេតុផលខាងលើនេះហើយ ទើបបានជាប្រជារាស្ត្រខ្មែរមើលឃើញថា គឺគណបក្សកុំមុយនីស្តនេះឯងដែលជាប្រភពតែមួយគត់ដែលបាន និងកំពុងធ្វើឱ្យកម្ពុជារស់នៅបាត់បង់កិត្តយស បាត់បង់សេចក្តីថ្លៃថ្នូរ ព្រមទាំងបាត់បង់ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីដែលជាវត្ថុមានតំលៃមិនអាចកាត់ថ្លៃបាន ។ ហើយវាមិនមែនជាការបាត់បង់ត្រឹមរយៈពេលជិតពីរទសវត្សដែលគណបក្សកុំមុយនីស្តនេះបាន និងកំពុងកាន់អំណាចពីអតីត និងបច្ចុប្បន្នប៉ុណ្ណោះទេ តែធាតុពិតវានឹងបន្តទៅថ្ងៃអនាគតរាប់រយពាន់ឆ្នាំទៀត ឬកម្ពុជាអាចប្រឈមមុខនឹងការបាត់ឈ្មោះនៅលើផែនទីពិភពលោក ប្រសិនបើរាស្ត្រខ្មែរគ្មានវិធានការណ៍ទប់ស្កាត់ទេ ។

មធ្យោបាយដែលល្អ ឬវិធានការណ៍ដែលល្អ ឬយុទ្ធសាស្ត្រដែលល្អ ក្នុងការការពារ និងប្រឆាំងការឈ្លានពានរបស់យួនលើទឹកដីកម្ពុជា គឺគ្មានអ្វីក្រៅពីនាំគ្នាប្រឆាំងកំទេច ឬផ្តួលរំលំគណបក្សកុំមុយនីស្តមួយដែលកំពុងកាន់អំណាចសព្វថ្ងៃនេះចោលទៅ។ នោះភាពថ្លៃថ្នូរ កិត្តិយសជាតិ ពិសេសឯករាជ្យភាព អធិបតេយ្យ-ភាព បូរណភាពទឹកដីដែលយួនបាន និងកំពុងឈ្លានពាន រួមទាំងប្រជាធិបតេយ្យ-សិទ្ធិសេរីភាពក្នុងការរស់នៅពេញលេញនឹងត្រូវធ្លាក់នៅក្នុងកណ្តាប់ដៃប្រជារាស្ត្រយ៉ាងប្រាកដ ។

បរិយាយខែនេះ

៨ មីនា និងស្ថានភាពពិតនៃសិទ្ធិនារីខ្មែរ

ដោយអ.បូរីឥន្ទ្រ

ក្នុងស្ថានភាពមួយដែលស្ត្រីនៅលើពិភពលោក កំពុងនាំគ្នាខិតខំប្រឹងប្រែងដើម្បីឈានទៅដល់ការទទួលស្គាល់ដ៏ពិតប្រាកដមួយនូវភាពស្មើគ្នាជាមួយបុរសខាងសិទ្ធិ តួនាទី និងការទទួលខុសត្រូវនេះ ស្ត្រីខ្មែរយើងក៏បានរួមចំណែកនៅក្នុងសកម្មភាពនេះក្នុងកាយវិការខិតខំប្រឹងប្រែងបំផុត។ តែសំទុះនៃការខិតខំប្រឹងប្រែង និងលទ្ធផលបានមកដូចជាមិនទាន់ឆ្លើយតបចំពោះបំណងប្រាថ្នារបស់ស្ត្រីខ្មែរនៅឡើយទេ ។ ហើយភាពដែលមិនសូវមានសំទុះចំពោះលទ្ធផលនៃការការខិតខំប្រឹងប្រែងនេះ បើយើងពិនិត្យឱ្យបានដិតដល់ទៅឃើញថា ប្រពៃណីទំនៀមទំលាប់ក៏ជាកត្តាមួយ ការសំរេចចិត្តចុងក្រោយរបស់ស្ត្រីខ្មែរ ក្នុងបេសកកម្មរបស់ខ្លួនក្នុងការប្រកាន់យកនូវតួនាទី ភារកិច្ចក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិក៏ជាកត្តាមួយដែរ ។ ហើយកត្តាចុងក្រោយគឺការឯកភាពគ្នានៃមជ្ឈដ្ឋានសំលេងស្ត្រីខ្លួនឯង ដែលជាប្រយោជន៍ដ៏ធំធេងជាងគេ ហើយដែលជាមូលដ្ឋានដ៏សំខាន់ដែលអាចធ្វើឱ្យស្ត្រីទទួលបាននូវជោគជ័យនៃការប្រាថ្នាដែលមើលទៅហាក់ដូចជាទំហំធំធេងនេះ ។

រយៈកាលកន្លងមកឆ្លងតាមសកម្មភាព ឬក៏អាចនិយាយបានថាចលនារបស់ស្ត្រីខ្មែរដើម្បីបង្កើនបន្ថែមទៀតនូវសិទ្ធិ តួនាទី ភារកិច្ច និងការទទួលខុសត្រូវ បានធ្វើឱ្យមតិស្ទើរគ្រប់មជ្ឈដ្ឋាន ពិសេសមជ្ឈដ្ឋានដែលនិយមការកែទំរង់ស្ត្រីយល់ឃើញថា ស្ត្រីនៅបន្តជួបនឹង "វិបត្តិ" ច្រើនប្រការ ។ ហើយដែលវិបត្តិនេះឯង គឺជាប្រភពធ្វើឱ្យស្ត្រីប្រឈមមុខទៅនឹងភាពយឺតយ៉ាវនៃការកែទំរង់ ដែលក្នុងន័យនេះយើងចង់និយាយទៅដល់ការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គម ។

ទន្ទឹមនឹងការយល់ដឹងពីសារៈសំខាន់ និងការកែទំរង់របស់ខ្លួននៅក្នុងការអភិវឌ្ឍន៍សង្គម ភាពមិនប្រាកដរបស់ស្ត្រីខ្មែរ ក្នុងការប្រៀបធៀបទាញយកផលប្រយោជន៍ស្តីពីសិទ្ធិ តួនាទី ភារកិច្ច និងការទទួលខុសត្រូវតាមបែបប្រជារាស្ត្រក្នុងសង្គមប្រជាធិបតេយ្យ និងប្រពៃណីនៅតែបិតនៅជាបញ្ហាដដែល ។ ពោលគឺស្ត្រីខ្មែរនៅតែចង់រក្សានូវភាពទន់ភ្លន់ សុភាពរាបសារ ការស្រលាញ់កិច្ចការផ្ទះ ការដែលស្ត្រីនៅមានមនោសញ្ចេតនាលើសលប់នឹកគិតដល់ផ្ទះសំបែងកូនចៅ និងការថែរក្សាស្ថានភាពទូទៅរបស់ប្តី ។ ហើយចំនុចមួយទៀត គឺភាពដែលពិបាកនឹងទទួលយកបាននូវភារកិច្ចដែលមានទំហំធំ ប្រើប្រាស់ពេលវេលាវែង និងមានចំងាយឆ្ងាយ ដែលករណីនេះក៏ជាប្រភពធ្វើឱ្យស្ត្រីបាត់បង់នូវការយល់ដឹង និងបទពិសោធន៍មួយចំនួនដែរ ។

ដោយសារទំនៀមទំលាប់ពីបុរាណដែលមិនចូលចិត្តឱ្យកូនស្រីរៀនសូត្របានច្រើន ម្ល៉ោះហើយមរតកនេះបានបន្សល់ទុកដល់បច្ចុប្បន្នភាពសំរាប់ស្ត្រីខ្មែរ គឺការប្រឈមមុខនឹងការខ្វះបទពិសោធន៍ សមត្ថភាព និងចំនេះដឹង ។ ព្រោះថា ជាបន្តបន្ទាប់សង្គមខ្មែរតែងបានប្តូរនូវរបបនយោបាយរបស់ខ្លួន ហើយដែលចុងក្រោយនេះ កម្ពុជាបានសំរេចទទួលយកនូវរបបប្រជាធិបតេយ្យសេរីពហុបក្សដែលតាមគោលការណ៍ច្បាប់ អំណាចដ៏សំខាន់ត្រូវបានប្រគល់ជូនប្រជារាស្ត្រ ។ ដូចនេះមានន័យថា អ្វីៗក៏ដោយរបបប្រជាធិបតេយ្យត្រូវការ ការប្រកួតប្រជែង ដើម្បីដណ្តើម

យកប្រជាប្រិយភាពសំរាប់ការទុកចិត្តរបស់ប្រជារាស្ត្រមកលើខ្លួនក្នុងការបំពេញកាងារបំរើរាស្ត្រវិញ ។ ដោយសារការប្រកួតប្រជែងនេះហើយ ដែលជាទូទៅយើងសង្កេតឃើញ ស្ត្រីពិតជាប្រឈមមុខនឹងការពិបាក ។

ចំនុចគួរចាប់អារម្មណ៏មួយដែលបានកើតចេញក្រោយពីបានតាមដាន និងពិនិត្យក្នុងការបំពេញបេសកកម្មរបស់ស្ត្រីខ្មែរ គឺយើងមើលឃើញថា កន្លងមកមានស្ត្រីខ្មែរមួយចំនួនបាន "យល់ច្រលំ" ក្នុងកិរិតគួរសមមួយនោះៗ គឺការចាប់អារម្មណ៏ក្នុងការទាមទារសិទ្ធិពីបុរស ។ ដែលក្នុងន័យនេះស្ត្រីខ្មែរទាំងនោះបាននាំគ្នាចាត់ទុកការទាមទារសិទ្ធិពីបុរស គឺជាការប្រាថ្នាតែមួយគត់ ។ ហើយដែលក្នុងពេលនោះឯងស្ត្រីខ្មែរ សឹងតែមិនបានធ្វើអ្វី ឬក៏យល់ដឹងពីការងារសំខាន់ៗផ្សេងទៀត ក្រៅតែពីការទាមទារសិទ្ធិពីបុរសនេះទេ ។

ភាពជឿនលឿនដែលគួរឱ្យកោតសរសើរចំពោះស្ត្រីខ្មែរ នោះគឺការដែលស្ត្រីបានយល់កាន់តែស៊ីជំរៅ និងបានស្គាល់កាន់តែច្បាស់បន្ថែមទៀតក្នុងល្បឿនដ៏លឿនមួយទៅលើការប្រឈមមុខរបស់ខ្លួន ។ ពោលគឺស្ត្រីហាក់ដូចជាយល់កាន់តែច្បាស់ពីអ្វីដែលជាសេចក្តីត្រូវការជាមូលដ្ឋាន ពីអ្វីដែលនាំឱ្យស្ត្រីខ្លួនឯងត្រូវបានសង្គមគេទទួលស្គាល់ជាសាធារណៈ ។ ជាងនេះទៅទៀតនោះ គឺការដែលស្ត្រីខ្លួនឯងបាននាំគ្នាប្រឹងប្រែងចាក់បំពេញបន្ថែមនូវអ្វីដែលជាកង្វះខ្វះខាត នូវអ្វីដែលខ្លួនមិនមាន ។ នោះគឺការស្វះស្វែងរកបទពិសោធន៍ សមត្ថភាព និងចំនេះដឹងដែលជាសេចក្តីត្រូវការរបស់សង្គម និងរបស់ប្រជារាស្ត្រ ។

បញ្ហាមួយទៀត ដែលជាលក្ខណៈដ៏ចំបងមួយអាចនឹងជួយជំរុញឱ្យស្ត្រីឈានឆ្ពោះទៅរកការកែទំរង់ជីវភាពរស់នៅ ការងារដឹកនាំធំៗ និងការទទួលស្គាល់សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវក្នុងសង្គមរបស់ស្ត្រី គឺការឯកភាពគ្នានៅក្នុងក្របខ័ណ្ឌស្ត្រីខ្មែរនោះឯង ។ ត្រង់នេះមានន័យថា ការដែលសង្គមខ្មែរមិនសូវឱ្យតំលៃទៅលើស្ត្រី ការដែលស្ត្រីត្រូវរងនៅការកប់បាត់យ៉ាងជ្រៅនៅក្នុងវេទិការទូទៅនៃសង្គម ការដែលស្ត្រីខ្មែរមានចំណែកយ៉ាងតិចបំផុតដែលសឹងតែគ្មាននៅក្នុងចំណាត់ថ្នាក់នៃលំដាប់អ្នកដឹកនាំប្រទេស គឺស្ត្រីខ្មែរខ្លួនឯងនេះហើយ ដែលជាប្រភពដ៏សំខាន់មួយធ្វើឱ្យស្ត្រីជួបនូវភាពបរាជ័យក្នុងការកែទំរង់ស្ថានភាពរួមរបស់ខ្លួន ។

ផ្តើមចេញពីបញ្ហាទាំងអម្បាលមាណខាងលើនេះ ពិតមែនថាកម្ពុជា ជាប្រទេសមួយដែលបានគិតគូរពីការលើកតំកើង ការផ្តល់ឱកាសឱ្យស្ត្រី ដើម្បីជួយជំរុញស្ត្រីឱ្យមានតួនាទី មានភារកិច្ច និងការទទួលខុសត្រូវកាន់តែមានប្រសិទ្ធភាពថែមទៀត ពិតមែនថា ៨ មីនាដែលជាថ្ងៃទិវានារីអន្តរជាតិ នៅប្រទេសកម្ពុជាបានរៀបចំប្រារព្ធពិធីបុណ្យនេះ ដើម្បីជាការទទួលស្គាល់នូវសិទ្ធិនារីភ្លី ក៏ស្ថានភាពពិតនៃសិទ្ធិស្ត្រីខ្មែរ និងទំហំនៃការផ្តល់សិទ្ធិចំពោះស្ត្រីខ្មែរដោយច្បាប់ផ្សេងៗ នៅតែស្ថិតនៅឆ្ងាយពីគ្នាដដែល ។

ប៉ុន្តែថា អ្វីដែលជាដំណោះស្រាយដ៏ល្អសំរាប់ស្ត្រី គឺនៅត្រង់ថាតើស្ត្រីហ៊ាន ឬមិនហ៊ាន តើស្ត្រីច្បាស់ក្នុងចិត្តហើយឬនៅ តើស្ត្រីបានសំរេចជ្រើសរើសមាគ៌ាណាមួយសំរាប់ខ្លួនហើយឬនៅ តើស្ត្រីពិតជានឹងអាចហ៊ានដើរឱ្យបានឆ្ងាយជាងទំនៀម ទំលាប់ប្រពៃណីដែលបានកំនត់ឬទេ តើស្ត្រីពិតជាអាចកែទំលាប់អាក្រក់មួយចំនួនដែលធ្លាប់បានធ្វើឱ្យខ្លួនអន់ថយជា ពិសេសតើស្ត្រីខ្មែរបានស្គាល់ពីខ្លួនឯងច្បាស់លាស់ហើយឬនៅ មុននឹងស្ត្រីប្រាថ្នាទទួលបាននូវជោគជ័យក្នុងបេសកកម្មរបស់ខ្លួន ដើម្បីស្វែងរកនូវការទទួលស្គាល់ជាសារធារណៈពីសំណាក់សង្គមខ្មែរ នូវសិទ្ធិដែលខ្លួនចង់បាននោះ ???

ទស្សនៈនិស្សិតៈ

បើដំបៅមិនជា រុយនៅតែរោម

ការគ្រប់គ្រងកម្ពុជានៃពួកអ្នកដែលមានទំនោរ និងមនោគមវិជ្ជាកុម្មុយនីស្តក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងអតីតរដ្ឋកម្ពុជា គឺស្ថិតនៅក្នុងទំរង់ឯកបក្ស ។ អំណាចបានវិលវល់នៅតែជុំវិញកណ្តាប់ដៃនៃជនមួយក្រុមដែលមានទំនោរ ទស្សនៈ និងផលប្រយោជន៏ប្រហាក់ប្រហែលគ្នា ។ ដូច្នេះទស្សនៈវិស័យនៃបណ្តាមនុស្សគ្រប់មជ្ឈដ្ឋានពុំបានមើលឃើញច្រើនពីការបោកផ្លប់គ្នានៃរលកអំណាចនោះឡើយ ។ ការគ្រប់គ្រងបែបនេះចំហាយនិងឥទ្ធិពលនៃអំណាចបានធ្លាក់ចុះមកត្រង់មកចំពីលើថ្នាក់ដែលតូចជាងជាបន្តបន្ទាប់ហើយចេះតែរីកធំឡើងៗជាលំដាប់។ ដល់ទីបំផុតអំណាចនេះត្រូវបានគេពួតផ្តុំវាទំលាក់មកសង្កត់កប្រជាជនតាមមូលដ្ឋាន ។ តាមការពិនិត្យមើលឃើញថាការគ្រប់គ្រងបែបនេះចំហាយអំណាចហាក់មិនសូវមានការប្រទាញប្រទង់ និងចំណាយចោលឥតប្រយោជន៏តាមថ្នាក់នៃអំណាចនោះឡើយ ។

ក្រោយពីមានការចរចាសំរុះសំរួល និងកិច្ចព្រមព្រៀងក្រុងប៉ារីស ថ្ងៃទី ២៣ តុលា ១៩៩១ រហូតដល់មានអ៊ុនតាក់ចូលស្រុកខ្មែរ និងការបោះឆ្នោតឆ្នាំ ១៩៩៣ មកនោះ ក្រុមកុម្មុយនីស្តហាក់មានការឃ្លេងឃ្លោង និងបាត់ទំនុកចិត្តខ្លះៗចំពោះអំណាចខ្លួន ។ សភាពគ្រប់គ្រងគ្រប់បណ្តាជាន់ថ្នាក់នៃអំណាចហាក់មានភាពរញ៉េរញ៉ៃ និងកាន់តែក្រពុលមុខទ្វេរឡើងជាលំដាប់ ។ អ្នកមានអំណាចម្នាក់ៗបានបាត់ជំនឿលើអំណាចដែលធ្លាប់មាន ព្រោះខ្លាចអ្នកមកថ្មីដណ្តើមបានលាភសក្ការៈពីពួកគេ ។ គតិដឹងនឹតនេះបាននាំឱ្យពួកគេបែកគំនិតលួចបំផ្លាញជាតិដើម្បីបំពេញហោប៉ៅផ្ទាល់ខ្លួន បំពុលសង្គម និងខំយ៉ាងអស់ពីសមត្ថភាពក្នុងទង្វើនេះតាមតែអាចប្រព្រឹត្តទៅបាន ។ ព្រោះថាម្នាក់ៗបានដឹងយ៉ាងច្បាស់ថាប្រជាជនពិតជាងាករេចេញពីអំណាចរបស់ពួកខ្លួន ។

ក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋក្រោយពេលបោះឆ្នោត ១៩៩៣ គឺថាពួកគេនឹងទទួលបានពន្លឺថ្មីនៃប្រជាធិបតេយ្យពិតៗ សង្គ្រាមត្រូវបានបញ្ចប់ ស្លាមរបួសត្រូវបានព្យាបាលឱ្យជាសះស្បើយ ។ ពោលគឺសង្គមកម្ពុជានឹងមានអ្នកដឹកនាំថ្មីដែលមានមនសិការស្នេហាជាតិពិតៗ ។ តាមរយៈសន្លឹកឆ្នោតរាស្ត្របានសង្ឃឹមយ៉ាងមាំថាពួកគេនឹងទទួលបាននូវអ្វីដែលគេគួរតែមាន ។ មិនត្រឹមតែរាស្ត្រខ្មែរទេ សូម្បីតែជនបរទេសជាមិត្តខ្មែរ ជាសត្រូវខ្មែរដែលជាចោរឈ្លានពានកម្ពុជាត ទៅមុខទៀត ។ ព្រោះពួកវាជឿថា ខ្មែរបានបៀមឈាមព្រួសដាក់គ្នាយូរពេកណាស់មកហើយ ដូច្នេះខ្មែរប្រាកដជាត្រូវតែរួបរួមគ្នា ក្តាប់ដៃគ្នាយ៉ាងណែនកសាងកម្ពុជាឱ្យល្អឡើងវិញជាក់ជាពុំខាន ។ គំនិតនេះបានធ្វើឱ្យពួកវាដេកមិនលក់បក់មិនល្ហើយ ហើយរង់ចាំអ៊ុតមើលសកម្មភាពរបស់ខ្មែរទាំងក្តីអន្ទះសារ ។

ប៉ុន្តែការគិតឃើញ និងក្តីព្រួយបារម្ភទាំងអម្បាលម៉ាណរបស់ពួកបរទេសទាំងនេះគឺមានលទ្ធផលផ្ទុយស្រឡះទាំងស្រុង ។ ព្រោះថាតាំងពីក្រោយពេលបោះឆ្នោតរហូតមកដល់ពេលនេះ កម្ពុជាពិតជាពុំទាន់មានការឯកភាពជាតិដោយពិតប្រាកដនៅឡើយ ។ អ្នកដឹកនាំថ្មីក៏មិនជាទីពេញចិត្តរបស់ប្រជារាស្ត្រខ្មែរ ។ ការច្រចាច់បញ្ចូលគ្នានៃគ្រប់ភាគីដែលមានអំណាច ពុំមានការណែនល្អនោះឡើយ ។ បណ្តាអ្នកដឹកនាំខ្មែរម្នាក់ៗ បានបង្ហាញឱ្យឃើញនូវ

ឥរិយាបទមិនទុកចិត្តគ្នាទៅវិញទៅមក ។ ជាពិសេសបណ្តាអំណាចជាចំនុចយុទ្ធសាស្ត្រសំខាន់ៗត្រូវបានគេពុះចែកគ្នាយ៉ាងច្បាស់ក្រឡែត (អ្វីៗក៏សហះ) ការតថ្លៃអំណាចហាក់ដូចជាការតថ្លៃទំនិញនៅទីផ្សារ ។ ម្ខាងៗនៅតែមានលាក់តម្រិះ លាក់ក្រចក និងរកស្នៀតសំរាប់ទប់ទល់គ្នាទៅវិញទៅមកមិនឈប់ឈរ ។

ចំណែកការផ្សាយ ឥទ្ធិពលមកលើរាស្ត្រប្រជាគឺកាន់តែមានទំងន់ទ្វេរឡើង ។ ការគ្រប់គ្រងអំណាចត្រូវគេមើលឃើញយ៉ាងច្បាស់ថា មានលក្ខណៈសាំញ៉ាំប្រទាក់ក្រឡាគ្នាទាំងខ្សែបណ្តោយ និងខ្សែទទឹង ។ ទាំងនេះវាបានស្តែងឱ្យឃើញនូវកំសោយភាព និងការដុនដាបនៃនយោបាយគ្រងគ្រងព្រោះការមិនទុកចិត្តគ្នាដែលបង្កើតឱ្យមានបាតុភាពរញ៉េរញ៉ៃក្នុងសង្គម ។ ម្យ៉ាងទៀតសង្គ្រាមដែលគេសង្ឃឹមថានឹងចប់ទៅហើយនោះស្រាប់តែផ្ទុះឡើងវិញកក្រើកមេឃកក្រើកដីខ្លាំងឡើងជាលំដាប់ ។ ដូច្នេះដំបៅដែលគេជឿថាត្រូវតែជាសះស្បើយនោះប្រែជារើឡើងវិញព្រោះតែមុខរបួសតែខាងក្នុង គឺនៅតែកខ្ទុះដដែល ។

មើលឃើញបញ្ហាទាំងនេះហើយ ដែលធ្វើឱ្យចោរឈ្លានពានរីកថ្លើមប្រមាត់ ធ្ងរទ្រូងហាក់ដូចបានដកបន្លាចេញ ។ ដោយសារការធូរលុង ដោយរវល់តែដណ្តើមអំណាចគ្នាដោយរវល់តែសណ្ឋាគារ ប្បៀរ បនរបស់អ្នកដឹកនាំខ្មែរហាក់ដូចជាបានហុចដៃឱ្យយួន សៀមជាចំហរ ។ ដោយហេតុយ៉ាងនេះហើយទើបយួន សៀមវាបានចូលមកច្រើបយកដីខ្មែរឥតញញើតដៃនោះ ។ ដឹងទេថាហេតុអ្វីបានជាយួនហ៊ានឈ្លានពានខ្មែរយ៉ាងចេញមុខនៅឆ្នាំ ១៩៩៦ នេះ? តើនេះបញ្ជាក់ថាយើងបានបង្រួបបង្រួមជាតិ កសាងជាតិ និងសាមគ្គីគ្នាស្អិតល្មួតដែរឬទេ ? តើពហុបក្សបែបហ្នឹងល្អមើលដែរហ្អេស ?!!

ដោយ ទិសេស_គតិយុត្តិ

☞☞☞☞☞☞☞☞

ឧស្សាហ៍នៈនិស្សិត :

ស្ត្រីខ្មែរនឹងពាក្យ "គ្រប់លក្ខណ៍"

ដោយសារប្រពៃណីទំនៀមទំលាប់តាំងពីបុរមបុរាណរបស់ខ្មែរយើង ដែលជាទូទៅត្រូវមនុស្សខ្មែរគ្រប់មជ្ឈដ្ឋាន ពិសេសនារីខ្មែរខ្លួនឯងបានមើលឃើញថា វាហាក់ដូចជាមានភាពតឹងតែងពេក នឹងដូចជាបានក្បៀបស្ត្រីខ្មែរមិនឱ្យមានតួនាទី និងបំពេញភារកិច្ចសំខាន់ៗក្នុងសង្គមបាន ។ ដោយសារចង់បាននូវកេរ្តិ៍ឈ្មោះប្រពៃជានារីខ្មែរពេញលក្ខណៈ ដោយសារខ្លាចការដៀលត្មិះចំពោះខ្លួនថា ជាស្ត្រីមិនគោរពប្រពៃណី ម្ល៉ោះហើយគោលបំណងដ៏សំខាន់របស់ស្ត្រីខ្មែរមួយចំនួនហាក់ដូចជាពុំចង់បានអ្វីក្រៅពីការធ្វើខ្លួនឱ្យសុភាពរាបសារដូចជាសំពត់ក្នុងផ្ទត់ដែលទីបញ្ចប់នឹងអាលឈានទៅរកងារជា "ស្ត្រីគ្រប់លក្ខណ៍" ។

ពាក្យស្ត្រីគ្រប់លក្ខណ៍ ជានិច្ចកាលបានក្លាយទៅជាទីប្រាថ្នាតែមួយគត់របស់នារីខ្មែរយើង ។ ដែលហេតុការណ៍នេះ បានក្លាយទៅជាទុក្ខសោកសំរាប់នារីខ្មែរក្នុងការប្រាថ្នាក្លាយខ្លួនទៅជានារីសកម្មក្នុងការចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសនាបច្ចុប្បន្នភាព ។ ព្រោះការប្រាថ្នានេះបាននាំខ្លួនស្ត្រីឱ្យងាកចេញយ៉ាងឆ្ងាយ

ពីការទទួលខុសត្រូវដ៏សំខាន់ ក្នុងនាមជាកោសិកាសង្គម ដែលជានិច្ចកាលគេតំរូវឱ្យកោសិការសង្គមនេះពួតផ្តុំគ្នា ដើម្បីជួយទ្រទ្រង់នូវជីវិតរួមនៃសង្គម ។ ដូចនេះហើយដើម្បីសំរេចបាននូវក្តីប្រាថ្នា (ជាស្ត្រីគ្រប់លក្ខណ៍) ទីកន្លែងដែលស្ត្រីខ្មែរយល់ថាសមរម្យបំផុត យល់ថាជាកន្លែងចុងក្រោយបំផុត គឺនៅថែរក្សាផ្ទះសំបែង កូនចៅ ថែរក្សាប្តី ហើយតាមរយៈនេះស្ត្រីបានបណ្តោយឱ្យប្តីចាត់ចែង និងទទួលខុសត្រូវរួមលើវាសនាអនាគតនៃគ្រួសារទាំងមូល ។ ដើម្បីទ្រទ្រង់នូវការរីកចំរើននៅក្នុងគ្រួសារ ក៏ដូចជាសង្គមជាតិ តើសង្គមខ្មែរយើងនាំគ្នាឱ្យតំលៃទៅលើពាក្យថា "ស្ត្រីគ្រប់លក្ខណ៍" តាមរូបភាពណា ?

ភាពមិនច្បាស់លាស់ក្នុងការឱ្យតំលៃទៅលើអត្ថន័យនៃពាក្យស្ត្រីគ្រប់លក្ខណ៍ ដែលបានកើតចេញពីប្រភពស្ត្រីខ្លួនឯងបានធ្វើឱ្យពាក្យ ឬងារដ៏ល្អផូរផង់សំរាប់បំពាក់ជារង្វាន់ដល់ស្ត្រីខ្មែរ ដែលជាប្រភពរក្សាបានយ៉ាងប្រពៃនូវទំនៀមទំលាប់ ប្រពៃណី ក្លាយទៅជាពាក្យអសកម្ម ពាក្យអវិជ្ជមាន និងពាក្យគ្មានប្រយោជន៍ទៅវិញ ។ តាមការសង្កេតជាញឹកញាប់ ដើម្បីបានក្លាយខ្លួនទៅជា "ស្ត្រីគ្រប់លក្ខណ៍" ស្ត្រីបានយកទ្រឹស្តី "ស្ងៀមជាងស្រដី" មកអនុវត្តក្នុងការរួមរស់ ជាមួយគ្រួសារ (ប្តី) ។ មូលហេតុនេះធ្វើឱ្យស្ត្រី វាងចាកពីការនិយមគិតកិច្ចការផ្សេងៗជាមួយប្តីក្រៅពីកិច្ចការផ្ទះ ហើយបែរជាចាប់យកនៅការអត់ធ្មត់ចំពោះប្តី ដែលបានប្រព្រឹត្តកំហុសឆ្គងមកលើខ្លួន និងបានបណ្តោយឱ្យប្តី ប្រព្រឹត្តអ្វីតាមអំពើចិត្តក្នុងសកម្មភាពដឹកនាំគ្រួសារ ។ តើស្ត្រីត្រូវការធ្វើខ្លួនឱ្យក្លាយទៅជា "ស្ត្រីគ្រប់លក្ខណ៍" តាមរូបភាពនេះឬ ?

រីឯការឱ្យតំលៃ ឬមួយក៏ការយល់ខុសរបស់បុរសចំពោះពាក្យថាស្ត្រីគ្រប់លក្ខណ៍នេះ ក៏បានធ្វើឱ្យស្ត្រីក្លាយទៅជាមនុស្សអសកម្មនៅក្នុងគ្រួសារ ក្លាយទៅមនុស្សដែលមានប្រយោជន៍តិចបំផុតនៅក្នុងគ្រួសារ ។ ជាពិសេសបានក្លាយទៅជាមនុស្សដែលបានដើរចោលកិច្ចការ តួនាទី ភារកិច្ច និងការទទួលខុសត្រូវដែលអ្វីៗទាំងនោះស្ត្រីខ្លួនឯងពិតជាអាចធ្វើបានក្នុងកំរិតអតិបរមាមួយ ។ ជាឧទាហរណ៍បុរសជាប្តីតែងតែនិយាយថា "ប្រពន្ធខ្ញុំស្លូតណាស់ នាងមិនដែលបន្ទោសខ្ញុំទេ ពេលខ្ញុំធ្វើខុស" "ប្រពន្ធខ្ញុំស៊ូទ្រាំទឹកភ្នែក ពេលខ្ញុំធ្វើឱ្យនាងពិបាកចិត្ត" "ប្រពន្ធខ្ញុំបានបណ្តោយឱ្យខ្ញុំធ្វើអ្វីស្រេចចិត្ត មិនដែលហ៊ានមាត់កអីទេ" "ប្រពន្ធខ្ញុំ មិនដែលតាំងខ្លួនជាអ្នកចេះជាងប្តី ឬត្រួតប្តីទេ " ទាំងនេះហើយដែលបញ្ជាក់ថា ប្រពន្ធខ្ញុំជាស្ត្រីគ្រប់លក្ខណ៍ ។ តើបុរសត្រូវការភរិយាក្លាយទៅជាស្ត្រីគ្រប់លក្ខណ៍តាមរូបភាពនេះឬ ?

សរុបមកទោះជាយ៉ាងណាក្តីស្ត្រីទាំឡាយណាដែលចង់ក្លាយខ្លួនជាស្ត្រីគ្រប់លក្ខណ៍ ឬបុរសទាំងឡាយដែលចង់បានប្រពន្ធជាស្ត្រីគ្រប់លក្ខណ៍ មិនគួរនាំគ្នា ដើរតាមមាគ៌ានៃទស្សនៈទាំងពីរខាងលើនេះឡើយ ។ ហើយផ្ទុយមកវិញបុរស_ស្ត្រី ទាំងឡាយត្រូវនាំគ្នាឱ្យតំលៃ "**ស្ត្រីខ្មែរគ្រប់លក្ខណ៍**" ចំពោះស្ត្រីដែលអាចជួយទ្រទ្រង់គ្រួសារបាន ស្ត្រីដែលអាចក្លាយជាមេគ្រួសារបាន ស្ត្រីដែលអាចជួយប្តីបាន ស្ត្រីដែលហ៊ានទទួលខុសត្រូវចំពោះការងារធំៗក្នុងគ្រួសារ_សង្គមស្មើបុរស ស្ត្រីដែលអាចមានសមត្ថភាព និងលទ្ធភាពជួយជ្រោមជ្រែង តំរែតំរង់ទិសដៅក្នុងការដឹកនាំគ្រួសារជាមួយប្តី ស្ត្រីដែលមានការយល់ដឹងទូទៅពីសភាពការណ៍រួមក្នុងរង្វង់គ្រួសារ និងសង្គម ហើយអាចមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ដោះស្រាយ ទើបជាការប្រសើរ ។ ចំពោះស្ត្រីបើធ្វើដូចនេះបាន គឺពិត

ជាស្ត្រីគ្រប់លក្ខណ៍ ដែលសង្គមខ្មែរត្រូវការជាចាំបាច់ ក្នុងស្ថានភាពមួយដែលព្រះរាជាណាចក្រកម្ពុជាយើងកំពុងប្រឈមមុខក្នុងការប្រឆាំងនឹងភាពក្រីក្រដែលកំពុងកើតមានយ៉ាងធ្ងន់ធ្ងរនៅលើប្រទេសយើង ។

ដោយកញ្ញា ដារី

លិខិតមិត្តអ្នកអាន ៖

និស្សិតខ្មែរសូមគាំទ្រនយោបាយ ប្រឆាំងការឈ្លានពានរបស់យួន

មោទនភាពរបស់ខ្មែរពីអតីតកាលក្នុងការរស់នៅដែលប្រកបទៅដោយ កិត្តិយស សេចក្តីថ្លៃថ្នូរក្នុងដែនដីដ៏មានវិសាលភាពមួយនេះ បានត្រូវទទួលនូវការបាត់បង់ជាបន្តបន្ទាប់ ហើយដែលការបាត់បង់នេះ កំពុងបានបន្តហើយនឹងត្រូវបន្តគ្មានទីបញ្ចប់ ប្រសិនបើកម្ពុជានូវតែបន្តការទុកចិត្តទុកថ្លើមជាមួយចោរបរទេសជិតខាងយើងនេះទៀត ។ ភាពអាណិតអាសូរ ការអត់ធ្មត់ដែលគួរឱ្យកោតសរសើររបស់ខ្មែរចំពោះប្រទេសជិតខាងបានធ្វើឱ្យកម្ពុជាស្ទើរតែក្លាយទៅជាប្រទេសមួយដែលគ្មានដែនដី និងព្រំដែនពិតប្រាកដនៅលើពិភពលោក ។

ភាពជូរចត់ ការឈឺចាប់ខ្លោចផ្សារដែលបានបង្កឡើងដោយយួន និងសៀមចំពោះទឹកដីខ្មែរ ហាក់ដូចជាបានធ្វើឱ្យការអត់ធ្មត់របស់ខ្មែរជិតឈានដល់ទីបញ្ចប់ ។ ការដែលខ្មែរមិនបាននឹកនាដល់ការទាមទារអតីតទឹកដីដ៏ច្រើនសន្ធឹកសន្ធាប់ដែលត្រូវបានបាត់បង់ដោយការឆក់ប្លន់របស់យួន និងសៀម យើងយល់ថា សំរាប់ប្រទេសទាំងពីរនេះល្មមគ្រប់គ្រាន់ហើយ ។ ម្យ៉ាងទៀតយើងយល់ថា ដើម្បីផ្សះផ្សានូវការឈឺចាប់របស់ខ្មែរដែលយួន និងសៀមបានបង្កើតឡើង និងដើម្បីបង្កើនឡើងវិញ នូវទំនាក់ទំនងល្អក្នុងនាមប្រទេសជិតខាង ល្មមយួន និងសៀមឈប់បើកភ្នែកដ៏ឥតអៀនខ្មាស់របស់ខ្លួនសំលឹងមើលមកទឹកដីខ្មែរទៀតទៅ ។

ជាពិសេសសំរាប់យួនត្រូវចងចាំថា ខ្មែរបច្ចុប្បន្ននេះ មិនមែនខ្មែរសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬខ្មែរសម័យរដ្ឋកម្ពុជាដែលស្មោះស្ម័គ្រលក់ក្បាលឱ្យទៅយួន ហើយយួនធ្វើអ្វីក៏បានដែរនោះទេ ។ ពិសេសជាងនេះទៅទៀតយុវជនខ្មែរ និងនិស្សិតខ្មែរឥឡូវនេះក៏មិនមែនជាយុវជន និងនិស្សិតអាយ៉ងយួន ឬអាយ៉ងរបស់អតីតរបបដែលលើកបន្តុបឡើងដោយយួនក្រោយឆ្នាំ ១៩៧៩ នោះដែរ ។ តែធាតុពិតប្រជារាស្ត្រ យុវជន និងនិស្សិតខ្មែរមិនត្រឹមតែបានគាំទ្រនយោបាយប្រឆាំងការឈ្លានពានរបស់យួន_សៀមប៉ុណ្ណោះទេ យើងថែមទាំងបានប្តេជ្ញាក្នុងចិត្តរួចជាស្រេចថា សុខចិត្តលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីការពារទឹកដីយើង ហើយប្រឆាំងដាច់ខាតចំពោះវត្តមានរបស់យួនខុសច្បាប់លើទឹកដីកម្ពុជា ។

យុវជន និងនិស្សិតខ្មែរយើងយល់ថា វាប្រាកដជាមិនជ្រុលពេកទេ ក្នុងការដែលយើងនាំគ្នាគាំទ្រនូវនយោបាយប្រឆាំងការឈ្លានពានរបស់យួន ដើម្បីភាពគង់វង្ស និងសេចក្តីសុខសាន្តនៃប្រទេសជាតិ និងប្រជារាស្ត្រ ។ យុវជន និងនិស្សិតខ្មែរយើងយល់ថា វាមិនហួសហេតុពេកទេ ក្នុងការដែលយើងនាំគ្នាបដិសេធកាតព្វកិច្ចជាកងទ័ពដើម្បីច្បាំងគ្នាជាមួយខ្មែរក្រហម ហើយបែរជានាំគ្នាស្មោះស្ម័គ្របំពេញកាតព្វកិច្ចក្នុងនាមកងទ័ពខ្មែរវ័យក្មេង ដើម្បីធ្វើសង្គ្រាមប្រឆាំងការឈ្លានពានរបស់យួនលើដែនដីព្រះរាជាណាចក្រកម្ពុជាយើង ។

យុវជន និងនិស្សិតខ្មែរយើងយល់ថា យើងពិតជាគ្មានកំហុសទេ ប្រសិនបើយើងបានលើកលែង និងអនុគ្រោះឱ្យខ្មែរទាំងឡាយដែលបានធ្លាប់បានប្រព្រឹត្តកំហុសឆ្គងមកលើមាតុភូមិរបស់ខ្លួនពីអតីតកាល ។ តែផ្ទុយមកវិញ យើងយល់ថា យើងមានកំហុសឆ្គងដ៏សែនធ្ងន់ធ្ងរ ដែលប្រវត្តិសាស្ត្រខ្មែរមិនអាចលើកលែងឱ្យបានឡើយ ប្រសិនបើយើងនាំគ្នាព្រងើយកន្តើយ ឬអត់អោនចំពោះការឈ្លានពានរបស់ប្រទេសជិតខាង ពិសេសយួនដែលធ្លាប់បានឆក់ប្លន់ និងកំពុងប្លន់យកទឹកដីខ្មែរយើង ។

ជាចុងក្រោយយុវជន និងនិស្សិតខ្មែរសូមជូនបណ្តាំដល់ជនរួមជាតិ ជាទីគោរពថា
"ខ្មែរ គឺខ្មែរ សៀម គឺសៀម ហើយពិសេសយួន គឺយួន"
ហើយសូមកុំច្រលំឱ្យសោះថា សៀម និងយួនជាខ្មែរ ។

ដោយកញ្ញា ដារី



ទេពិការនារី :

ការទទួលស្គាល់សិទ្ធិនារីនៅមានកំរិត

បច្ចុប្បន្ននេះយើងពិនិត្យឃើញថា ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើនទៀតនៅលើពិភពលោកដែលបានចាប់ផ្តើមយកចិត្តទុកដាក់ឡើងវិញយ៉ាងខ្លាំងទៅលើស្ត្រីភេទ ។ ទាំងរាជរដ្ឋាភិបាលក៏ដូចជាសមាគម_អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធទៅនឹងស្ត្រី តែងបានយកបញ្ហាស្ត្រីនេះបំផុសឱ្យប្រជាពល_រដ្ឋដឹងថា ស្ត្រីមានសិទ្ធិស្មើនឹងបុរសនៅគ្រប់កិច្ចការក្នុងសង្គមទាំងមូល ។

ហើយជាពិសេសជាងនេះទៅទៀត ប្រការដែលបញ្ជាក់ថា ពិភពលោកបាននាំគ្នាយកចិត្តទុកដាក់ទៅលើស្ត្រី គឺដូចយើងទាំងអស់គ្នាបានដឹងហើយថាឆ្នាំនេះ ក៏ដូចជាឆ្នាំមុនៗដែរ ស្ត្រីនៅលើពិភពលោកបាននាំគ្នាប្រារព្ធធ្វើសន្និសីទស្ត្រីពិភពលោកលើកទី ៤ នៅទីក្រុងប៉េកាំងប្រទេសចិន ។ ដែលគោលបំណងនៃសន្និសីទនេះ គឺដើម្បីបង្កើតវេទិកាឱ្យស្ត្រីទាំងអស់នៅលើពិភពលោកជួបជុំគ្នា ហើយនិយាយប្រាប់គ្នាទៅវិញទៅមកពីបញ្ហាផ្សេងៗដែល

ស្ត្រីនៃបណ្តាប្រទេសនីមួយៗបានជួបប្រទះក្នុងសង្គម ហើយដើម្បីរកយុទ្ធវិធីផ្សេងៗដោះស្រាយនូវបញ្ហាដែលបានជួបប្រទះនោះឱ្យមានភាពល្អប្រសើរឡើងវិញ ។

ដោយឡែកនៅប្រទេសកម្ពុជា បើនិយាយពីរឿងសិទ្ធិស្ត្រី យើងត្រូវពិនិត្យមើលស្ថានភាពពិតរបស់ស្ត្រីថា តើស្ត្រីមានសិទ្ធិ និងមានតួនាទីធ្វើអ្វីខ្លះ ? ហើយឆ្លងតាមរយៈការប្រើប្រាស់ពាក្យ "សិទ្ធិស្ត្រី" នេះដោយប្រៀបធៀបទៅនឹងអ្វីដែលស្ត្រីអាចធ្វើបាន វាហាក់ដូចជាខុសប្លែកពីគ្នា ។ ហើយការខុសប្លែកពីគ្នានេះ វាបានបង្កើតឡើងនូវការមិនពេញចិត្តពីសំណាក់ចាស់ៗ ព្រោះពួកគាត់បានសំលឹងទៅរកអតីតកាលដែលទាក់ទងទៅនឹងប្រពៃ_ណីនៃសិទ្ធិរបស់ស្ត្រីខ្មែរ ហើយប្រការនេះបានធ្វើឱ្យចាស់ៗមានការធុញទ្រាន់ស្រគៀលត្រចៀកនឹងពាក្យថា "សិទ្ធិស្ត្រី" នេះ ។ ហើយគាត់ហាក់ដូចជាជឿជាក់ចំពោះការសំលឹងមើលឃើញរបស់គាត់ដែលថាតាំងតែពីណាពីណឹមកគាត់មិនដែលឃើញស្ត្រីរកចំរើនហោះទៅណាឆ្ងាយទេ គឺបានត្រឹមតែនៅផ្ទះដាំបាយ មើលកូនចៅ___តែប៉ុណ្ណោះ ។

ប៉ុន្តែផ្ទុយមកវិញចំពោះបញ្ហា "សិទ្ធិស្ត្រី" បើយើងនិយាយជាមួយយុវបុរសនោះ នោះពួកគាត់បានបញ្ចេញនូវកាយវិកាមួយដែលមិនទុទ្ធិដ្ឋិនិយមពេក ឬក៏សុទិដ្ឋិនិយមពេកទេ ។ ពោលគឺ យុវបុរសគាត់មិនបានសំដែងនៅការមិនពេញចិត្ត ហើយឱ្យតំលៃខ្ពង់ខ្ពស់ជ្រុលហួសហេតុពេកទៅលើប្រពៃណីនៃការប្រកាន់សិទ្ធិស្ត្រីពីអតីតកាលដូចចាស់ៗទេ ។ នេះសរបញ្ជាក់ឱ្យឃើញថា ការគោរពសិទ្ធនារី និងការឱ្យតំលៃទៅលើនារីវាពិតជាមានកំរិត ហើយតំលៃដែលមានទម្ងន់ជាងគេចំពោះសិទ្ធិស្ត្រីនោះ គឺយុវបុរស មិនមែនស្ត្រីដែលមានវ័យចំណាស់ៗទេ ។

នៅក្នុងឱកាសប្រារព្ធពិធីរំលឹកខួបដល់ការទាមទារសិទ្ធិរបស់នារីនៅលើទូទាំងពិភពលោកនាថ្ងៃទី ៨ ខែមីនា ដែលនៅប្រទេសកម្ពុជាយើងបានប្រព្រឹត្តឡើងជារៀងរាល់ឆ្នាំ ដូចប្រទេសដទៃទៀតដែរនោះ យើងសង្កេតឃើញថា ប្រភេទវ័យនៃមនុស្សទូទៅដែលមានការចាប់អារម្មណ៍ និងបានចូលរួមយ៉ាងយកចិត្តទុកដាក់នៅក្នុងទិវាបុណ្យសិទ្ធិនារីអន្តរជាតិ ស្ថិតនៅក្នុងសភាពគ្មានលក្ខណៈទូទៅ ឬក៏មានការឯកភាពគ្នាជាសាធារណៈគួរជាទីមោទនៈសំរាប់ស្ត្រីខ្មែរយើងទេ ។

ជាតួយ៉ាងដូចជាការទិញវត្ថុអនុស្សាវរីយ៍ ឬមួយក៏ការប្រារព្ធពិធីផ្សេងៗដើម្បីជាការលើកទឹកចិត្តដល់ស្ត្រីខ្មែរសំរាប់ថ្ងៃនោះ យើងមិនដែលឃើញលោកតា លោកអ៊ុំប្រុស លោកពូ ឬក៏បងប្រុស ធ្វើសកម្មភាពនេះសំរាប់ជូនទៅដល់លោកយាយ លោកអ៊ុំស្រី អ្នកមីង ឬបងស្រីទេ ។ ពោលគឺ យើងសង្កេតឃើញមានតែយុវជនធ្វើឡើងសំរាប់ សង្សារ គូរដណ្តឹង មិត្តរួមថ្នាក់ និងមិត្តរួមការងាររបស់គេដែលជានារីមានវ័យក្មេងៗតែប៉ុណ្ណោះ ។

តាមរយៈខ្លឹមសារនៃសកម្មភាពមានកំរិតនេះ យើងទាំងអស់គ្នាគួរសួរខ្លួនឯងថា តើសិទ្ធិនារីវាកើតមានតែចំពោះយុវនារីទេឬ ? ចុះស្ត្រីដែលមានគ្រួសារហើយ និងស្ត្រីដែលមានវ័យចំណាស់នោះសិទ្ធិគាត់ស្ថិតនៅឯណា ? និយាយដល់ត្រង់នេះយើងសូមសរសើរដល់យុវបុរសខ្មែរដែលបានស្គាល់ និងឱ្យតំលៃខ្ពស់ដល់ថ្ងៃ ៨ មីនា ដែលជាថ្ងៃសិទ្ធិនារីអន្តរជាតិ ។

តែនារីខ្មែរយើងក៏សូមសំណូមពរបន្ថែមទៀតដែរថា សូមកុំឱ្យយុវបុរសយើងយល់ថា "សិទ្ធិនារីមានតែថ្ងៃ ៨ មីនា" សូមបុរសៗទូទាំងប្រទេសកម្ពុជាចងចាំថា ថ្ងៃ ៨ មីនា វាគ្រាន់តែជាថ្ងៃបុណ្យរំលឹកខួបដល់ការដែលស្ត្រីទូទាំងពិភពលោកនាំគ្នាខិតខំតស៊ូទាមទារសិទ្ធិសេរីភាពរបស់ខ្លួនមកវិញ បន្ទាប់ពីត្រូវបានគេជិះជាន់ពីអតីតកាល

តែប៉ុណ្ណោះ។ ហើយសូមប្រជារាស្ត្រខ្មែរយើងយល់ថា សិទ្ធិនារីវាពុំមែនមានតែនៅក្នុងវ័យណាមួយនោះទេ គឺមានគ្រប់វ័យមានរហូតដល់ចាស់ស្លាប់ ។

ស្ត្រីខ្មែរសង្ឃឹមជាពិសេសថា យុវបុរសទាំងអស់នៅក្នុងសម័យនេះនឹងខិតខំគោរពសិទ្ធិស្ត្រី និងលើកទឹកចិត្តយ៉ាងប្រពៃដល់ស្ត្រីខ្មែរយើងរហូតដល់ខ្លួនមានគ្រួសារ និងចុងក្រោយរហូតដល់ចាស់ស្លាប់ ។ ជាងនេះទៅទៀតសង្ឃឹមថា យុវបុរសកម្ពុជានឹងខិតខំធ្វើយ៉ាងណាជួយជំរុញបន្ថែមដើម្បីឱ្យស្ត្រីខ្មែរមានសិទ្ធិពេញលេញដូចបណ្ដាស្ត្រីនៅលើពិភពលោក ។

ជាចុងក្រោយស្ត្រីខ្មែរ សូមអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាល ដល់សមាគម_អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ជាពិសេសប្រជាពលរដ្ឋគ្រប់ស្រទាប់ វណ្ណៈ គ្រប់វ័យ សូមមេត្តាបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធ្វើយ៉ាងណាឱ្យស្ត្រីខ្មែរក្លាយទៅជាមនុស្សមួយប្រភេទដែលមានគុណភាពពិតប្រាកដ និងធ្វើយ៉ាងណាឱ្យសិទ្ធិស្ត្រីខ្មែរត្រូវបានទទួលស្គាល់ជាសាធារណៈពីសំណាក់សង្គមខ្មែរយើងទាំងមូល ។

ដោយអ៊ុក ដានី

និស្សិតមហាវិទ្យាល័យពាណិជ្ជសាស្ត្រ

ទស្សនៈគួរយល់ដឹង :

តើបុរសគួរនឹងធ្វើអ្វីខ្លះ ដើម្បីសុភមង្គលគ្រួសារ ?

ធម្មជាតិបានបង្កើតមនុស្សមកឱ្យមានប្រុស និងស្រី ។ បុរស និងស្ត្រីប្រៀបបានដូចជាកំលាំងចលករមួយនៅក្នុងសង្គមដែលមិនអាចខ្វះបាន និងប្រៀបដូចជាដៃទាំងទ្វេរបស់យើង ដែលយើងត្រូវប្រើប្រាស់វាជាប្រចាំរៀងរាល់ថ្ងៃ ។ សង្គមគ្រួសារទាំងមូលចាំបាច់ត្រូវតែមានភេទទាំងពីរ ដែលជាអ្នកស្ថាបនិកនៃដំណើរជីវិតរបស់គេ ។ ប៉ុន្តែចរិកលក្ខណៈរបស់សង្គមខ្មែរហាក់ដូចជាមិនសូវមើលឃើញពីតំលៃរបស់ស្ត្រីនោះប៉ុន្មានទេ ។

ច្បាប់ទូន្មានជាច្រើន គឺការអប់រំស្ដែងឡើងហាក់បីដូចជាមានការគៀបសង្កត់តែទៅលើស្ត្រី ព្រោះឪពុកឬម្ដាយនៅក្នុងសង្គមខ្មែរភាគច្រើនតែងតែបំបិទសិទ្ធិកូនស្រីមិនសូវឱ្យរៀនសូត្រជ្រៅជ្រះ ។ ហើយដែលលោកជាបុរសក៏ជាអ្នកដែលបានតាក់តែងជាច្បាប់ដែលសំរាប់តែគៀបសង្កត់តែទៅលើស្ត្រីភេទប៉ុណ្ណោះ ។

ច្បាប់ស្រីរបស់អ្នកនិពន្ធ "ម៉ឺនម៉ៃ" បានក្លាយទៅជាការអនុវត្តន៏ជាក់ស្ដែងរបស់ស្ត្រីខ្មែរនៅក្នុងគ្រួសារ ឬមួយនៅក្នុងសង្គម ហើយដែលភាគច្រើននោះ គឺស្ត្រីខ្មែរតែងប្រកាន់ខ្ជាប់ និងអនុវត្តន៏បាន ។ ប៉ុន្តែលោកបុរសដែលខ្លួនឯងជាអ្នកដែលបានបង្កើតច្បាប់ឱ្យស្ត្រីខ្មែរគេអនុវត្តន៏នោះ បែរជាមិនបានអនុវត្តន៏ ហើយថែមទាំងច្បិចយកផលចំនេញដើម្បីជិះជាន់ស្ត្រីទៅវិញ ។

មានលោកបុរសដែលជាប្ដីរបស់គេមិនតិចទេ គឺលោកពុំដែលបានមើលឃើញពីទំហំនៃកិច្ចការផ្ទះសំបែងរបស់ស្ត្រី ដែលជាប្រពន្ធរបស់ខ្លួនទេ ។ លោកតែងតែប្រមាទចំពោះនាងជាប្រពន្ធ ហើយថែមទាំងឱ្យតំលៃយ៉ាងតិចបំផុតចំពោះនាង ។ លោកតែងប្រមាទថា "ស្រីបង្វិលចង្ក្រានមិនជុំ" តើលោកបុរសមានដែលសួរខ្លួនឯងទេថាតើលោកបានធ្វើអ្វីខ្លះសំរាប់សុភមង្គលក្នុងគ្រួសារ ? តើលោកចង់បានសិរីសួស្តីដែលមានតែស្ត្រីជាអ្នកបង្កទាំងស្រុងនៅពេលដែលលោកមិនបានចូលរួមចំណែកបន្តិចណានោះទេ ?

ជាការពិតជាក់ស្តែង ស្ត្រីគឺជាសិរីសួស្តី ស្ត្រីជាអ្នកដែលធ្វើឱ្យមានសោភ័ណ្ឌនៅក្នុងគ្រួសារ ។ ប៉ុន្តែតើវាអាចមាន សុភមង្គល មានសិរីសួស្តីឬទេ នៅពេលដែលលោកជាបុរសមិនអាចបំពេញនូវតួនាទីរបស់ខ្លួន ជាប្តី "ជាម្ចាស់" របស់គ្រួសាររបស់ប្រពន្ធនោះ ? តើបុរសគួរតែធ្វើអ្វីខ្លះដើម្បីសុភមង្គលនៅក្នុងគ្រួសារ ?

នៅក្នុងជីវិតគ្រួសារមានបញ្ហាពីរចំបងសំរាប់ផ្តល់ឱ្យមានសុភមង្គល គឺមួយជាកត្តាស្មារតី និងមួយទៀតជាកត្តាសំភារៈ ។ កត្តាស្មារតី គឺបានបំពេញ និងឱ្យស្ត្រីខ្មែរប្រតិបត្តិ និងអនុវត្ត ប៉ុន្តែចុះបើលោកជាបុរសមិនបានបំពេញនូវកត្តាសំភារៈនោះ តើវាអាចបង្កឱ្យមានសុភមង្គលដែលឬទេ ? លក្ខខ័ណ្ឌទាំងពីរខាងលើនេះ គឺជាលក្ខខ័ណ្ឌដ៏លំបាកបំផុតក្នុងចំណោមលក្ខខ័ណ្ឌទាំងឡាយ ដែលនៅក្នុងគ្រួសារត្រូវតែឆ្លងកាត់ ។ បើគ្មានលក្ខខ័ណ្ឌទាំងពីរនេះទេ ដាច់ខាតគ្រួសារមិនអាចមានសុភមង្គលស្ថិតស្ថេររឹងមាំឡើយ ។

យើងមិនបន្ទោសអ្នកអក្សរសាស្ត្រទាំងដែលធ្លាប់និយាយថា "មានលុយ គឺមានអ្វីៗទាំងអស់ គ្មានលុយគឺគ្មានអ្វីៗទាំងអស់" នោះទេ ។ ពាក្យមួយឃ្លានេះ ថ្វីត្បិតតែវាពុំត្រឹមត្រូវទាំងស្រុង ប៉ុន្តែជាការពិតចំណែកណាមួយនោះលុយកាក់ជាកត្តាសំខាន់ ។ ហេតុនេះ លោកជាបុរសគួរចងចាំថា ប្រការមួយនៅពេលស្រលាញ់គ្នា គេត្រូវការសេចក្តីស្នេហា តែនៅពេលរស់នៅជាមួយគ្នានោះ នោះបញ្ហាលុយកាក់ និងត្រូវធ្វើឱ្យសេចក្តីស្នេហាត្រូវរាយមាយ ។

ការនិយាយបែបនេះ គឺមិនមែនមានន័យមើលស្រាលដល់លោកជាបុរស ហើយយកចិត្តទុកដាក់រឿងលុយកាក់ ជាងរឿងស្នេហានោះទេ ។ តែសូមលោកជាបុរសសាកល្បងគិតទៅមើលបើគ្មានលុយកាក់ តើមិត្តអាចកសាងគ្រួសារឱ្យរស់នៅក្នុងភាពសុខស្រួលបានទេ ? ដាច់ខាតគឺទេ បើគ្មានលុយកាក់ គ្មានសំភារៈនោះសង្គមគ្រួសារពិតជាគ្មានសុភមង្គលឡើយ ។

ចំពោះការអត្ថាធិប្បាយខាងលើនេះ យើងខ្ញុំចង់និយាយថា លក្ខខ័ណ្ឌចាំបាច់ក្នុងពេលកសាងគ្រួសារ គឺត្រូវធ្វើយ៉ាងណាបង្គ្រឹះសំភារៈសំរាប់អនាគត ។ យើងចង់និយាយថា លោកជាបុរសត្រូវកសាងសមត្ថភាព និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរកលុយកាក់ បើពុំដូច្នោះទេ លោកនឹងជួបប្រទះការលំបាកនៅក្នុងដំនើរការកសាងសុភមង្គល ។

នៅក្នុងស្ថានភាពគ្រួសារមួយ ដែលគ្មានមូលដ្ឋានសំភារៈធ្វើជាគ្រឹះនោះ គឺគូរស្វាមីភរិយាច្រើនតែមានរឿងមិនល្អនឹងគ្នា ។ ប៉ុន្តែចំពោះស្មារតី នោះស្ត្រីត្រូវតែធ្វើឱ្យបានទូលាយនៅក្នុងជីវិតគូរស្រករដែរ។ បើសិនជាសំភារៈជាកត្តាកំនត់ឱ្យមានលំនឹង នោះសេចក្តីស្នេហាពិតជាធានាបាននូវអត្ថិភាពសំរាប់គ្រួសារ ។ ប៉ុន្តែបើគ្រួសារមាន

ទ្រព្យសម្បត្តិ តែប្រពន្ធមិនចេះទុកដាក់ព្រងើយកន្តើយនឹងកិច្ចការផ្ទះ ពេលនោះគ្រួសារក៏ប្រាកដជាគ្មានសុភមង្គលដែរ ។

សរុបមកគ្រួសារដ៏ឧត្តមមួយត្រូវមានលក្ខខណ្ឌទាំងពីរ គឺស្មារតី និងសំភារៈព្រមៗគ្នា ។ កសាងលក្ខខណ្ឌទាំងពីរនេះបាន ទើបសេចក្តីស្នេហាក្នុងគ្រួសារមានភាពរឹងមាំ ។ ហើយទាំងបុរស និងស្ត្រីត្រូវតែមានការយល់ដឹងពីគ្នាទៅវិញទៅមកមិនត្រូវមើលឃើញតែសំភារៈ ទើបជីវិតគ្រួសារមានសុភមង្គលនោះទេ ។

ដោយ ជេត ជុំ
និស្សិតមហាវិទ្យាល័យប្រទត្តិវិទ្យា UPP

ទស្សនៈគួរយល់ដឹង :

អត្ថន័យរូបសំណាកបុប្ផាក្រុងកែប

ក្រុងកែបជាទីរមណីយដ្ឋានមួយដ៏ល្អត្រកាលមួយនៃកម្ពុជា។ ជំនោរសមុទ្របក់ត្រសៀកនាំសូរខ្សែកៗពិរោះរណ្ដំ ផ្សំនឹងសំនៀងកកិតស្រាលៗនៃស្លឹករុក្ខជាតិ បង្កើតបានជាការប្រគុំតន្ត្រីដ៏ពិរោះល្វេងល្វើយរកស្មានមិនត្រូវ ។ ដើមដូងយោលយេរាំពត់ខ្លួនដូចនាងនាដការ ពីលើខ្នងសមុទ្រដ៏សុខមនោរម្យ ព្រៃភ្នំស្រោងស្រោងស្កុមស្កៃ--។សាយ័ណ្ហសម័យបានប្រាកដខ្លួនឡើងបង្កើតបានជាផ្ទាំងទស្សនីយភាពដ៏ស្រស់ត្រកាលគ្មានអ្វីប្រៀបផ្ទឹម ។ មើលនុះហ្ន ! ឯនាយសមុទ្រទូកនេសាទបណ្ដែតខ្លួនប្លែងប្លុងៗ មុជងើបៗ លិមៗកណ្ដាលមហាសាគរដ៏ធំល្វឹងល្វើយ ។ ប្រសិនបើយើងជាអ្នកទេសចរណ៍នៅចំពោះមុខទិដ្ឋភាពបែបនេះពិតជាពិបាកនឹងធ្វើឱ្យយើងភ្លេចពីចិន្តារម្មណ៍ណាស់ ។

ឯនេះព្រៃភ្នំដ៏ស្កុកស្កម្ភ ឯនោះវាលសមុទ្រដ៏ធំល្វឹងល្វើយ ឯនាយកោះតូច ធំរេវដិបរដុបជាច្រើនអន្លើ--- ។ បើយើងងាកមកមើលឆ្នេរខ្សាច់ដ៏វែងអន្លាយសណ្ដូកតាមមាត់សមុទ្រវិញ រលកប្រដេញគ្នារត់មកបោកឆ្នេរខ្សាច់ ជួនខ្លាំង ជួនតិចតាមតែវាយោរ ។ ចុងទីឆ្នេរដ៏ត្រកាលនេះ ដូនតាយើងបានសាងជាជ្រោយលយចូលជ្រៅទៅក្នុងសមុទ្រ និងសាងរូបស្រីសល្អស្រស់ម្នាក់ អង្គុយលែងខ្លួនទទេធ្វើវាហឺ បែរមុខឆ្ពោះទៅកាន់លំហរសមុទ្រ ហាក់ពុំរវីរវល់ទទួលស្វាគមន៍ចំពោះភ្ញៀវទេសចរណ៍ដល់តិចតួចឡើយ ។ មនុស្សគ្រប់រូបដែលបានទៅដល់ទីនោះបានយល់ឃើញពីរូបភាពនេះតាមរបៀបផ្សេងៗពីគ្នា ។ អ្នកខ្លះខិតខំទាញទស្សនៈតាមបែបវិជ្ជមាន តែមានអ្នកខ្លះខិតខំវាយតំលៃបន្ទាបបន្ថោក ហើយលេងសើចទាំងងងឹតងងុលតាមបែបអវិជ្ជមានទៅវិញ ។ តែបើពួកអ្នកទាំងនោះបានដឹងអត្ថន័យនៃរូបនេះ មិនដឹងជាគេមានចិត្តស្រពាប់ស្រពោននឹកខ្លោចផ្សាអាណិតជាតិដែរ ឬអត់ ? ខ្ញុំគិតថាពួកគេនឹងស្រក់ទឹកភ្នែកស្រណោះដែនខ្មែរ ប្រសិនបើពួកគេមានតំណក់លោហិតជាតិនិយមតែបន្តិចបន្តួចនៅក្នុងខ្លួន។

ដើម្បីជាជំនួយពញ្ញាក់ស្មារតី និងបណ្ដុះឆន្ទៈ មនសិការកូនខ្មែរឱ្យយល់ពីអត្ថន័យរូបសំណាកនេះខ្ញុំសូមរួមវិភាគទានចងក្រងឡើងវិញ នូវប្រសាសន៏របស់លោកសាស្ត្រាចារ្យជើងចាស់ម្នាក់ដែលបាននិទានប្រវត្តិនេះទាំងទឹកមុខឈឺចាប់សោកស្ដាយថា :

កូនអើយ! គ្រានោះគឺស្ថិតក្នុងអំឡុងឆ្នាំ ១៩៤៩ នៅប្រទេសចិនមានសង្គ្រាមវប្បធម៌មួយឆេះឡើងយ៉ាងសន្ធោរសន្ធៅ។ ម៉ៅ_សេទុង(Mao Tse Toung)ដែលជាមេកុម្មុយនីស្តចិនក្រហមបានវាយសន្ធាប់បណ្តេញលោកជាង_កាយជេក (Tcheang Kai Tchek) ដែលជាប្រមុខនៃចលនាសេរីចិន និងបក្សពួកឱ្យធ្លាក់ទឹករត់ដល់កោះតៃវ៉ាន់ ។ មិនអស់ចិត្តចិនក្រហមបានជំរុលទៅមុខថែមទៀតធ្វើឱ្យពួកចិនសេរីនៅមិនសុខ ហើយបានភៀសខ្លួនមកដល់ដែនសមុទ្រកម្ពុជា ហើយចាប់យកកោះត្រល់(Ile de Navette)ដែលជាកម្មសិទ្ធិរបស់ខ្មែរ ដែលតាំងនៅត្រឹមតែ ៣៦ គីឡូម៉ែត្រពីកែប_កំពតនោះជាទីសំចត ។

គ្រានោះខ្មែរយើងដែលមានកើរ្តិ៍អាករ និងរស់នៅទីនោះមានត្រឹម ១៣ គ្រួសារប៉ុណ្ណោះ ។ ដោយខ្លាចចិនសេរី គ្រួសារទាំងអស់នោះបានរត់ចេញមកតាំងទីនៅតាម សមុទ្រក្រុងកែបវិញ ។ ក្រោយពេលមកស្នាក់នៅបាន ៧ ខែសភាពការណ៏នៅតៃវ៉ាន់បានស្ងប់ស្ងាត់ ពួកចិនសេរីក៏បានវិលត្រលប់ទៅកាន់កោះតៃវ៉ាន់វិញ ។ ប៉ុន្តែខ្មែរទាំង១៣ គ្រួសារពុំបានវិលត្រលប់ទៅកាន់លំនៅដើមវិញទេ ។ ឯរាជការខ្មែរក៏ពុំបានអើពើរវីរវល់ពីបញ្ហា នេះដែរ ។ ដោយសារឃើញឱកាសហុចឱ្យ និងដោយសារមានផែនការឈ្លានពានដ៏យូរអង្វែងផង ទើបរដ្ឋការយួនបានបញ្ជូនពួកវាឱ្យមករស់នៅពេញទាំងកោះត្រល់ ។

ដោយមើលឃើញការរំលោភបំពានយ៉ាងស្រស់ៗ បែបនេះទើបរាជការខ្មែរក្រោមអាណាព្យាបាលបារាំងទាមទារឱ្យមានសន្និសីទកំរិតព្រំដែននៅខែ ១១ ឆ្នាំ ១៩៤៩ ។ ពេលធ្វើការវាស់វែង និងឯកសារនោះគឺពិតជារបស់ខ្មែរ តែដល់ពេលទៅពិនិត្យឃើញសុទ្ធតែយួន ទើបពួកអាណាចរបារាំងបារោចោរអបលក្ខណ៏កាត់កោះត្រល់ដែលជាផ្នែកមួយនៃមាតុភូមិជាទីស្នេហារបស់យើងឱ្យទៅអាចោរយួនទៅហោង ។

ដោយសារខ្មែរមានវិប្បដិសារីខ្លាំងពេក ខ្មែរក៏មានគំនិតសាងរូបស្រីម្នាក់ដែលមានរូបឆោមលោមពណ៌យ៉ាងស្រស់ស្អាត អង្គុយសំលឹងទាំងទឹកមុខស្តាយស្រណោះបែរឆ្ពោះទៅកាន់កោះត្រល់ដែលនៅឯនាយលំហរសមុទ្រ ។ ការសាងរូបនេះឡើងគឺស្ថិតក្នុងគោលបំណងឱ្យកូនខ្មែរពិចារណានឹកឃើញឡើងវិញពីដែនសមុទ្រខ្មែរនាអតីតកាល ។ កោះត្រល់នេះយើងអាចមើលឃើញប្រៀបដូចជាភ្នំដ៏ធំស្កឹមស្កៃ (ស្មើរប៉ុនខេត្តតាកែវ) នាកណ្តាលមហាសាគរ ។ សូមបញ្ជាក់ថាកោះនេះយើងអាចមើលឃើញយ៉ាងច្បាស់ពីក្រុងកែប_កំពត តែមើលពីស្រុកយួនមកមិនឃើញទេ ។ ក្រោយពេលឈ្លានពានបានមកយួនបានដូរឈ្មោះកោះនេះថា ហ្វូកុក ដែលមានន័យថា ដែនដីដ៏សំបូររុងរឿងនូវភោគទ្រព្យធម្មជាតិមិនខ្វះ ។ យួនបានរៀបចំជាតំបន់អភិវឌ្ឍន៏យុទ្ធសាស្ត្រ ព្រមទាំងលប់បំបាត់អស់រលីងនូវស្លាកស្នាមកេរ្តិ៍តំណែលខ្មែរ ។

យួនបានជិះសេះលែងដៃយ៉ាងរំភើយចំពោះបញ្ហាកោះត្រល់ ទោះខ្មែរតាស់ដូនតាស់តាមកប្តឹងអន្តរជាតិម្តងទៀតក៏មិនឈ្នះវាដែរ ។ ព្រោះថាច្បាប់អង្គការសហប្រជាជាតិបានចែងហើយ បញ្ហាព្រំដែនបើមានចោរឈ្លានពានយកបានហួសរយៈពេល ២៥ ឆ្នាំហើយពិបាកកាត់ឱ្យមកម្ចាស់ដើមឈ្នះវិញណាស់ ។ ឃើញក្រឡាអុកប្រវត្តិសាស្ត្របែបនេះ ទើបយួន និងសៀមវាប្រឹងឈ្លានពានកម្ពុជាបន្តទៀត ហើយវាដេកសង្ឃឹមថាមិនយូរទេ ២៥ឆ្នាំខាងមុខនេះវានឹងយកដីខ្មែរបានពុំខាន ។

មួយជ្រុងនៃប្រវត្តិសាស្ត្រនេះពិតជាមានតំលៃសំរាប់យុវជន_និស្សិតខ្មែរយើងណាស់ ។ សូមយុវជន_និស្សិតខ្មែរយើងទាំងក្នុងនឹងក្រៅប្រទេសរួបរួមសាមគ្គីគ្នាងើបឡើងតស៊ូ ការពារបូរណភាពដែនដី ការពារជាតិ សាសនា ព្រះមហាក្សត្រ ដើម្បីភាពគង់វង្សរុងរឿងនៃកម្ពុជា ។ យួន_សៀមវាកំពុងតែបង្រៀនកូនចៅវាឱ្យមើលឃើញដែនដីខ្មែរជានំចំណី ជាកេរ្តិ៍កម្មសិទ្ធិរបស់វាដែលត្រូវដណ្តើមឱ្យខាងតែបាន ។ ពួកវាទាំងនេះតែងមានទស្សនៈតកូនថា បើចង់អភិវឌ្ឍន៏ស្រុកទេសវាឱ្យជឿនលឿនត្រូវបង្អិនបង្ហោចប្រទេសជិតខាង ។ ចូរប្រយ័ត្ន! ខ្មែរកំពុងស្ថិតនៅក្នុងមាត់ដង្កាប់របស់ពួកវាហើយ សូមប្រញាប់ខ្លួនឡើង !!! ។

ដោយ ទិសេស_គតិយុត្តិ

និស្សិតយល់ឃើញ

- យើងយល់ឃើញថា ភាពផ្អែមល្ហែមនៃនយោបាយបង្រួបបង្រួមជាតិហាក់ដូចជាបានឈានដល់ទីបញ្ចប់ហើយ។ អ្នកដែលទទួលផលបានយ៉ាងច្រើនពីនយោបាយនេះ គឺគណបក្សប្រជាជន។ ការធ្វើសម្បទានរបស់ហ៊្វុន_ស៊ីនប៉ិច ចំពោះគណបក្សប្រជាជននៃតំណែងសហនាយករដ្ឋមន្ត្រី លទ្ធផលតបស្នងវិញ គឺគណបក្សប្រជាជនបដិសេធការបែងចែកអំណាចថ្នាក់ស្រុក ដោយមូលហេតុថា គ្មានចែងនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងច្បាប់បោះឆ្នោតទេ ។

- យើងយល់ថា ប្រសិនបើមេដឹកនាំគណបក្សប្រជាជនសំអាងទៅលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងច្បាប់បោះឆ្នោត ហើយមិនយល់ព្រមដល់ការបែកចែកអំណាចថ្នាក់ស្រុក ជូនដល់ភាគីផ្សេងៗ ដែលបានឈ្នះឆ្នោតដើម្បីធ្វើឱ្យនយោបាយបង្រួបបង្រួមជាតិទទួលបាននូវលទ្ធផលជោគជ័យទេ នោះមេដឹកនាំគណបក្សប្រជាជនម្នាក់ដែលបានទទួលតំណែងជាសហនាយករដ្ឋមន្ត្រី និងពីរ_បីនាក់ទៀត ជាសហរដ្ឋមន្ត្រីនៃក្រសួងមួយចំនួនទៀត និងបណ្តាចៅហ្វាយខេត្ត ដែលបានមកដោយសារហ៊្វុនស៊ីនប៉ិចធ្វើសម្បទានឱ្យ ត្រូវតែចុះចេញពីតំណែងទាំងអស់ ។ ព្រោះថា នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងច្បាប់បោះឆ្នោតក៏អត់បានចែងថា គណបក្សដែលចាញ់ឆ្នោតដូចគណបក្សប្រជាជនត្រូវតែបានទទួលអំណាចជាសហនាយករដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីទេ ។

- យើងយល់ទៀតថា ដើម្បីដោះស្រាយបញ្ហាខាងលើនេះបាន គណបក្សប្រជាជនត្រូវតែបន្តនូវរូបមន្តនៃការបែងចែកអំណាចឱ្យមានតុល្យភាពគ្នារវាង CPP & FUNCINPEC ពិសេសអំណាចចៅហ្វាយស្រុក ។ ធ្វើដូចនេះបាន វិបត្តិនយោបាយបង្រួបបង្រួមជាតិ ដែលកើតឡើងពីការដណ្តើមអំណាចធ្វើធំស្មើគ្នា នឹងអាចត្រូវដោះស្រាយបាន ។ ជាពិសេសជាងនេះទៅទៀត ការប្រឈមមុខគ្នាដោយអាវុធ អសន្តិសុខ អស្ថេរភាពនយោ_បាយក្នុងសង្គម ទោះបីថាមិនទាន់កើតឡើងនៅពេលនេះ តែវាប្រាកដជានឹងកើតមានឡើងនៅពេលខាងមុខដោយដោយចៀសមិនផុត ។ ការប៉ែងជើងគ្នាក្នុងពេលបំពេញការងារ ការមិនគោរពគ្នា នឹងមានឥទ្ធិពលខ្លាំងក្លាឡើង ប្រសិនបើការបែងចែកអំណាចថ្នាក់ស្រុកនេះនឹងមិនត្រូវបានដោះស្រាយតាមបែបធ្វើសម្បទានទេនោះ ។

- យើងមើលឃើញថា ក្នុងសភាពការណ៍មួយដែលនយោបាយនៅលើពិភពលោកហាក់ដូចជាបានឈានទៅរកការព្រមព្រៀងគ្នាដើម្បីបញ្ចប់នៅការឈ្លានពាន ខាងអធិបតេយ្យភាព និងបូរណភាពទឹកដី ។ ក៏ប៉ុន្តែផ្ទុយ

មកវិញ នៅព្រះរាជាណាចក្រកម្ពុជា យើងនាពេលបច្ចុប្បន្ននេះ បែរជាកំពុងប្រឈមមុខនៅការឈ្លានពានយ៉ាងកំរោលពីយួនក្នុងការលេបយកទឹកដីខ្មែរទៅវិញ ។ យើងយល់ថា ការដែលយួនហ៊ានចូលឈ្លានពានដីខ្មែរបែបនេះ ព្រោះដោយសារកម្ពុជាមានគណបក្សកុំមុយនីស្តមួយដែលកំពុងដឹកនាំប្រទេសសព្វថ្ងៃនេះគាំទ្រ និងបើកដៃឱ្យ ។

- យើងយល់ឃើញថា បច្ចុប្បន្នភាពនេះការធុញទ្រាន់ក្នុងការធ្វើសង្គ្រាមដើម្បីប្រឆាំងជាមួយខ្មែរក្រហមដែលមានឈ្មោះជាខ្មែរបានកើតមានឡើងក្នុងជួរកងយោធពលខេមរភូមិន្ទ ។ តែផ្ទុយមកវិញ កងយោធពលខេមរភូមិន្ទយើង បែរជាមានទឹកចិត្តពុះពោរក្នុងការប្រយុទ្ធប្រឆាំងជាមួយយួនដើម្បីការពារឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី ជាពិសេសកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជាតិ ។ យើងមើលឃើញថា កាយវិការជាតិនិយមរបស់កងយោធពលខេមរភូមិន្ទនេះ ត្រូវបានទទួលនូវការគោរពកោតសរសើរ និងឱ្យតំលៃយ៉ាងខ្ពង់ខ្ពស់បំផុតពីសំណាក់ប្រជាពលរដ្ឋ ។

ដោយអមរ

♥♥♥♥♥

អត្ថបទស្រាវជ្រាវ :

អំពីចំនួនប្រជាជននៅលើពិភពលោក

(តចប់)

B- ទ្វីបអាស៊ី	៣ ២៣៣.០	៤ ៩០០.៣	១.៨	២៦	៨	៦៥
a- អាស៊ីខាងកើត	១ ៣៨៧.៩	១ ៧៦២.២	១.៣	២០	៧	៧២
- ចិន	១ ២០៥.២	១ ៥៣៩.៨	១.៤	២១	៧	៧១
- កូរ៉េខាងជើង	២៣.១	៣៣.៣	១.៩	២៤	៥	៧១
- ហុងកុង	៥.៨	៦.៤	០.៨	១៣	៦	៧៨
- ជប៉ុន	១២៥.០	១២៧.០	០.៤	១១	៧	៧៩
- ម៉ុងហ្គោលី	២.៤	៤.៦	២.៦	៣៤	៨	៦៤
- កូរ៉េខាងជើង	៤៤.៥	៥០.៣	០.៨	១៦	៦	៧១
b- អាស៊ីខាងអាគ្នេយ៍	៤៦១.៥	៧១៥.៦	១.៩	២៨	៨	៦៣
- កម្ពុជា	៩.០	១៦.៧	២.៥	៣៩	១៤	៥១
- ឥណ្ឌូណេស៊ី	១៩៤.៦	២៨៣.៣	១.៨	២៧	៨	៦៣
- ឡាវ	៤.៦	៩.៤	៣.០	៤៥	១៥	៥១

_ មាឡេស៊ី	១៩,២	៣១,៣	២,៤	២៩	៥	៧១
_ ភូមា	៤៤,៦	៧៥,៦	២,១	៣៣	១១	៥៨
_ ហ្វីលីពីន	៦៦,៥	១០៥,១	២,១	៣០	៧	៦៥
_ សឹង្ហបុរី	២,៨	៣,៣	១,០	១៦	៦	៧៤
_ ថៃឡង់	៥៦,៩	៧២,៣	១,៣	២១	៦	៦៩
_ យួន	៧០,៩	១១៧,០	២,០	២៩	៩	៦៤
C- អាស៊ីខាងត្បូង	១ ២៤៤,៣	២ ១៣៩,៨	២,២	៣២	១០	៥៩
_ អាហ្វានីស្ថាន	២០,៥	៤៥,៨	៦,៧	៥៣	២២	៤៣
_ បង់ក្លាដែស	១២២,២	២២៣,៣	២,៤	៣៨	១៤	៥៣
_ ប៊ុយតាន	១,៧	៣,៤	២,៣	៤០	១៧	៤៨
_ ឥណ្ឌា	៨៩៦,៦	១ ៣៩៣,៩	១,៩	២៩	១០	៦០
_ អៀរ៉ង់ អ៊ីស្លាម	៦៣,២	១៤៤,៦	២,៧	៤០	៧	៦៧
_ ណេប៉ាល់	២១,១	៤០,១	២,៥	៣៧	១៣	៥៤
_ ប៉ាគីស្ថាន	១២៨,១	២៥៩,៦	២,៧	៤១	១០	៥៩
_ ស្រីឡាំងកា	១៧,៩	២៤,៧	១,៣	២១	៦	៧២
d- អាស៊ីខាងលិច	១៩៣,៣	២៨៦,៦	២,៧	៣៤	៧	៦៦
_ អៀរ៉ាក់	១៩,៩	៤៦,៣	៣,២	៣៩	៧	៦៦
_ អ៊ីស្រាអែល	៥,៤	៨,១	៤,៧	២១	៧	៧៧
_ ហ្សកដានី	៤,៤	១០,៨	៣,៤	៤០	៥	៦៨
_ គុយវ៉ែត	១,៨	២,៨	៥,៨	២៨	២	៧៥
_ លីបង់	២,៩	៤,៥	២,០	២៧	៧	៦៩
_ អូម៉ង់	១,៧	៤,៧	៣,៦	៤០	៥	៧០
_ អារ៉ាប៊ីសាអ៊ូឌីត	១៦,៥	៤០,៤	៣,៤	៣៦	៥	៦៩
_ ស៊ីរី	១៣,៨	៣៥,៣	៣,៦	៤២	៦	៦៧
_ ទួគី	៥៩,៦	៩២,៦	២,០	២៨	៧	៦៧
_ អារ៉ាប់រួមអេមីរ៉ាត់	១,៧	២,៨	២,៣	២១	៤	៧១
_ យីម៉ែន	១៣,០	៣៤,២	៣,៥	៤៨	១៤	៥៣
C- អឺរ៉ុប	៥១២,០	៥៤១,៨	០,៣	១៣	១១	៧៥
a- អឺរ៉ុបខាងកើត	៩៦,៩	១០៧,២	០,២	១៤	១១	៧១

- ប៊ុលហ្គារី	៨,៩	៨,៨	០,២	១៣	១២	៧២
- សាធារណរដ្ឋឆែក	១០,៤	១១,៩	០,៣	១៤	១១	៧៣
- ស្លូវ៉ាគី	៥,៣	៦,១	០,៣	១៤	១១	៧៣
- ហុងគ្រី	១០,៥	១០,៤	០,២	១២	១៤	៧០
- ប៉ូឡូញ	៣៨,៥	៤៣,៨	០,៣	១៤	១០	៧២
- រ៉ូមានី	២៣,៤	២៦,៣	០,៣	១៦	១១	៧០
b- អឺរ៉ុបខាងជើង	៩២,៨	៩៧,៨	០,២	១៤	១១	៧៦
- ដាណឺម៉ាក	៥,២	៥,១	០២	១២	១២	៧៦
- អេស្តូនី	១,៦	១,៧	០,២	១៤	១២	៧១
- ហ្វាំងឡង់	៥,០	៥,២	០,៣	១៣	១០	៧៦
- អៀរឡង់	៣,៥	៣,៦	០,២	១៤	៩	៧៥
- ឡាតវី	២,៧	២,៨	០,៣	១៤	១២	៧១
- លីទុយអានី	៣,៨	៤,១	០,២	១៥	១០	៧៣
- ន័រវែស	៤,៣	៤,៩	០,៥	១៥	១១	៧៧
- ស៊ុយអែត	៨,៧	៩,៥	០,៥	១៤	១១	៧៨
- ចក្រភពអង់គ្លេស	៥៧,៨	៦០,៣	០,២	១៤	១១	៧៦
c- អឺរ៉ុបខាងត្បូង	១៤៤,៦	១៤៨,២	០,២	១១	១០	៧៦
- អាល់បានី	៣,៣	៤,៥	០,៨	២៣	៥	៧៣
- គ្រិស	១០,២	១០,១	០,៣	១០	១០	៧៨
- អ៊ីតាលី	៥៧,៨	៥៦,២	០,១	១០	១០	៧៧
- ព័រទុយហ្គាល់	៩,៩	១០,១	០,០	១២	១០	៧៥
- អេស្ប៉ាញ៉ុល	៣៩,២	៤០,៦	០,២	១១	៩	៧៨
- យូហ្គោស្លាវី អតីត	២០,៨	២២,៦	០,៣	១៤	១០	៧២
- បូសនៀរ	៤,៥	៤,៨				
- ក្រូអេស្យា	៤,៩	៥,៣				
- ស្លូវេនី	២,០	២,២				
- យូហ្គោស្លាវី	១០,៦	១១,៥				
d- អឺរ៉ុបខាងលិច	១៧៧,៦	១៨៨,៧	០,៤	១២	១១	៧៦
- អូទ្រីស	៧,៨	៨,៣	០,៤	១២	១១	៧៦

- បែលហ្ស៊ិក	១០.០	៩.៩	០.១	១២	១១	៧៦
- បារាំង	៥៧.៤	៦០.៨	០.៤	១៣	១០	៧៧
- អាឡឺម៉ង់	៨០.៦	៨៣.៩	០.៤	១១	១១	៧៦
- ហូឡង់	១៥.៣	១៧.៧	០.៧	១៤	៩	៧៧
- ស្វីស	៦.៩	៧.៧	០.៧	១៣	១០	៧៨
D- អាមេរិកឡាទីន	៤៥៧.៧	៧០១.៦	១.៨	២៦	៧	៦៨
a- ការីបៀន	៣៤.៦	៥០.៤	១.៤	២៤	៨	៦៩
- គុយបា	១០.៩	១៣.០	០.៩	១៧	៧	៧៦
- សាធារណរដ្ឋដូមីនិក	៧.៦	១១.៤	២.០	២៨	៦	៦៨
- ហៃទី	៦.៩	១៣.១	២.០	៣៥	១២	៥៧
- ចាមៃកា	២.៥	៣.៥	១.០	២២	៦	៧៤
- ពុយអ៊ីតូ រីយ៉ូ	៣.៦	៤.៧	០.៩	១៨	៧	៧៥
- ទ្រីនិដាត តាបាហ្គោ	១.៣	១.៨	១.១	២៣	៦	៧១
b- អាមេរិកកណ្តាល	១១៨.៦	១៩៩.២	២.២	៣០	៦	៦៩
- កូស្តារីកា	៣.៣	៥.៦	២.៤	២៦	៤	៧៦
- អែលសាវ៉ាឌ័រ	៥.៥	៩.៧	២.២	៣៣	៧	៦៦
- គំរទេម៉ាលា	១០.០	២១.៧	២.៩	៣៩	៨	៦៥
- ហុងឌូរ៉ា	៥.៦	១១.៥	៣.០	៣៧	៧	៦៦
- ម៉ិកសិកូ	៩០.០	១៣៧.៥	២.១	២៨	៥	៧០
- នីហ្គារ៉ាហ្គ័រ	៤.១	៩.១	៣.៧	៤០	៧	៦៧
- ប៉ាណាម៉ា	២.៦	៣.៩	១.៩	២៥	៥	៧៣
c- អាមេរិកខាងត្បូង	៣០៤.៥	៤៥១.៩	១.៧	២៤	៧	៦៧
- អាហ្សង់ទីន	៣៣.៥	៤៥.៥	១.២	២០	៩	៧១
- បូលីវី	៧.៧	១៤.១	២.៤	៣៤	៩	៦១
- ប្រេស៊ីល	១៥៦.៦	២១៩.៧	១.៦	២៣	៧	៦៦
- ឈីលី	១៣.៨	១៩.៨	១.៦	២៣	៦	៧២
- កូឡុំប៊ី	៣៤.០	៤៩.៤	១.៧	២៤	៦	៦៩
- អេក្វាឌ័រ	១១.៣	១៨.៦	២.៣	៣០	៧	៦៧
- ប៉ារ៉ាហ្គេ	៤.៦	៩.២	២.៧	៣៣	៦	៦៧

- ពេរូ	២២.៩	៣៧.៤	២.០	២៩	៨	៦៥
- អ៊ុយរ៉ាហ្គៃ	៣.១	៣.៧	០.៦	១៧	១០	៧២
- វេណេស៊្វែលឡា	២០.៦	៣២.៧	២.១	២៦	៥	៧០
E- អាមេរិកខាងជើង	២៨២.៧	៣៦០.៥	១.១	១៦	៩	៧៦
- កាណាដា	២៧.៨	៣៨.៤	១.៤	១៤	៨	៧៧
- អាមេរិក	២៥៧.៨	៣២២.០	១.០	១៦	៩	៧៦
F- ទ្វីបអូសេអានី	២៧.៥	៤១.៣	១.៥	១៩	៨	៧៣
- អូស្ត្រាលី	១៧.៨	២៥.២	១.៤	១៥	៨	៧៧
- នូវែលសេឡង់	៣.៥	៤.៣	០.៩	១៧	៨	៧៦
- មេឡាណេស៊ី	៥.៥	១០.២	២.២	៣២	៩	៥៩
- ប៉ាពំញូហ្គេនី	៤.១	៧.៨	២.៣	៣៣	១១	៥៦
G- អតីតសហភាពសូវៀត	២៨៤.៥	៣៤៤.៥	០.៥	១៦	១០	៧០
- អាមេនី	៣.៦	៤.៥	២.៣	២៣	៦	៧១
- អាស៊ែបៃសាន	៧.៣	៨.៩	០.៨	២៧	៧	៧០
- បេឡារ៉ូស	១០.៣	១២.៣	០.១	១៦	១០	៧២
- ចរចារ	៥.៥	៦.៥	០.១	១៨	៩	៧២
- កាហ្សាស្តង់	១៧.២	២០.៨	០.៨	២៤	៨	៦៩
- គៀរកស៊ីស្តង់	៤.៦	៥.៦	១.៣	៣១	៧	៦៩
- ម៉ុលដូវី	៤.៤	៥.២	០.០	២១	១០	៦៨
- សហព័ន្ធរុស្ស៊ី	១៤៩.២	១៧៨.៧	០.២	១៦	១១	៧០
- តាស៊ីគីស្ថាន	៥.៧	៧.២	២.៥	៤០	៧	៧០
- តួកមេនីស្ថាន	៤.០	៥.០	២.៥	៣៦	៨	៦៥
- អ៊ុយក្រែន	៥២.២	៦២.៥	០.២	១៤	១២	៧១
- អ៊ុយបេគីស្ថាន	២១.៩	២៧.៣				

ស្រាវជ្រាវដោយ សេង សុផាលីន

ទំព័រកំនាព្យ ៖

សំរែកអ្នកក្រ

១- ស្នូរសំរែកអ្នកក្រ ស្រែកអង្វរអង្គទេវតា
អស់លោកគ្រប់អាត្មា ដាក់នេត្រាគួរគិតផង ។
២- ប្រឹងប្រែងនឹងកិច្ចការ សែនខ្លោចផ្សាពេកកន្លង
ហាលក្ដៅញើសហៀរខ្នង សោកសៅហ្មងមិនហ៊ានយប់ ។
៣- អត់គិតអស់កំលាំង ខំតតាំងទាំងថ្ងៃយប់
ហេវហត់ហួបមិនគ្រប់ ត្រដរទប់ទល់វាសនា ។
៤- ពេលស្ងួតត្រាំតែទឹក រោលរីកស្លឹកអង្គកាយា
ចុកចាប់ពេញឱរា ឱសង្ខារស្ទើរតែក្ស័យ ។
៥- ក្រីក្រហើយឈឺទៀត គ្រោះធម្មជាតិមិនគួរគាប់
ជោរជន់លេចលង់ទ្រព្យ រាស្ត្រតោងជាប់តែតោកយ៉ាក ។
៦- បុណ្យ-ទានគ្មានសប្បាយ ចិត្តខ្វល់ខ្វាយសែនលំបាក
យ៉ាប់យ៉ឺនឥតស្រានស្រាក ពេលចេញចាកចិត្តរឹងរៃ ។
៧- ថ្ងូចថ្ងូរស្នូររងំ ទុក្ខទួញយំតែភិតភ័យ
រស់រានដូចគ្មានន័យ រស់រំពៃក្ដីអត់ឃ្លាន ។
៨- កាយកម្មសែនស្រណោះ រស់ក្រៀមក្រោះដើរសុំទាន
លូនក្រាបជ្រកគុម្ពគៀន កាត់ខ្វាសអៀនសែនអនិច្ចា ។
៩- ចំណែកកូនចៅវិញ ទុក្ខទោម្នេញខ្វះសិក្សា
ស្លូតស្លើងគ្មានបញ្ញា រិះរកការធ្វើក៏អត់ ។
១០- តែលតោលព្រោះខ្លួនក្រ រាប់តំណសែនកំសត់
លំបាកមិនចៀសផុត ព្រោះតែអត់អីទីពឹង ។
១១- អស់លោកគួរតែគិត សូមពិនិត្យចិត្តសញ្ជឹង
កុំភ្លេចហើយត្រូវដឹង ជួយពង្រឹងឱ្យរាស្ត្ររស់ ។
១២- បើសិនលោកមិនជួយ គួរណាព្រួយដល់កេរ្តិ៍ឈ្មោះ
ជាតិខ្មែរដែលរងគ្រោះ រាស្ត្ររលួសរដួររលាយ ។

ដោយ ហែម សារិន
និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រឆ្នាំទី ២ UPP

ទំព័រកំសាន្តចិត្ត :

អាចំណាំងក៏ចេះដែរ !

ថ្ងៃមួយសមាគមនិស្សិតខ្មែរ បាននាំសមាជិកមួយក្រុមចុះទៅធ្វើកម្មសិក្សាស្រាវជ្រាវ ស្តីពីស្ថានភាពវិស័យអប់រំ សិក្សាធិការជាតិ ដែលបញ្ហានៃការសិក្សាស្រាវជ្រាវនោះ គឺចង់ដឹងពីអត្រាភាគរយនៃចំនួនប្រជាពលរដ្ឋមិនចេះអក្សរនៅតាមជនបទ ។ ការដើរសាកសួរពត៌មានចេះតែបានបន្តពីមនុស្សម្នាក់ទៅម្នាក់ទៀត ពេលនេះយើងបានទៅជួបនឹងអ៊ុំប្រុសដែលមានវ័យចំណាស់ម្នាក់ ដែលកំពុងអង្គុយជជែកគ្នានៅត្រៀមស្រាមួយ ។

អ្នកស្រាវជ្រាវ : សូមទោសលោកអ៊ុំប្រុស តើលោកអ៊ុំចេះអាសរ (អក្សរ)ទេ ?

អ៊ុំប្រុស : ក្មួយអើយ នៅស្រុកស្រែដូចអ៊ុំនេះ កុំថាឡើយអាសរ សូម្បីអាចំណាំងក៏អ៊ុំចេះដែរ មិនចាំបាច់ប៊ីយៀរ (BEER) អីទេ ។

អ្នកស្រាវជ្រាវ : លោកអ៊ុំ ខ្ញុំចង់សួរថា តើលោកអ៊ុំចេះអក្សរឬទេ ? មិនមែនខ្ញុំចង់សួរថា តើលោកអ៊ុំចេះពិសាស្រាសរឬអត់ នោះទេ ។

អ៊ុំប្រុស : អ៊ុំអត់ចេះអក្សរម៉ាតួទេក្មួយអើយ អញ្ចឹងហើយទើបអ៊ុំស្តាប់សំនួរក្មួយមិនយល់ហ្នឹងណា !

អ្នកស្រាវជ្រាវ : គួរឱ្យអាណិតលោកអ៊ុំពន់ពេកណាស់ !!!

ដោយអបរ



ប្រជារាស្ត្រខ្មែរយើងមើលឃើញថា នៅក្នុងប្រទេសកម្ពុជា ប្រសិនបើគ្មានច្បាប់ប្រឆាំងនឹងអំពើពុករលួយទេ នោះនាពេលអនាគតដ៏ខ្លីខាងមុខនេះ អ្វីៗទាំងអស់ រាប់តាំងពីសាលារៀន មន្ទីរពេទ្យ ដីធ្លី ផ្ទះសំបែង ព្រៃឈើ ប្រឡាយទឹក ទំនប់ទឹក ស្រះទឹក ផ្លូវថ្នល់ វាលស្រែ សួនច្បារ...នឹងក្លាយទៅជាកម្មសិទ្ធិផ្តាច់មុខរបស់មនុស្សពីរ-បីនាក់ដែលមានអំណាចតែប៉ុណ្ណោះ...

ព្រឹត្តិបត្រសមាគមនិស្សិតខ្មែរ

Khmer Students Association Newsletter

ឆ្នាំទី៤ លេខ០២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អាស័យដ្ឋានលេខ៧៥ វិថីលេខ១១៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក្រុងភ្នំពេញ
ទូរស័ព្ទលេខ : (855) 23 (3) 66656, (015) 914 332
ទូរសារលេខ : (855)23 26746

មាតិការឿង

~ បទវិចារណកថា : តុលាការកម្ពុជាមានឯករាជ្យ ក្នុងភាពអវិជ្ជមាន
~ បរិយាយខែនេះ : អ្វីជាសុច្ឆន្ទៈពិតរបស់និស្សិតខ្មែរយើង ?
~ ទស្សនៈនិស្សិត : ទោះបីធើជាសត្វក៏ធើដែរ ឱ្យតែរក្សាអំណាចបាន
: ខ្មែរអើយ អនាគតអ្នកយ៉ាងណាទៅ !
~ លិខិតមិត្តអ្នកអាន : សង្គ្រាមនៅកម្ពុជាកាន់តែធំ កាលណាគណបក្សកុំមុយនីស្តកាន់តែមានអំណាច
~ ស្តាប់និស្សិតស្រែក : បញ្ហាពុករលួយ និងអនាគតនៃកម្ពុជា
~ ស្តាប់គ្រូបង្រៀននិយាយ : អនិច្ចារបស់គ្រូបង្រៀននៅស្រុកខ្មែរ
~ និស្សិតយល់ឃើញ
~ អត្ថបទស្រាវជ្រាវ : អំពីចំនួនប្រជាជននៅលើពិភពលោក (នៅមានត)
~ ទំព័រកំណាព្យ : អនិច្ចាជីវិតជនពិការ
~ ទំព័រកំសាន្តចិត្ត : ខ្ញុំធ្លាប់ប៉ះគាត់ញយ

ចែកជូនដោយឥតគិតថ្លៃ

បទវិចារណកថា :

តុលាការកម្ពុជា មានឯករាជ្យក្នុងភាពអវិជ្ជមាន

ដោយអ_បូរីវង្ស

ការចែកមិនដាច់ពីគ្នារវាងអំណាចទាំងបី គឺអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ដែលបានកំនត់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យមានភាពអស់សង្ឃឹមយ៉ាងធំធេងចំពោះចេតនារបស់ប្រជារាស្ត្រកម្ពុជាក្នុងការប្រាថ្នាឱ្យតុលាការមានឯករាជ្យភាព ។ ភាពអស់សង្ឃឹមក្នុងបំណងឱ្យតុលាការកម្ពុជាមានឯករាជ្យភាព វាបានបង្កើតឱ្យប្រជារាស្ត្រមានការជឿជាក់តិចបំផុតចំពោះច្បាប់ ហើយដែលជាប្រភពធ្វើឱ្យតំលៃនៃ ការគោរពច្បាប់នៅកម្ពុជាមានកំរិតទាបបំផុត ។

នៅក្នុងបណ្តាប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ច្បាប់គឺជាឧបករណ៍សំរាប់ការពារមនុស្សទូទៅ ច្បាប់គឺវាបានតំរូវឱ្យមនុស្សគ្រប់ស្រទាប់វណ្ណៈគោរពស្មើមុខគ្នា ហើយពេលនោះឯងដែលច្បាប់បានក្លាយទៅរនាំងដ៏រឹងដែលគ្មានវណ្ណៈសំរាប់ការពារយុត្តិធម៌ជូនសង្គមជាតិ និងប្រជារាស្ត្រទូទៅ ។ ពោលគឺបើគេចង់រកខុសហើយនិងត្រូវគេនាំគ្នាទៅពឹងពាក់ច្បាប់ឱ្យរកឱ្យ មិនមែនដូចកម្ពុជាការរកខុសត្រូវតំរូវឱ្យយើងដើរទៅរកលុយឱ្យបានច្រើន និងរកអ្នកណាដែលមានអំណាចធំជាងគេឱ្យជួយដោះស្រាយនោះទេ ។ ដែលបញ្ហានេះភាពខុសនិងត្រូវ ត្រូវបានកំនត់ដោយច្បាប់ និងអ្នកកាន់ច្បាប់ដែលមានភាពឥតលំអៀងមានសច្ចៈធម៌ យុត្តិធម៌ និងមានឯករាជ្យភាពគ្រប់គ្រាន់ ហើយដែលអ្វីៗទាំងអស់នេះស្ថិតនៅក្នុងភាពវិជ្ជមាន ។

ក្រោយពីលទ្ធផលនៃការកាត់ក្តីអ្នកកាសែតជាច្រើនលើកដែលត្រូវបានប្តឹងដោយរដ្ឋាភិបាល ក្រោយពីការកាត់ក្តីចោរដែលជាឧក្រិដ្ឋជនសំខាន់ៗតែត្រូវបានរួចខ្លួនក្នុងរយៈពេលខ្លី ជាពិសេសក្រោយពីការកាត់ក្តី ស្តេចក្រុមឃុននរោត្តម សិរីវុឌ្ឍ អតីតរដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការដែលបានលាលែងពីតំណែង និងជាអតីតសមាជិកសភាជាតិដែលត្រូវបានបណ្តេញចេញពីរដ្ឋសភាជាតិ ដោយចោទប្រកាន់ពីបទប៉ុនប៉ងធ្វើឃាតសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២ និងជាអនុប្រធានគណបក្សកុំមុយនីស្ត CPP បានធ្វើឱ្យមតិជាតិ និងអន្តរជាតិយល់ថា តុលាការកម្ពុជាគ្មានឯករាជ្យទាល់តែសោះ ។ គឺជាតុលាការដែលត្រូវបានដឹកច្រមុះដោយរដ្ឋាភិបាល ដោយអ្នកមានអំណាច និងដោយអំពើពុករលួយ ។

ជាញឹកញាប់សាលក្រមរបស់តុលាការបានក្លាយទៅជាឧបរណ៍បង្កើតនូវទឹកភ្នែករាប់លានដំណក់ ការឈឺចាប់ ការអស់សង្ឃឹម ដល់អ្នករងគ្រោះ អ្នកក្រីក្រ អ្នកអត់អំណាច អ្នកគ្មានបក្សពួក អ្នកស្នេហាប្រជាធិបតេយ្យ អ្នកស្រលាញ់សិទ្ធិមនុស្សជាដើម ។ តើអ្វីៗទាំងនេះវាជាតួនាទីរបស់ច្បាប់ របស់តុលាការឬ ? តើអ្វីដែលជាប្រភពធ្វើឱ្យតុលាការកម្ពុជាក្លាយទៅជាឧបរណ៍បង្កើតឡើងនូវភាពអាស្រូវគ្មានកិត្តិយស គ្មានសេច

ក្តីថ្លៃថ្នូរ គ្មានសីលធម៌បែបនេះនោះ ? តើគ្រប់សាលក្រមរបស់តុលាការខ្មែរពិតជាសាលក្រមដែលកើតចេញពីការសំរេចរបស់ច្បាប់ពិតជាកើតចេញពីគតិបណ្ឌិតនៃច្បាប់ពិតជាកើតចេញពីយុត្តិធម៌ និងសច្ចៈធម៌មែនឬ ?

គ្រប់លទ្ធផលសាលក្រមនៃការកាត់ក្តីរបស់តុលាការកម្ពុជាត្រូវបានប្រកាស ដែលទាក់ទិនទៅនឹងក្តីក្តាំធំៗដូចជា ឧក្រិដ្ឋជន ពាណិជ្ជកម្ម សារពត៌មានពិសេសនយោបាយ___គឺគ្រប់ពេលដែលមតិជាតិនិងអន្តរជាតិតែងហួសចិត្តពីលទ្ធផលនៃការកាត់ក្តីនេះ ហើយក៏បានក្លាយទៅជារឿងគ្រប់ពេលដែលតុលាការស្រែកថាជាការកាត់ក្តីដែលមានឯករាជ្យត្រឹមត្រូវបំផុត។ តើតុលាការខ្មែរមានឯករាជ្យពិតមែនឬ? បើតុលាការខ្មែរមានឯករាជ្យ ចុះហេតុអីក៏មានគេថ្កោលទោសច្រើនម្ល៉េះ? ចុះបើយើងនិយាយថា មកពីអ្នកស្រែកមិនឯករាជ្យតើសមរម្យទេ?

បញ្ហាឯករាជ្យភាពនៃប្រព័ន្ធតុលាការកម្ពុជានេះវាហាក់ដូចជាបានក្លាយទៅជាមុខរបរសំរាប់អ្នកដែលប្រកបរបរនេះ ពិសេសអ្នកដែលមានអំណាចកំពូលៗ។ ហើយបញ្ហាឯករាជ្យភាពនេះវាហាក់ដូចជាបានបង្កើតភាពអានាធិបតេយ្យយ៉ាងពេញទំហឹងនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ។ ជាទូទៅគេសង្កេតឃើញថាតុលាការខ្មែរឆ្លៀតពេលដែលត្រូវបានគេប្រគល់នូវភាពឯករាជ្យ តាមបែបសេរីដែលមិនទាន់មានស្ថាប័នណាមួយមានសិទ្ធិពលត្រួតពិនិត្យមើលលើបញ្ហាឯករាជ្យនេះក៏នាំគ្នាបង្កើតនូវអំពើពុករលួយ បក្សពួកនិយម និងការកាត់ក្តីដើម្បីដោះដូរនឹងបុណ្យសក្តិ ឬក៏ដើម្បីអំណាចនយោបាយនៅក្នុងបក្សរបស់ខ្លួន ដោយយកបញ្ហាឯករាជ្យភាពនេះធ្វើជាលេស។ ស្ថិតក្នុងស្ថានភាពដែលកម្ពុជាបានប្រកាសខ្លួនថាជាប្រទេសប្រជាធិបតេយ្យដែលយករាស្ត្រនិងច្បាប់ជាធំទៅហើយ តើកម្ពុជានឹងត្រូវបន្តឱ្យមានភាពអនាធិបតេយ្យនៅក្នុងស្ថាប័នដែលជាអំណាច ទី៣ នេះឬ ?

តុលាការកម្ពុជាមិនគួរយកពាក្យឯករាជ្យនេះ ទៅធ្វើជាការសំរេចចិត្តតាមបែបថោកទាប គ្មានសេចក្តីថ្លៃថ្នូរ គ្មានកិត្តិយស គ្មានសច្ចៈធម៌ គ្មានយុត្តិធម៌ និងក្បត់សីលធម៌វិជ្ជាជីវៈរបស់ខ្លួននោះទេ ។ កុំយកភាពឯករាជ្យនេះឱ្យទៅជារឿងអានាធិបតេយ្យឱ្យសោះ ។ ឯករាជ្យភាពរបស់តុលាការ គឺត្រូវបូកផ្សំយុត្តិធម៌ សច្ចៈធម៌ សីលធម៌ ស្មោះត្រង់ ឥតលំអៀង អព្យាក្រិត___ទាំងនេះទើបហៅថា តុលាការឯករាជ្យ ហើយគឺឯករាជ្យក្នុងភាពវិជ្ជមាន ឬអាចហៅបានម្យ៉ាងទៀតថា ឯករាជ្យភាពក្នុងភាពថ្លៃថ្នូរ ។ មិនមែនអាងតែមានឯករាជ្យ កាត់ទោសស្រេចតែចិត្តនឹកឃើញ ត្រូវជាប់គុក ១០ ខែឱ្យទៅជាប់គុក ១០ឆ្នាំ ខុសតិចថាច្រើន ខុសច្រើនថាត្រឹមត្រូវនោះទេ___នេះគឺជាឯករាជ្យក្នុងភាពអវិជ្ជមាន ឬអាចហៅបានម្យ៉ាងទៀតថា ឯករាជ្យភាពតាមបែបថោកទាប ។

តាមពិតប្រព័ន្ធតុលាការ គឺជាប្រព័ន្ធមួយដែលមានសារៈសំខាន់បំផុត ព្រោះថាគ្រប់សង្គមនៅលើពិភពលោកយើងនេះគេត្រូវការច្បាប់សំរាប់ការពារ ។ ហេតុនេះជានិច្ចកាលច្បាប់ត្រូវតែយុត្តិធម៌ ច្បាប់ត្រូវតែបង្កើតក្តីសង្ឃឹមដល់ប្រជារាស្ត្រគ្រប់រូប ដូចនេះអ្នកកាន់ច្បាប់ត្រូវតែមានឯករាជ្យភាពពេញលេញ ។ ព្រោះថាប្រសិនបើអ្នកកាន់ច្បាប់គ្មានឯករាជ្យភាពសង្គមនឹងទៅជាអានាធិបតេយ្យ ប្រសិទ្ធភាពនៃការគោរពច្បាប់ត្រូវធ្លាក់ចុះ ការអភិវឌ្ឍន៍ប្រាកដជាអន់ថយ ។

បរិយាយខែនេះ :

អ្វីជាសុច្ឆន្ទៈពិតរបស់និស្សិតខ្មែរយើង

ដោយអ_បូរីតន្ត្រី

គ្រប់ប្រទេសនានានៅលើពិភពលោក ទាំងប្រទេសដែលមាននិន្នាការងាកទៅរកលោកសេរីភ្ជ័ កុំមុយនីស្តក្តិ ដែលនៅក្នុងនោះមានប្រទេសកម្ពុជាយើងមួយដែរ ដែលតែងនាំគ្នាចាត់ទុកថា " យុវជន និងនិស្សិតជាអនាគតទំពាំងស្នងឫស្សី ជាអនាគតនៃប្រទេសជាតិ ជាសរសរទ្រូងនៃប្រទេសជាតិ" ។

ជានិច្ចកាលយើងតែងសង្កេតឃើញថា គ្រប់រូបនៃយុវជន និងនិស្សិតយើង ក្រោយពីបានលឺបានស្តាប់នូវពាក្យខាងលើនេះ ទោះចេញពីមាត់របស់មនុស្សប្រភេទណាក្តី យុវជន និងនិស្សិតយើងមានពេលតិចណាស់ដែលយើងមិនរីករាយ មិនញញឹម ហើយមិនដែលមានទាល់តែសោះនូវភាពអស់សង្ឃឹមព្រោះតែករណីបានលឺនូវការពោលពាក្យខាងលើនេះពីនរណាម្នាក់ចំពោះខ្លួនឡើយ។ ជាងនេះទៅទៀតប្រភពដែលធ្វើឱ្យយើងរីករាយធ្វើឱ្យយើងញញឹមធ្វើឱ្យយើងមានសង្ឃឹមច្រើនជាងគេបំផុតនោះគឺប្រភពដែលចេញមកពីអ្នកដឹកនាំនយោបាយ។

កន្លងមកដោយសារភាពសរសើរ និងការឱ្យតំលៃដល់យុវជន និងនិស្សិតខ្មែរពីមជ្ឈដ្ឋាននានា ពិសេសអ្នកនយោបាយ ដោយសារការទទួលយកដោយក្តីមោទនៈ ដោយក្តីរីករាយ ដោយក្តីសង្ឃឹមចំពោះពាក្យស្លោកឬទស្សនៈ ខាងលើនេះហួសពេកក៏មិនដឹងទើបវាហាក់បីដូចជាបានធ្វើឱ្យកើតមាននូវភាពភ្លើតភ្លើន ភ្លេចអស់នូវតួនាទី ភារកិច្ចដ៏មានតំលៃ និងមានសារៈសំខាន់បំផុតក្នុងនាមយុវជន និងនិស្សិតនៃសង្គមប្រជាធិបតេយ្យដែលប្រទេសជាតិ និងប្រជារាស្ត្របានផ្ញើវាសនា។ ពោលគឺយុវជនដូចជាមិនបានបំពេញនូវតួនាទី និងភារកិច្ចដ៏មានតំលៃនិងប្រកបទៅដោយកិត្តិយសរបស់ខ្លួនជូនជាតិ និងប្រជារាស្ត្រទេតែបែរជានាំគ្នាធ្វើសកម្មភាពគ្រប់យ៉ាងដើម្បីជាប្រយោជន៍ឱ្យអ្នកកាន់អំណាចផ្តាច់ការ ពុករលួយ រំលោភសិទ្ធិមនុស្សមួយចំនួនដែលកំពុងតែដឹកនាំប្រទេសសព្វថ្ងៃនេះទៅវិញ ។

ជាទូទៅនៅស្ទើរគ្រប់ប្រទេសក្នុងពិភពលោកស្ថិតក្នុងស្ថានភាពមួយដែលសង្គមគ្មានស្ថេរភាព សន្តិសុខមានមិនគ្រប់គ្រាន់ និងអ្វីៗផ្សេងទៀតដែលជាផលប្រយោជន៍ជាតិ_ប្រជារាស្ត្រត្រូវទទួលរងនូវការបាត់បង់ព្រោះតែអ្នកដឹកនាំនយោបាយរបស់ប្រទេស ភាគច្រើនគេសង្ឃឹមទៅលើកំលាំង និងសំលេងយុវជនដែលជានិស្សិតថានឹងអាចធ្វើអ្វីៗដើម្បីឱ្យស្ថានការណ៍ដែលអាក្រក់ទាំងនេះមានភាពល្អប្រសើរឡើងបាន ។ ព្រោះគេយល់ថានៅក្នុងសង្គមទាំងមូលអ្នកដែលបានទទួលនូវការអប់រំខ្ពស់បំផុត ហើយដែលអាចយល់ដឹងបានជ្រៅជ្រះនូវបញ្ហាវប្បធម៌ជាតិ សេដ្ឋកិច្ច នយោបាយដឹកនាំជាតិ និងប្រព័ន្ធច្បាប់ផ្សេងៗ ។

ប៉ុន្តែមួយរយៈកន្លងមកនេះ មានហេតុការណ៍ដ៏សែនអាក្រក់ និងអាប់អួរបំផុតដែលបានកើតចេញពីសកម្មភាពរបស់យុវជន និងនិស្សិតខ្មែរយើងមួយចំនួន ។ ដូចជាការដែលនិស្សិតបានក្លាយទៅជាអ្នកតាមដាន

ស៊ើបការណ៍ការងារយុវជនគ្នាឯងឱ្យអ្នកដឹកនាំនយោបាយផ្តាច់ការ និស្សិតបានក្លាយទៅជាកំលាំងប្រឆាំងចលនាសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ និស្សិតបានក្លាយខ្លួនទៅជាអ្នកដើរហែរហមហែអើជាមួយជនក្បត់ជាតិក្បត់ប្រជារាស្ត្រ ពុករលួយ លោភសង្គ្រាម ។ និងជាពិសេសជាងនេះទៅទៀត គឺតាមរយៈសកម្មភាពវាយអ្នកកាសែតម្តងជាពីរដង ការធ្វើបាតុកម្មប្រឆាំងស្ថានទូតអូស្ត្រាលី ការសរសេរលិខិតគាំទ្រអ្នកដឹកនាំប្រទេសផ្តាច់ការចំពោះការដាក់ទោសដ៏ធ្ងន់ធ្ងរលើអ្នកស្នេហាជាតិប្រជាធិបតេយ្យដែលគ្មានកំហុស ។

គឺតាមរយៈសកម្មភាពទាំងនេះហើយ ដែលប្រទេសជាតិ និងប្រជារាស្ត្រខ្មែរយើងយល់ថា យុវជននិងនិស្សិតខ្លួនឯងដូចជាកំពុងបានព្រមព្រៀងគ្នាដោយចេតនានាំកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួនដែលមិនអាចកាត់ថ្លៃបានតាមរយៈពាក្យស្លោក ឬទស្សនៈខាងលើនេះ ឈានទៅរកភាពអស់សង្ឃឹមសំរាប់ជាតិ ឈានទៅរកការបង្កើតភាពស្អុយគគ្រុកសំរាប់វ័យដ៏ត្រចះត្រចង់របស់ខ្លួន ។

ក្នុងស្ថានភាពដែលប្រទេសជាតិមានភាពអាប់អួរដូចសព្វថ្ងៃនេះ តើយើងគួរនាំគ្នាធ្វើអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងសភាពការណ៍នេះ និងដើម្បីជាប្រយោជន៍ជាតិ និងប្រជារាស្ត្រយើងផង ? តើនិស្សិតខ្មែរយើងត្រូវមានសុច្ឆន្ទៈបែបណាដើម្បីប្រែក្លាយខ្លួនឱ្យទៅជាកំលាំងនិងសំលេងរបស់ជាតិ និងប្រជារាស្ត្រដែលកំពុងតែត្រូវរងគ្រោះព្រោះសភាពការណ៍បច្ចុប្បន្ននេះ ។ តើសកម្មភាពនិយមការជប់លៀងស៊ីផឹកការសប្បាយរីករាយព្រោះបានទទួលលាភសក្ការៈពីអ្នកដឹកនាំនយោបាយពុករលួយ ការដើរហែរហម ហែអើតាមអ្នកនយោបាយផ្តាច់ការ ការដែលបាននាំគ្នាលក់ឧត្តមគតិ លក់មនសិការ ដើម្បីប្តូរយកនូវមុខមាត់លុយកាក់បុណ្យស័ក្តិដែលមិនឋិតថេរទាំងនេះឬដែលជាសុច្ឆន្ទៈរបស់និស្សិតខ្មែរយើង ?

យុវជនគួរយល់ថា ក្នុងស្ថានភាពមួយដែលប្រទេសគ្មានស្ថេរភាពនយោបាយ គ្មានសន្តិសុខគ្រប់គ្រាន់ងាយស្រួលក្នុងការបែកបាក់ប្រេះឆា សំបូរបែបទៅដោយការរំលោភច្បាប់ រំលោភសិទ្ធិមនុស្ស និយមភាពផ្តាច់ការ ប្រឈមមុខនឹងការបាត់បង់អធិបតេយ្យភាព បូរណភាពទឹកដី អំពើហឹង្សា និងភេរវកម្មផ្នែកនយោបាយជាដើម តើខ្លួនគួរធ្វើអ្វីបានខ្លះដើម្បីជួយប្រទេសរបស់ខ្លួនក្នុងនាមយុវជនជាទំពាំងស្នងឫស្សីជាសរសរទ្រូងនៃប្រទេសជាតិ និងជាអនាគតប្រទេសជាតិនោះ ? យើងត្រូវសួរខ្លួនយើងថា បើយើងមិនអាចជួយស្រោចស្រង់ប្រទេសយើងបានចំពោះស្ថានភាពតានតឹងបែបនេះបានទេ តើយើងគួរត្រូវប្រកាន់នូវជំហរបែបណាដើម្បីសមជាយុវជនដែលជាក្តីសង្ឃឹមរបស់ជាតិនាពេលអនាគត ?

មធ្យោបាយពីរដែលយុវជន និងនិស្សិតខ្មែរអាចធ្វើបាន ហើយដែលរក្សាបាននូវកិត្តិយស សេចក្តីថ្លៃថ្នូរសំរាប់វ័យរបស់ខ្លួនទុកជារង្វាន់សំរាប់ប្អូនៗ កូនៗ និងចៅៗយើងជំនាន់ក្រោយដើម្បីយកជាគំរូបាន ។ ទីមួយ យុវជន និងនិស្សិតបើសភាពការណ៍ជាតិមានភាពធ្ងន់ធ្ងរដែលបង្កឡើងដោយអ្នកដឹកនាំប្រទេសផ្តាច់ការ ហើយយើងគ្មានសមត្ថភាពនឹងអាចជួយស្រោចស្រង់បាន គឺយើងត្រូវរក្សាខ្លួនយើងឱ្យនៅជាអព្យាក្រិត ឱ្យស្ថិតនៅក្នុងភាពឯករាជ្យ មិនក្លាយទៅជាអាយ៉ង ពិសេសមិនត្រូវក្លាយខ្លួនទៅជាឈ្នាន់ឱ្យអ្នកដឹកនាំនយោបាយផ្តាច់ការឡើយ "ជួយជាតិមិនបាន កុំជួយជនផ្តាច់ការ ឬរដ្ឋាភិបាលផ្តាច់ការ"។ ទីពីរទោះជាស្ថិតនៅក្នុងករណីអាច

ឬមិនអាចក្តីយុវជនត្រូវតែហ៊ានតស៊ូលះបង់ដើម្បីជាគំរូដល់ប្រជារាស្ត្រ ក៏ប៉ុន្តែសកម្មភាពជាគំរូនោះជានិច្ចកាលត្រូវតំកល់ផលប្រយោជន៍ជាតិ និងប្រជារាស្ត្រជាធំ មិនមែនប្រយោជន៍របស់បុគ្គលម្នាក់_ពីរនាក់នោះទេ ។

ផ្ទុយមកវិញប្រសិនបើការលះបង់របស់យើងប្រាសចាកពីផលប្រយោជន៍ជាតិ និងប្រជារាស្ត្រនោះ សកម្មភាពជាគំរូនោះ នឹងក្លាយទៅជាសកម្មភាពដ៏សែនលាមកបំផុត ហើយប្រវត្តិសាស្ត្រនឹងកត់ត្រាទុកនូវរាល់ភាពអាស្រូវទាំងនេះ ។ ប្រទេសជាតិ និងប្រជារាស្ត្រពឹងផ្អែកលើយុវជន និងនិស្សិតយើងហើយសង្ឃឹមថាយុវជន និងនិស្សិតយើងពិតជានឹងក្លាយទៅជាឫស្សីដែលមានគុណភាព សរសរទ្រូងដែលរឹងមាំ និងក្លាយទៅជាអ្នកកសាងអនាគតកម្ពុជាដែលមានភាពវិជ្ជមានគ្រប់វិស័យ ។

ជាចុងក្រោយយុវជន និងនិស្សិតយើងត្រូវតាំងខ្លួនជាអ្នកផ្សះផ្សាជាតិក្នុងកាលៈទេសៈដែលជាតិបែកបាក់ ជាអ្នកឯករាជ្យក្នុងកាលៈទេសៈដែលជាតិឃ្លីងឃ្លោងមិនបិតបេរ ជាសំលេងដែលតំណាងឱ្យជាតិខ្មែរនៅពេលដែលជាតិខ្មែរមានតែសំលេងបុគ្គលនិងបក្ស ក្លាយទៅជាកំលាំងរបស់ជាតិ នៅពេលដែលជាតិខ្សោយ នឹងត្រូវតាំងខ្លួនជាអាវុធសំរាប់កំទេចនូវអ្វីៗទាំងអស់ដែលនឹងបំផ្លាញដល់ប្រយោជន៍ជាតិ ។

សុច្ឆន្ទៈរបស់យុវជន និងនិស្សិតខ្មែរបែបនេះឯងដែលជាតិ និងប្រជារាស្ត្រត្រូវការ សូមកុំច្រលំថាសកម្មភាពទៅវាយអ្នកកាសែតម្តងពីរដង ការធ្វើបាតុកម្មប្រឆាំងស្ថានទូតអូស្ត្រាលី ជាពិសេសការគាំទ្រអ្នកដឹកនាំនយោបាយខ្មែរផ្តាច់ការម្នាក់នោះ ក្នុងការកំទេចអ្នកស្នេហាជាតិប្រជាធិបតេយ្យនោះ ថាជាសេចក្តីត្រូវការរបស់ជាតិ និងប្រជារាស្ត្រខ្មែរយើងឱ្យសោះ ។

ទស្សនៈនិស្សិត :

ទោះបីធើជាសត្វក៏ធើដែរ អោយតែរក្សាអំណាចបាន

នៅពេលដែលស្ថានភាពទូទៅនៅក្នុងប្រទេសកម្ពុជា បានធ្លាក់ចុះបន្តិចម្តងៗទៅនោះ ការកើនចំនួនយ៉ាងច្រើននៃអ្នកនយោបាយខ្មែរ គ្រប់ម៉ាក គ្រប់ប្រភេទនៅក្នុងប្រទេសនេះ ក៏បានរីកឡើងទៅតាមសភាពការណ៍ និងការវិវត្តន៍របស់ប្រទេសនេះផងដែរ ។ នៅក្រោមពាក្យថាស្នេហាជាតិ ស្នេហាទឹកដី ស្នេហាប្រជាជន-- ហើយស្របពេលទៅនឹងកាលៈទេសៈប្រទេសជាតិដុនដាបផងនោះ សំរាប់ខ្មែរភាគច្រើន ការធ្វើនយោបាយហាក់ដូចជាកាក់កបខ្លាំងណាស់ ហើយប្រហែលជាបុព្វហេតុតែមួយគត់ដែលធ្វើអោយខ្មែរយើងជាច្រើន បានអោយអាទិភាពជាចំបងបង្អស់ទៅលើការធ្វើនយោបាយជាជាងធ្វើអ្វីៗផ្សេងទៀត។ ពោលគឺមានអ្នកនយោបាយច្រើន "រាប់ភ្លេច "បានផុសចេញពីគ្រប់ទិសទី គ្រប់ស្រទាប់វណ្ណៈ តាំងពីលើរហូតដល់ក្រោម តាំងពីទីក្រុងរហូតដល់ជនបទដាច់ស្រយាល

ដោយរួមមានទាំងស្រទាប់បញ្ញាវ័ន្តខ្ពស់ៗរហូតដល់អ្នកមិនស្គាល់ និងមិនចេះអក្សរខ្មែរមួយតួ ពីអ្នកជំនួញធំៗ រហូតដល់អ្នកកាប់ជ្រូក អ្នកឡើងត្នោត ចោរលួចមាន់លួចគោ ដែលត្រូវបានគេវាយអោយបាក់ដៃបាក់ជើង និងធ្វើអោយខ្វាក់ភ្នែកជាដើម ។ ហើយដែលអ្នកទាំងនោះសុទ្ធតែជាអ្នកបានបង្វែរនូវអាជីពដើមរបស់គេ មកធ្វើជាអ្នកនយោបាយ ខ្លះក៏ជាអ្នកនយោបោកដែលកំពុងតែពេញនិយមជាមួយនឹងលទ្ធផលនៃការតស៊ូយ៉ាងប្តូរផ្តាច់របស់ពួកគេដែលមានកន្លងមកហើយ ។

ជាច្រើនឆ្នាំមកនេះ សំរាប់អ្នកនយោបាយខ្មែរការធ្វើនយោបាយគឺជាការស្វែងរកអំណាចដែលជា អំណាចអាចបំពេញបាននូវគោលបំនង និងមហិច្ឆតារបស់គេរៀងៗខ្លួន ប៉ុន្តែសំរាប់អ្នកមានអំណាចវិញនោះ បើទោះបីជាមានវិសាលភាពប៉ុណ្ណា ហើយនៅក្នុងស្ថានភាពបែបណាក៏ដោយ តែរាល់ការធ្វើនយោបាយរបស់គេ ហាក់ដូចបានបង្ហាញអោយឃើញត្រឹមតែជាបេសកកម្មដ៏ធំមួយសំរាប់ធ្វើការបំភ័ន្ត និងបំភ្លៃអោយបាននៅក្នុងគោលបំណងបិទបាំងអោយជិតនូវរាល់អំពើដ៏លាមករបស់ខ្លួន ដើម្បីគេចអោយផុតពីអ្វីៗជាការពិតទាំងអស់ដែលកំពុងតែតាមផ្តន្ទានូវរាល់អំពើអាក្រក់របស់គេទាំងអស់ ។

ការធ្វើនយោបាយដើម្បីទាមទារអំណាច ការរក្សាអំណាចដោយការធ្វើនយោបាយប្រកបដោយប្រជាប្រិយភាព និងមានឥទ្ធិពលយ៉ាងធំសំបើមនេះហើយ ដែលវាប្រហែលជាប្រការតែមួយគត់ដែលមកទល់នឹងពេលបច្ចុប្បន្ន វាហាក់ដូចជាបានក្លាយទៅជាទិសដៅនៃសេចក្តីប៉ងប្រាថ្នា ឬជាមុខរបរ មុខជំនួញ ឬជាទំនិញដ៏មានតំលៃរបស់មនុស្សភាគច្រើនទៅហើយដែរ ។ ប៉ុន្តែអ្វីដែលមានការប្លែកគ្នាត្រង់ថាមានមធ្យោបាយ និងសិល្បវិធីនៃការផ្តើមការធ្វើនយោបាយជាមួយនឹងការរក្សាអំណាច ឬថាការជួញដូរនូវវត្ថុដែលមានតំលៃ និងពេញនិយមរបស់ពួកគេមានសភាពផ្សេងៗគ្នាទៅតាមឧបនិស្ស័យ និងបុគ្គលិកលក្ខណៈនៃអ្នកនយោបាយនីមួយៗ ។

អ្នកនយោបាយខ្លះនិយមនូវភាពទន់ភ្លន់ សុភាពរាបសារ ដឹងនូវហេតុ និងផល ល្អនិងអាក្រក់ដែលគួរជាទីពំនាក់ និងទំនុកចិត្តទៅលើក្តី សង្ឃឹមនៃជនអភ័ព្វខ្មែរ ខ្លះមាននិស្ស័យជាមនុស្សប្រជាភិថុតបោកប្រាស់ ទៅលើមនុស្សដែលខ្វះការពិចារណា ខ្វះសុភវិនិច្ឆ័យទៅវិញ ។ ពួកគេបាននឹងកំពុងត្រូវធ្វើអាជីវកម្មដោយអ្នកនយោបាយបែបនេះ ហើយដែលអ្នកនយោបាយ ទាំងនោះមិនគួរជាទីគោរពរាប់អាន និងត្រូវបានអោយតំលៃទាល់តែសោះទោះបីថានៅក្នុងស្ថានភាពបែបណាក៏ដោយ ។ តែអ្នកនយោបាយខ្លះមាននិស្ស័យត្រឹមតែជាអ្នកនយោបាយសាហាវឃោរឃៅ និយមតែការកាប់ចាក់ ការសំលុតគំរាមគំហែង ការបោកប្រាស់កុហកភូតភរ ប្រើចុងកាំភ្លើងដើម្បីទទួលបាននូវអំណាច ឬ ក៏ថាដើម្បីរក្សាអោយបាននូវរបស់តែមួយគត់ដែលមិនអាចអត់បានវាជាអំណាចដែលមានស្រាប់មកហើយ ហើយត្រូវពង្រឹងវាអោយមានទាំងកំលាំង ទាំងឥទ្ធិពលបានកាន់តែខ្លាំងឡើង ។

ដូច្នេះរាល់អ្នកនយោបាយណាក៏ដោយដែលមាននិស្ស័យបែបចុងក្រោយនេះ ថ្វីបើមានខ្លួនជាមនុស្សធំទាំងឈ្មោះ ខ្ពស់ទាំងមាឌ តែគំនិតរបស់អ្នកនោះមិនខុសពីសត្វព្រៃទេ អាចថាជាសត្វខ្លាឬថាជាសត្វតោបាន ព្រោះអីមានតែសត្វព្រៃបែបខ្លា ឬបែបតោនេះទេដែលយើងជាមនុស្សគ្រប់រូប កុំថាឡើយដល់ទៅឃើញផ្ទាល់ភ្នែកគ្រាន់តែការនឹកភ្នកដល់សត្វទាំងអស់នោះ ក៏យើងតែងតែខ្លាចរអានឹងឈ្មោះវារួចជាស្រេចទៅហើយ ។ ហើយសំរាប់អ្នកនយោបាយដែលធ្វើអោយមនុស្សផងទាំងពួងខ្លាចរអា គឺជាអ្នកនយោបាយដែលគ្មានតំលៃបន្តិចសោះ ព្រោះថាគេ

ម្នាក់ៗភ័យខ្លាចនឹងអំណាចរបស់អ្នកនយោបាយម្នាក់ហ្នឹងបាន ។ ជាការពិតណាស់ដែលគេមិនអាចអោយតំលៃអ្នកនយោបាយធុនហ្នឹងបានដោយសារការភ័យខ្លាចរបស់គេនោះ អោយស្មើនឹងលាមកសត្វខ្លាឬសត្វគោផង ។ ដោយហេតុថា អ្នកនយោបាយនេះជាអ្នកនយោបាយដែលមិនដឹងអ្វីដែលល្អ មិនដឹងអ្វីដែលអាក្រក់ យកវេទិកាឈ្នះ_ចាញ់ដោយហឹង្សា មកដោះស្រាយវិបត្តិទាំងងងើល ជាអ្នកនយោបាយដែលខ្វះការពិចារណា គុណធម៌ យុត្តិធម៌ និងគតិធម៌ ហើយដែលគេតែងតែគិតថាគ្មាននរណាទាល់តែសោះដែលមានសមត្ថភាពស្មើខ្លួនក្នុងការធ្វើអោយប្រទេសជាតិរីកចំរើនបាន ។

ពេលនេះអ្វីដែលជាការព្រួយរបស់ខ្មែរគ្រប់ៗរូបនោះ គឺការបង្កិនបំផ្លាញប្រទេសជាតិបន្តិចម្តងៗ របស់អ្នកនយោបាយបែបនេះដោយនយោបាយប្រជាភិថុតក្រោមផ្លាកថា ស្នេហាជាតិ ស្នេហាប្រជាជនរួមជាមួយនឹងនយោបាយផ្តាច់ការរបស់វា។ តើវាជាការស្នេហាជាតិពិត ឬជាប្រការដែលខ្លួនបារម្ភពីការបាត់បង់អំណាចទៅវិញទេ ?

បើពិតជាស្នេហាជាតិមែននោះ ការបង្ហូរឈាមខ្មែរដោយសារសង្គ្រាមពិតជាមិនកើតមានទេ !!!!

សង្គ្រាមបង្ហូរឈាម គឺជាចេតនារបស់ភាគីជំលោះ !!!!

ភាគីជំលោះត្រូវតែទទួលខុសត្រូវ លើភាពហិនហោចដោយសារសង្គ្រាមទាំងនេះ !!!!

ដោយមាលាដួងចិត្ត

ទស្សនៈនិស្សិតៈ

ខ្មែរអើយអនាគតអ្នកយ៉ាងណាទៅ !

ស្ថានការណ៍សង្គមកម្ពុជាបច្ចុប្បនេះធ្វើអោយខ្មែរទាំងឡាយ ពិតជាមិនដឹងថា តើវាសនាអនាគតរបស់ខ្លួនយ៉ាងណានោះទេបើអតីតកាលដ៏ជូរចត់វានៅ តែដើរតាមយើងដូចជាស្រមោលអន្ទោលតាមប្រាណជានិច្ចបែបនេះ ឬមួយមកពីខ្មែរជាជនជាតិមួយមានចិត្តធម៌មេត្តាពេកទេដឹង? ខ្មែរច្រើនតែមើលបំណាំគ្នាទៅវិញទៅមក ភាគច្រើនខ្មែរខ្វះភាពឈឺឆ្អាលចំពោះជាតិខ្លួនលៃយ៉ាងណាអោយតែអាត្មាអញស៊ីឆ្អែត ដេកស្រួល មានកិត្តិយស មានអំណាចទៅបានហើយ។ ម៉្យាងវិញទៀតខ្មែរខ្វះភាពឈឺចាប់ទោះជាបរទេសឈ្លានពានមើលងាយខ្លួនយ៉ាងណា ជាតិខ្លួនយ៉ាងណាក៏នៅតែលើកគេទូលដែរ តែបែរជាមកគ្រាន់បើដាក់ខ្មែរគ្នាឯងឯណេះទៅវិញ។ ម្នាក់ៗសុទ្ធតែចាត់ទុកថាខ្លួនគ្រាន់បើនិយាយហារទ្បើងសុទ្ធតែអញគ្មានអាណាដល់ខ្លួន ។

ពិតជាគួរអោយខ្មាសដូនតា និងប្រវត្តិសាស្ត្រខ្មែរមែនព្រោះថា ខ្មែរយើងជាជនជាតិមួយគួរអោយកោតស្ញប់ស្ញែង រុងរឿងតាំងពីបុរាណកាល ។ គ្រានោះខ្មែរមានគំនិតស្នេហាជាតិមែនទែន ទឹកដីខ្មែរមានវិសាលភាពធំល្វឹងល្វើយមិនចាញ់ប្រទេសចិននិងឥណ្ឌាឡើយ ។ ចំពោះការរីកចំរើនផ្នែកសេដ្ឋកិច្ចជាតិក៏មិន

អន់ជាងបរទេសនានានៅជិតខាងយើងផង ។ ខ្មែរអាចសាងសង់ប្រាសាទរាប់រយពាន់បង្ហាញពីភាពអស្ចារ្យរបស់ខ្មែរ និងទុកជាកេរ្តិ៍តំណែលប្រវត្តិសាស្ត្រដែលមានតំលៃមិនអាចកាត់ថ្លៃបាន ព្បិតអីគេអាចស្គាល់ខ្មែរបានក៏ដោយសារតែភាពល្បីល្បាញនៃបុរាណប្រាសាទនានា ពិសេសអង្គរវត្តនេះតែម្តង ។ ម្យ៉ាងទៀតគេអាចស្គាល់ខ្មែរតាមរយៈការរួបរួមសាមគ្គីគ្នា ការឯកភាពជាតិ ការដឹកនាំប្រកបដោយទសពិធរាជធម៌របស់អ្នកដឹកនាំជាតិ ។

ចុះបច្ចុប្បន្ននេះវិញគេស្គាល់ខ្មែរដោយសារអ្វី ? គឺមិនដោយសារភាពហឹង្សាកាប់សំលាប់ជនជាតិឯងគ្មានត្រាប្រណីនោះទេឬ? បច្ចុប្បន្នអ្នកដឹកនាំខ្មែរស្គាល់តែបរទេស ទូតែបរទេស ហើយបែរក្បាលមកប្រឈមមុខ និងពាក់មុខយក្សដាក់ជាតិឯងទៅវិញ ។ គួរអោយអាម៉ាស់ណាស់ខ្មែរពេលនេះសល់តែផ្លាកឃីហោ និងដូចជារាងកាយសាកសពគ្មានវិញ្ញាណ ។ ធាតុពិតខាងក្នុងស្ទើរគ្មានអ្វីទាល់សោះ សូម្បីដីដែលសល់តែមួយចង្អាមក៏រក្សាស្ទើរតែមិនបានទៅទៀត។ ងាកទៅលិចត្រូវចោរប្រវត្តិសាស្ត្រមើលងាយដូចសត្វធាតុ ងាកបន្តិចទៀតទៅទិសខាងកើតត្រូវចោរប្រវត្តិសាស្ត្រទីពីរស្ទើរស៊ីសាច់ហុតឈាមតើខ្មែរបច្ចុប្បន្នគួរដើរតាម ទិសណាបើងាកបន្តិចមើលជុំវិញខ្លួនឃើញមានតែសត្រូវយ៉ាងនេះ ? បច្ចុប្បន្ននេះសភាពការណ៍កម្ពុជាប្រៀបបាននិងសម័យនៃការបែងចែកទឹកដីខ្មែរជាពីរគឺចេនឡាទឹក និងចេនឡាគោក។ ដោយសារកាលនោះខ្មែររវល់តែទាស់គ្នាគិតតែពីរឿងអំណាចចោរផ្កាមិនខ្លាចចូលមកយាយីយកទឹកដីដែលបែងចែកជាពីរសំលាប់ប្រជារាស្ត្រព្រមទាំងស្តេច ។

"ឥឡូវត្រូវពេលសន្ធត យួនបានកំនត់ប្រឹងតស៊ូ តាមលិទ្ធិមិញជីហ្វ ស៊ូស្លាប់ប្រឹងប្តូរយកដីខ្មែរ ។ ឯចោរសៀមក៏មិនអន់ ប្រឹងខំលួចបន់អោយយួន ប្លន់ខ្មែរអាងបានខ្លួន អាចចូលតាមយួនមកលួចដែរ ។"

ចោរយួនចោរសៀមអាចោរទាំងពីរ ខិតខំវាតទីយកទឹកដីខ្មែរ
ដែលតាមពិតទៅខ្មែរជាឪម៉ែ អាសៀមហៅឡៃលេងម៉ែឪ ។
ចំណែកខ្មែរឯងមិនចាប់គិត មិនប្រើគំនិតគិតលកលៃ
តើធ្វើយ៉ាងណាទើបប្រពៃ រក្សាដែនដីអោយគង់វង្ស ។
មួយថ្ងៃៗគិតស្រីស្រា បនល្បែងក្នុងបាររាល់យប់ថ្ងៃ
ពេលអស់កម្លាំងដេកមិនសំចៃ រហូតទេសថ្ងៃទើបទៅធ្វើការ ។
រីឯអ្នកក្រប្រឹងត្រដររស់ រកស៊ីមួយពោះរស់តែមួយថ្ងៃ
លះដល់ពេលយប់ដេកលកលៃ តើស្អែកបានអ្វីចំអែតក្រពះ។

តើខ្មែរបច្ចុប្បន្ននេះចង់ក្លាយខ្លួនទៅជាខ្ញុំកញ្ជះគេទៅឬ ? ដើមឡើយជាតិខ្មែរធ្លាប់ជាចៅហ្វាយគេនោះ ឬអស់លោកអ្នកមានលុយដុល្លាអាងរត់ទៅជ្រកដីគេ កុំភ្លេចថាខ្លួនអស់ទឹកដី គឺត្រូវអស់ជាតិនឹងត្រូវគេមើលងាយថា ខ្លួនជាពូជចោលម្សៀតការពារជាតិមិនកើតបណ្តោយអោយគេប្លន់បាន ។

ដោយកញ្ញា ម៉ៅ សុខណ្ណា

លិខិតមិត្តអ្នកអាន :

សង្គ្រាមនៅកម្ពុជាកាន់តែផ្ទុះធំ កាលណាគណបក្សកុំមុយនីស្តកាន់តែមានអំណាច

ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីដំណោះស្រាយជំលោះរួម ប្រជារាស្ត្រដែលស្នេហាសេរីភាព សន្តិភាពនៅលើពិភពលោក ពិសេសប្រជារាស្ត្រខ្មែរសង្ឃឹមថា សង្គ្រាមនឹងត្រូវបញ្ចប់ ហើយសន្តិភាពពិតប្រាកដមួយនឹងកើតមានឡើងនៅកម្ពុជា តាមរយៈរូបមន្តនៃកិច្ចព្រមព្រៀងនោះ ។ ប៉ុន្តែផ្ទុយទៅវិញក្តីស្រមៃរបស់ប្រជារាស្ត្រនៅលើពិភពលោក ពិសេសប្រជារាស្ត្រខ្មែរ ត្រូវរលាយខ្សុរដោយសារគំរោងការណ៍របស់គណបក្សកុំមុយនីស្តមួយដែលកំពុងកាន់អំណាចដែលបានមកពីការបង្កើតតំបន់អបគមន៍ ។

ការដែលអង្គការសហប្រជាជាតិបានសំរេចរៀបចំការបោះឆ្នោតមួយដែលហាក់ដូចជាបានប្រាសចាកពីមាត៌ានៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ការដែលខ្មែរក្រហមធ្វើពហិការមិនព្រមចូលរួមនៅក្នុងការបោះឆ្នោត ការដែលកិច្ចប្រជុំតុមូលដើម្បីស្វែងរកសន្តិភាពជូនប្រជារាស្ត្រខ្មែរដែលជាការខិតខំប្រឹងប្រែងដែលប្រកបទៅដោយព្រះបញ្ញាញាណរបស់ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូងត្រូវបរាជ័យក៏ដោយសារគំរោងការណ៍និងឧបាយកលដ៏ថោកទាប និងដែលមានការត្រៀមទុករបស់គណបក្សកុំមុយនីស្តមួយនេះដែរ ។ ហើយបើនិយាយឱ្យខ្លី សង្គ្រាមដែលកំពុងអូសបន្លាយហើយដែលមិនអាចកំនត់បាននូវទីបញ្ចប់នៅកម្ពុជាសព្វថ្ងៃនេះ ក្រៅពីគំរោងការណ៍របស់ខ្មែរក្រហមវាក៏គឺជាគំរោងការណ៍ដ៏សែនខ្មៅកខ្វក់របស់គណបក្សកុំមុយនីស្តដែលបានស្ម័គ្រចិត្តលក់ក្បាលធ្វើជាកញ្ជះយួនក្រោយឆ្នាំ ១៩៧៩ នេះឯង ។

លទ្ធផលនៃជ័យជំនះដែលស្ថិតក្នុងភាពមិនច្បាស់លាស់ និងអមតៈដែលបានមកពីសង្គ្រាមដណ្តើមអំណាចរវាងខ្មែរក្រហម និងរដ្ឋាភិបាលប្រជាធិបតេយ្យក្លែងក្លាយ ដែលអំណាចរបស់ប្រទេសតាមពិតស្ថិតក្នុងដៃគណបក្សកុំមុយនីស្តផ្តាច់ការនោះបាន និងកំពុងបំផ្លាញជីវិតប្រជាពលរដ្ឋ ពិសេសយុវជនខ្មែររាប់ម៉ឺននាក់ ។ តាមការពិតសង្គ្រាមនៅកម្ពុជា មិនមែនគ្មានលទ្ធភាពសំរាប់ដោះស្រាយ ឬមួយក៏ការដោះស្រាយបានឈានទៅដល់ភាពទាល់ច្រកផ្នែកសមត្ថភាព មធ្យោបាយ និងលទ្ធភាពនោះទេ ។ ពោលគឺកម្ពុជាមានមធ្យោបាយមានលទ្ធភាពគ្រប់គ្រាន់ដែលអាចបញ្ចប់សង្គ្រាមនេះបាន ។ ហើយអ្វីដែលជាលទ្ធភាពដ៏ល្អប្រពៃសំរាប់កម្ពុជាក្នុងការបញ្ចប់សង្គ្រាមរ៉ាំរ៉ៃនោះ គឺកម្ពុជាមានព្រះបិតាបង្រួបបង្រួមផ្សះផ្សាជាតិមួយព្រះអង្គ គឺព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ដែលទ្រង់គឺជាអ្នកអព្យាក្រិតឥតលំអៀង ដែលអាចធ្វើឱ្យកម្ពុជាឈានទៅដល់ការឯកភាពជាតិបាន ។

ប៉ុន្តែធាតុពិតនៃការលំបាកសំរាប់កម្ពុជាក្នុងការបញ្ចប់សង្គ្រាមរ៉ាំរ៉ៃនៃការដណ្តើមអំណាច នោះគឺបណ្តាលមកពីពួកគណបក្សកុំមុយនីស្តផ្តាច់ការដែលកំពុងកាន់អំណាចមួយនោះ មិនដង្ហែរតាមព្រះរាជតំរិះរបស់ព្រះបិតាបង្រួបបង្រួមជាតិ ។ ហេតុនេះមធ្យោបាយតែមួយគត់របស់ប្រជារាស្ត្រខ្មែរ ក្នុងការបញ្ចប់

សង្គ្រាមនៅកម្ពុជាដើម្បីស្វែងរកសន្តិភាព ការបង្រួបបង្រួមផ្សះផ្សាជាតិ ការគោរពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យពិតប្រាកដ គឺការរួបរួមគ្នារបស់ប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់ ក្រោកឡើងតស៊ូដើម្បីផ្ដួលរំលំគណបក្សកុម្មុយនីស្តមួយដែលកំពុងតែកាន់អំណាច និងបានប្រើអំណាចដ៏សែនឃោរឃៅសំរាប់ដឹកនាំជាតិសព្វថ្ងៃនេះ ។

វាជាការពិតណាស់ដែលប្រជារាស្ត្រខ្មែរស្នេហាសន្តិភាព គោរពសិទ្ធិមនុស្ស និងស្រលាញ់របបប្រជាធិបតេយ្យបាននាំគ្នាយល់ថា គណបក្សកុម្មុយនីស្តគឺជាប្រភពសង្គ្រាមនៅកម្ពុជា ។ ហើយវារិតតែត្រឹមត្រូវថែមទៀតដែលប្រជារាស្ត្រខ្មែរទាំងនោះយល់ថា ការចង់បានសន្តិភាពជូនជាតិមាតុភូមិរបស់ខ្លួនបេសកកម្មទីមួយ គឺបេសកកម្មកំទេចគណបក្សកុម្មុយនីស្តឱ្យផុតពូជ និងឱ្យផុតពីរង្វង់នៃអំណាចដឹកនាំជាតិ ។ ព្រោះថា កាលណាគណបក្សកុម្មុយនីស្តមួយនេះកាន់តែមានអំណាច នោះពន្លឺនៃសន្តិភាព ការបង្រួបបង្រួមផ្សះផ្សាជាតិ ការឯកភាពជាតិ កាន់តែនៅឆ្ងាយពីរង្វង់ដៃរបស់ប្រជារាស្ត្រ និងប្រទេសជាតិយើង ។

ការរំលឹកឡើងវិញនៅថ្ងៃ ៧ មករា វាគឺជាភស្តុតាងនៃការការប្រកាសសង្គ្រាមសារជាថ្មីឡើងវិញរបស់គណបក្សកុម្មុយនីស្តនៅលើទឹកដីកម្ពុជា ។ ពិតមែនហើយថាថ្ងៃ ៧ មករា វាជាថ្ងៃរំដោះប្រជារាស្ត្រខ្មែរឱ្យរួចផុតពីការកាប់សំលាប់របស់របបប៉ុលពត ប៉ុន្តែ វាក៏គឺជាថ្ងៃដែលបានអូសបន្លាយសង្គ្រាមនៅកម្ពុជាសំរយៈពេលជាង ១០ឆ្នាំ ដែរ ។ ម្យ៉ាងទៀតនយោបាយឆ្មុះឆ្មៀលអុជអាលបង្កើតឱ្យមានអំពើហិង្សាផ្នែកនយោបាយ ការតាមព្យាបាទបំផ្លិចបំផ្លាញអ្នកស្នេហាជាតិប្រជាធិបតេយ្យ វាក៏ជាភស្តុតាងនៃការបង្កើតឱ្យមានភាពបែកបាក់ និងឈានទៅសង្គ្រាមនៅពេលអនាគតដែរ ។ ហេតុនេះយើងសួរថា តើអ្វីៗទាំងនេះដែលបង្កឡើងដោយគណបក្សកុម្មុយនីស្តនេះ វាជាប្រភពធ្វើឱ្យកើតមានសន្តិភាពនៅកម្ពុជាឬ ?

មកដល់ពេលនេះហើយបើប្រជារាស្ត្រខ្មែរមិនទាន់រកឃើញប្រភពនៃសង្គ្រាមនៅកម្ពុជា ហើយបែរជានាំគ្នាទុកចិត្ត នាំគ្នាគាំទ្រ ឬនឹងនាំគ្នាបោះឆ្នោតឱ្យគណបក្សកុម្មុយនីស្តមួយនេះមានអំណាច នោះអ្វីដែលប្រជារាស្ត្រ និងជាតិខ្មែរទទួលបានជារង្វាន់ពីការផ្ដល់អំណាចនេះ គឺសង្គ្រាមរ៉ាំរ៉ៃ ភាពហិនហោច ការឈឺចាប់ខ្លោចផ្សា ការរំលោភសិទ្ធិមនុស្ស ភាពផ្ដាច់ការ ដែលគ្មានទីបញ្ចប់តែប៉ុណ្ណោះ___។

ដោយគរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ

ស្នាប់និស្សិតស្រែក :

បញ្ហាពុករលួយ និងអនាគតនៃកម្ពុជា

នយោបាយ "រាស្ត្រមានមុនរដ្ឋ" ដែលរាជរដ្ឋាភិបាលបានកំនត់ថា ជាទិសដៅចុងក្រោយរបស់ខ្លួនហាក់ដូចជាបានដើរនៅលើមាគ៌ានៃភាពបរាជ័យដោយចេតនា ។ ការខ្វះការយកចិត្តទុកដាក់ចំពោះយុទ្ធសាស្ត្រក្នុងការទប់ស្កាត់អំពើពុករលួយដែលមានភាពធ្ងន់ធ្ងរបំផុតនៅកម្ពុជា បានធ្វើឱ្យកម្ពុជាមិនអាចឈានផុតពីភាពដ៏មហាសែនក្រីក្ររបស់ខ្លួនបាន ។ ភាពមិនច្បាស់លាស់ក្នុងការកសាងអនាគតកម្ពុជាមួយដែលមានការរីកចំរើន

មានការគោរពសិទ្ធិមនុស្ស មានប្រជាធិបតេយ្យ មានសន្តិភាព នៅមិនទាន់ប្រាកដថា តើវាជាតួនាទី_ភារកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ឬមួយវាក៏ជាតួនាទី_ភារកិច្ចរបស់មនុស្សម្នាក់ ពីរនាក់ដែលជាប្រមុខដឹកនាំរាជរដ្ឋាភិបាល ។ហើយដោយសារតែបញ្ហានេះហើយដែលវិបត្តិនៃការកសាងជីវភាពសាធារណៈរបស់ប្រជារាស្ត្រនៅតែមិនអាចដោះស្រាយបាន ។

ពិតមែនថាកម្ពុជាដោះស្រាយបាននូវជំលោះរ៉ាំរ៉ៃតាមរយៈនយោបាយបង្រួបបង្រួមជាតិ ហើយដែលគណបក្សធំៗទាំងពីរបានប្តេជ្ញាថាមិនឱ្យមានការប្រេះស្រាំនឹងគ្នាក៏ដោយ ក៏មួយរយៈកាលកន្លងមកប្រជារាស្ត្រខ្មែរយើងមើលឃើញថា គណបក្សទាំងពីរមិនបានរួមគ្នាឱ្យអស់ពីចិត្តពីថ្លើមក្នុងការអភិវឌ្ឍន៍ប្រទេសទេ ។ ពោលគឺការអភិវឌ្ឍន៍ប្រទេសមានលាយឡំទៅដោយការប្រាថ្នាចង់បានប្រជាប្រិយភាពផ្នែកនយោបាយ ។ ដែលហេតុនេះបានជំរុញឱ្យមេគណបក្សនយោបាយទាំងពីរដែលជាប្រមុខនៃរាជរដ្ឋាភិបាល ធ្វើការអភិវឌ្ឍន៍ប្រទេសគ្មានមូលដ្ឋានប្រាកដប្រជា ។ ហើយការអភិវឌ្ឍន៍ប្រទេសដែលប្រមុខរដ្ឋាភិបាលទាំងពីរប្រឹងប្រែងធ្វើគឺមានចេតនាតែមួយគត់ គឺ "បង្ខំឱ្យរាស្ត្រចងចាំនូវឈ្មោះរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ " ។

ភាពចង់បានមុខមាត់ និងប្រជាប្រិយភាពផ្នែកនយោបាយចំពោះបុគ្គលផ្ទាល់ខ្លួន បានធ្វើឱ្យមេដឹកនាំនយោបាយ ខ្មែរធំៗគិតតែពីរឿងខំស្វែងរកលាភសក្ការៈលុយកាក់សំរាប់ផ្ទាល់ខ្លួនដើម្បីយកលុយទាំងនេះដើរទិញទឹកចិត្តប្រជារាស្ត្រ ពិសេសយុវជន និងនិស្សិតខ្មែរជាជាងស្វែងរកថវិកា ឬលាភសក្ការៈសំរាប់កសាងជាតិ ។ ហើយគឺដើម្បីបាននូវអ្វីៗទាំងអស់នេះឯង បានធ្វើឱ្យមេគណបក្សនយោបាយ និងដែលជាប្រមុខរដ្ឋាភិបាលផងនោះបានបណ្តែតបណ្តោយឱ្យមន្ត្រីរាជការកំពូលៗរបស់គណបក្សខ្លួនដែលកំពុងតែបំពេញភារកិច្ចប្រព្រឹត្តិនូវអំពើពុករលួយយ៉ាងអស់សាច់ជាទីបំផុតនៅស្ទើរគ្រប់ក្រសួង មន្ទីរ និងស្ថាប័ននានា ។

នយោបាយរាស្ត្រមានមុនរដ្ឋ ហាក់ដូចជាបានត្រឹមតែស្ថិតនៅក្នុងក្តីស្រមៃរបស់ប្រជារាស្ត្រប៉ុណ្ណោះ ។ ព្រោះរាស្ត្របានមើលឃើញថា វាជាការពិបាកបំផុតក្នុងការស្វែងរកនូវភាពមានបានរបស់ខ្លួន នៅក្នុងកាលៈទេសៈមួយដែលរដ្ឋបានប្រព្រឹត្តអំពើពុករលួយដែលមិនបានអើពើទាល់តែសោះក្នុងការរកយុទ្ធសាស្ត្រសំរាប់ដោះស្រាយ ។ បញ្ហារាស្ត្រមានមុនរដ្ឋ កាលណារាស្ត្រកាន់តែពិចារណាទៅៗ គឺកាន់តែមើលឃើញនូវភាពក្រីក្រ ឬភាពយ៉ាប់កាន់តែខ្ទេឡើង ។ តើអាចឱ្យរាស្ត្រទូទាំងប្រទេស សង្ឃឹមចំពោះរដ្ឋាភិបាលក្នុងការកសាងជីវភាពរបស់ខ្លួនឱ្យមានការរីកចំរើនដូចម្តេចបាន បើការអភិវឌ្ឍន៍ជាតិមានសន្ទុះមិនបានពាក់កណ្តាលនៃអំពើពុករលួយផងនោះ ? ហើយតើឱ្យរាស្ត្រសង្ឃឹមម្តេចបានបើលុយដែលយកទៅអភិវឌ្ឍន៍ជាតិនោះ មិនបានដល់ដៃរាស្ត្រ និងជាតិទាំងអស់ផងនោះ ?

ភាពដែលមិនអាចយល់បានរបស់ប្រជារាស្ត្រចំពោះឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍន៍ជាតិបានបង្កើននូវក្តីអស់សង្ឃឹមកាន់តែខ្ទេឡើង ។ ពោលគឺប្រជារាស្ត្រមិនដឹងថា តើឆន្ទៈបុគ្គល ឬមួយក៏ឆន្ទៈរបស់រាជរដ្ឋាភិបាលដែលមានបំណងប្រាថ្នាក្នុងការអភិវឌ្ឍន៍ជាតិនោះ ។ រាស្ត្រយើងកាន់តែមិនយល់នៅពេលដែលមើលឃើញវិសាលភាពនៃភាពក្រីក្ររបស់រាស្ត្រមានទំហំធំ តែអ្នកដឹកនាំបែរនាំគ្នាដណ្តើមយកភារកិច្ច

បំបាត់ភាពក្រីក្ររបស់ប្រជារាស្ត្រនេះទៅធ្វើតែពីរ_បីនាក់ទៅវិញ ។ ជាឧទាហរណ៍កន្លងមកប្រមុខរដ្ឋាភិបាលតែងតែប្រកាសក្តែងៗពីសមិទ្ធិផលដែលខ្លួនបានកសាង និងជួយដល់ប្រជារាស្ត្រមួយចំនួន ដូចជាសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ប្រលាយទឹក ស្រះ___ហើយសមិទ្ធិផលនេះសុទ្ធតែមានដាក់ឈ្មោះខ្លួនឯងទៀតផង ។

យើងឆ្ងល់ណាស់ថា បើគ្រប់សមិទ្ធិផលទាំងអស់នេះសុទ្ធតែកើតឡើងដោយសារតែសម្តេចនេះ ព្រះអង្គម្ចាស់ក្សត្រីយ៍នោះ ឯកឧត្តមនេះ លោកជំទាវនោះយ៉ាងដូច្នេះ ចុះសមិទ្ធិផលរបស់រដ្ឋាភិបាលនោះនៅឯណា ? តើអស់សម្តេច ម្ចាស់ក្សត្រីយ៍ ឯកឧត្តម លោកជំទាវបានលុយពីណាមកសង់នោះមហាសង់មិនចេះហិនហោចបែបនេះ ? តើថៅកែក្រុមហ៊ុនទាំងអស់ហ្នឹងគេបានលុយពីណាមកជួយសម្តេចមិនចេះខ្ជិលបែបនេះ ? គេរកស៊ីមិនព្រមបង់ពន្ធ ឬក៏បង់ពន្ធចូលរដ្ឋមិនគ្រប់តាមច្បាប់ទើងបានជាគេរកស៊ីចំនេញរហូតដល់ជួយសម្តេចរាប់លានដុល្លាហើយៗ មិនចេះអស់ដូចនេះ ? តើសម្តេចមានធ្លាប់ជួយសំរួលកិច្ចការរកស៊ីឱ្យពួកថៅកែអស់ហ្នឹងទេ ? បើទេមានតែពួកថៅកែក្រុមហ៊ុនអស់ហ្នឹងគាត់ឆ្កួត គាត់ភ្លើ គាត់ល្ងីល្ងើ ? បើមិនអញ្ចឹងទេមិនមែនទទេៗគាត់យកលុយមកឱ្យសម្តេចទេ ? ឬមួយគាត់ចង់ជួយជាតិ ? បើជួយជាតិម៉េចមិនឱ្យទៅរដ្ឋាភិបាល ? បើចង់ជួយជាតិម៉េចបានជួយជាតិតិចជាងជួយបុគ្គល ?

និយាយឱ្យចំទៅភាពមិនច្បាស់លាស់ក្នុងការអភិវឌ្ឍជាតិនេះហើយ ដែលបានធ្វើឱ្យការកែទំរង់សេដ្ឋកិច្ចដើម្បីឈានសំដៅទៅរកការកែទំរង់ជីវភាពរស់នៅរបស់ប្រជារាស្ត្រមិនបានទទួលនូវជោគជ័យ ។ ហើយផ្ទុយមកវិញបែរជាមានការរីកលូតលាស់ និងថែមទាំងបានចាក់គ្រឹះយ៉ាងរឹងមាំនូវអំពើពុករលួយទៅវិញ ។ ប្រជារាស្ត្រខ្មែរយល់ថា ការចង់កសាងប្រទេសឱ្យមានការរីកចំរើនជំហានជាមូលដ្ឋានដំបូងគឺការបង្កើតច្បាប់ប្រឆាំងនឹងអំពើពុករលួយ ឬមួយក៏យន្តការផ្សេងៗដែលអាចទប់ស្កាត់ រារាំងនិងប្រឆាំងនឹងអំពើពុករលួយបាន ។ តាមពិតទៅរដ្ឋាភិបាលណាក្តី ប្រសិនបើចង់ដឹកនាំប្រទេសក្នុងបំណងឱ្យរាស្ត្រមានមុនរដ្ឋ ហើយចាត់ទុកការអភិវឌ្ឍន៍ជាតិជាអាទិភាពចំបង តែមិនបានគិតគូរពីការប្រឆាំងនឹងអំពើពុករលួយថាជាបញ្ហាអាទិភាពទេនោះ វាជាការដឹកនាំដែលមានលក្ខណៈខុសឆ្គងដ៏ធ្ងន់ធ្ងរមួយ ។

គ្មានការដឹកនាំណាមួយដែលមានបំណងនាំប្រទេសឈានទៅរកការរីកចំរើនទទួលបាននូវជោគជ័យ នៅពេលដែលប្រទេសនោះ ពិសេសអ្នកដឹកនាំបាននាំគ្នាប្រព្រឹត្តិអំពើពុករលួយនោះទេ ។ កាលណាគេនិយាយអំពីការអភិវឌ្ឍន៍ឬចាប់ស្ទានពីល្បឿននៃការអភិវឌ្ឍន៍ ជាដំបូងគេគប្បីត្រូវសំលឹងមើលពីទំហំនៃអំពើពុករលួយ ។ ព្រោះគេមិនអាចអភិវឌ្ឍន៍ជាតិ ដោយឱ្យអំពើពុករលួយដើរទន្ទឹមគ្នាបានទេ។ ចុះចំណែកកម្ពុជាភាពពុករលួយស៊ីរូងផ្ទៃក្នុងស្ទើរទូទាំងប្រទេសទៅហើយតើរដ្ឋាភិបាលបានបង្កើតអ្វីដើម្បីទប់ស្កាត់នឹងអំពើនេះហើយឬនៅ ?

ករណីប្រទេសកម្ពុជារដ្ឋាភិបាលមិនត្រឹមតែមិនបានទប់ស្កាត់អំពើពុករលួយទេ តែមានពេលខ្លះថែមទាំងបានបណ្តោយឱ្យអំពើនេះមានសំទុះលឿនជាងធម្មតាទៀតផង ។ ការដែលរដ្ឋាភិបាលយល់ថា ភាពក្រីក្របានបង្កើតឱ្យមានភាពពុករលួយវាជាគំនិតយ៉ាងសកម្មមួយក្នុងការជួយជំរុញអំពើពុករលួយឱ្យមានកំលាំងកាន់តែខ្លាំងឡើង។ បានជាយើងហ៊ាននិយាយដូចនេះ ព្រោះយល់ថាកាលណាមានអំពើពុករលួយ គឺមានការស៊ីសំណូក

កាលណាមានការស៊ីសំណូកគឺមានការបាត់បង់ចរិការជាតិ កាលណាចរិការជាតិមានចំនួនតិច ឬក៏មិនមាន តើរដ្ឋមានលុយឯណា សំរាប់បើកឬតំឡើងប្រាក់បៀវត្សឱ្យមន្ត្រីរាជការបាន ? ម្ល៉ោះហើយភាពក្រីក្រចេះតែបន្តគ្មានទីបញ្ចប់ ។

ប្រជារាស្ត្រខ្មែរយើងយល់ថា ប្រសិនបើនយោបាយចុងក្រោយបំផុតរបស់រដ្ឋាភិបាលពិតជាមានបំណងធ្វើឱ្យរាស្ត្រមានមុនរដ្ឋមែន នោះរដ្ឋាភិបាលគួរតែប្រឹងប្រែងយ៉ាងណាបង្កើតច្បាប់ប្រឆាំងនឹងអំពើពុករលួយឱ្យបានឆាប់បំផុត ។ ប្រជារាស្ត្រយើងយល់ទៀតថា កាលណាគ្មានច្បាប់ប្រឆាំងនឹងអំពើពុករលួយ ឬក៏ការបង្កើតច្បាប់នេះមានភាពយឺតយ៉ាវ នោះកម្ពុជាកាន់តែប្រឈមមុខនឹងគ្រោះថ្នាក់គ្រប់បែបយ៉ាង ពិសេសវិស័យអភិវឌ្ឍន៍ជាតិ ។ ព្រោះថា អំពើពុករលួយវាបានធ្វើឱ្យមានការរំលោភសិទ្ធិមនុស្សកាន់តែខ្លាំងបានធ្វើឱ្យការអនុវត្តប្រជាធិបតេយ្យជួបប្រទះនូវវិបត្តិដ៏ធ្ងន់ធ្ងរ បានធ្វើឱ្យតុលាការបាត់បង់ឯករាជ្យភាព បាត់បង់នូវសេចក្តីថ្លៃថ្នូរ_កិត្តិយស និងជាប្រភពបង្កើតឱ្យមានអំពើអយុត្តិធម៌ទៅវិញ ។ ជាងនេះទៅទៀតអំពើពុករលួយបានធ្វើឱ្យមានអំពើហឹង្សា ចោរកម្ម ពេស្យាចារ និងបានធ្វើឱ្យកងកំលាំងប្រដាប់អាវុធក្លាយទៅជាជនគ្មានសីលធម៌ និងក្លាយទៅជាអ្នកការពារអំណាចឱ្យជនផ្តាច់ការទៅវិញ ។

ហើយពិសេសជាងនេះទៅទៀតបើគ្មានច្បាប់ប្រឆាំងនឹងអំពើពុករលួយទេ នោះចុងក្រោយអ្វីៗ ទាំងអស់នៅក្នុងប្រទេសកម្ពុជារាប់តាំងពីដី ព្រៃឈើ វាលស្រែ ប្រឡាយទឹក ស្ពាន ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ___នឹងក្លាយទៅជាកម្មសិទ្ធិផ្តាច់មុខរបស់ជនមានដាក់ឈ្មោះមនុស្សពីរ_បីនាក់នោះតែប៉ុណ្ណោះ ។

ដោយកញ្ញា ដារី

ស្តាប់គ្រូបង្រៀននិយាយ :

អនិច្ចារបស់គ្រូបង្រៀននៅស្រុកខ្មែរ

គ្រូបង្រៀន! ពាក្យនេះបើយើងស្តាប់ទៅគឺវាពោរពេញទៅដោយកិត្តិយសមួយដ៏ថ្លៃថ្នូរ និងឧត្តមគតិមួយដ៏ឧត្តុងឧត្តមដែលសង្គមមនុស្សឱ្យតំលៃ ។ គ្រូបង្រៀន គឺបានន័យថាមនុស្សដែលជាគំរូ ជាមនុស្សដែលមាននាទីអប់រំមនុស្សឱ្យឈានទៅរកមាគ៌ាល្អក្នុងជីវិត ។ លោកគ្រូ អ្នកគ្រូ គឺលោក_អ្នកដែលជាគំរូរបស់របស់នរជនផងទាំងពួង ជាមនុស្សដែលត្រូវសង្គមទុកចិត្តទាំងស្រុងក្នុងការកសាងមនុស្សថ្មីដែលជាគ្រឹះសង្គម ។ គ្រូបង្រៀនជាមនុស្សវិសេសថ្លៃថ្លាដែលត្រូវបានមាតា បិតានៃអនាគតពលរដ្ឋទុកចិត្តជាទីបំផុត ។ មាតា បិតា ប្រជាពលរដ្ឋសុខចិត្តយកបុត្រ ធីតាជាទីស្រឡាញ់របស់គាត់មកផ្ញើឱ្យគ្រូអប់រំប្រៀនប្រដៅ ឱ្យគ្រូបង្ហាញនូវគំរូល្អដល់កុមារបំភ្លឺនូវសេចក្តីល្ងិតល្ងង់របស់កុមារ ។ គ្រូជាអ្នកផ្តល់ឱវាទ ចំណេះដឹង ជាអ្នកអប់រំទាំងវិជ្ជាសម្បត្តិ ទាំងចរិយាសម្បត្តិដល់កុមារ គឺថាគ្រូមានតួនាទីយ៉ាងសំខាន់បំផុតក្នុងការហាត់ពត់លត់ដំកុមារឱ្យក្លាយជាទំពាំងស្នងឬស្សីដ៏ល្អ

ជាអនាគតនៃប្រទេសជាតិមួយដ៏រឹងមាំ សំរាប់ជាគ្រឹះកសាង និងជំរុញសង្គមជាតិឱ្យរីកចំរើនរុងរឿង ។ ព្រោះថាមន្ត្រីរាជការ គ្រប់មុខតំណែង ស្ថាប័ន ក្រសួងដែលជាប្រព័ន្ធចលនាជាតិសុទ្ធតែធ្លាប់ឆ្លងកាត់សាលារៀន ធ្លាប់ឆ្លងកាត់ការអប់រំរបស់គ្រូបង្រៀន ។ ដូច្នេះបើយើងពិចារណាឱ្យល្អិតល្អន់នឹងឃើញថា គ្រូបង្រៀននេះជាបុគ្គលដែលសំខាន់បំផុតក្នុងសង្គម ជាអាទិភាពទី ១ដែលត្រូវតែនាំគ្នាគិតគូរឱ្យបានខ្លាំងក្លាជាទីបំផុត ។

តាមទ្រឹស្តីគរុកោសល្យបានបញ្ជាក់យ៉ាងច្បាស់ថា គ្រូបង្រៀនជាវិស្វករនៃព្រលឹង ។ វិស្វករបែបនេះមាននាទីសំខាន់ និងលំបាកជាទីបំផុត ។ ព្រោះថាបើវិស្វករសាងសង់ផ្ទះវិញបើខុសប្លង់បន្តិចបន្តួច អាចកែច្នៃបានចុះ បើវិស្វករសាងសង់ព្រលឹងមនុស្សវិញគឺមិនអាចកែច្នៃបានឡើយ ។ បើអប់រំត្រូវក្លាយជាពលរដ្ឋល្អនោះវាចំរើនជាតិ តែបើអប់រំមិនល្អតើជាតិយើងវាយ៉ាងម៉េចទៅវិញ ? ដូច្នេះគ្រូត្រូវតែប្រុងប្រៀប រៀបចំ សំអិតសំអាង លត់ដំពត់តំរង់ចិន្តាភាពព្រមទាំងច្នៃចិត្ត មនោរម្មណ៍ និងទស្សនៈរបស់សិស្ស និស្សិតឱ្យប្រកាន់យកមាគ៌ាមួយដែលល្អ ។ គ្រូជាអ្នកអប់រំសិស្ស សិស្សតែងប្រតិបត្តិតាមស្ទើរតែទាំងអស់តាមដំបូន្មានគ្រូ ត្រាប់តាមអត្តចរិតគ្រូ។ ម្យ៉ាងទៀតគេបានប្រៀបធៀបគ្រូបង្រៀនទៅនឹងវិចិត្រករម្នាក់ ឯកុមារប្រៀបបានក្រដាស ឬក្រណាត់សស្អាតដែលវិចិត្រករត្រូវគូរតាមចំណង់ ឬគំនិតរបស់ខ្លួន ។ បើគ្រូចង់បង្ហឹកក្មេងឱ្យអាក្រក់ ល្អ ស ខ្មៅគឺមានលទ្ធភាពច្រើនជាទីបំផុត ។ ដូច្នេះហើយបានជាប្រទេសជឿនលឿនលើពិភពលោកគេឱ្យតំលៃទៅលើគ្រូបង្រៀននេះណាស់ ។

មកដល់ត្រឹមនេះយើងក្រលេកមើលវិស័យអប់រំក្នុងគ្រាអតីតកាលនៃកម្ពុជា នារបបសង្គមរាស្ត្រនិយមវិញ ។ គ្រូបង្រៀននៅសម័យសង្គមរាស្ត្រនិយមត្រូវបានសង្គមកម្ពុជាឱ្យតំលៃជាអតិបរមា។ ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូងសម្តេចឪទ្រង់ឈ្វេងយល់ក្រុបដោយលក្ខណៈសុភវិនិច្ឆ័យជាទីបំផុតចំពោះវិស័យអប់រំសិក្សាធិការនេះ ។ គ្រូបង្រៀនត្រូវបានលើកតំកើងជាបុគ្គលដែលមានលក្ខណៈគំរូ និងមានកិត្តិយសសក្តិសមពិតៗ មានមុខមាត់ជាមន្ត្រីរាជការនៅក្នុងចំណោមមហាជននៃសង្គមកម្ពុជា ។ ទោះគ្រូបង្រៀនមិនអាចក្លាយទៅជាអ្នកមានសម្បត្តិសំបូរហូរហៀរដូចជាពាណិជ្ជករក្តី ក៏គ្រូមិនត្រូវបានជនផងទាំងពួងមើលងាយមើលថោកក្នុងផ្នែកជីវភាព ។ គ្រូរស់នៅក្នុងជីវភាពមួយគ្រប់គ្រាន់ថ្លៃថ្នូរ និងកិត្តិយស ។ គ្រូមិនខ្វាយខ្វល់ពីជីវភាពប្រចាំថ្ងៃ ។ គ្រូមិនភ័យព្រួយពីការផ្លាស់ប្តូរតំបន់បង្រៀនទៅទីជនបទដាច់ស្រយាល។ ព្រោះថាក្រៅពីបៀវត្សប្រចាំខែគ្រប់គ្រាន់ គ្រូមានរបបផ្ទះ (ពេលផ្លាស់ទៅកាន់តំបន់ឆ្ងាយៗ) មានប្រាក់រ៉ាប់រងធានាសុខភាព និងសោហ៊ុយធ្វើដំណើរ។ល។ តើមានអ្វីត្រូវភ័យព្រួយទៀត ? ប្រាក់ចាយគ្រប់គ្រាន់ ផ្ទះមាននៅ គ្រួសាររស់នៅក្នុងសភាពសមរម្យថ្លៃថ្នូរដូចគេឯងទៅហើយ ។ តាំងចិត្តជាអ្នកបណ្តុះបណ្តាលអប់រំមនុស្សទៅហើយគ្រូពិតជាគ្មានកង្វល់ទៀតទេ ។ ភារកិច្ចមានតែម្យ៉ាងគឺខិតខំសិក្សាស្រាវជ្រាវរាវរកវិធីល្អៗ សំរាប់យកទៅបង្រៀនកុលបុត្រ កុលធីតាខ្មែរឱ្យក្លាយទៅជាមនុស្សល្អ និងពោរពេញទៅដោយសមត្ថភាព ប៉ុណ្ណោះ ។ យ៉ាងនេះហើយទើបសម័យនោះកម្ពុជាអាចរីកចំរើនបានលើគ្រប់វិស័យ ។

មកដល់សម័យសង្គ្រាម មុខរបរគ្រូបង្រៀនត្រូវបានគេបំភ្លេចចោលបន្តិចម្តងៗ ។ បណ្តាអ្នកដឹកនាំខ្មែរបានធ្វើព្រងើយកន្តើយ និងមើលស្រាលចំពោះវិស័យអប់រំនេះជាខ្លាំង ។ សម័យសង្គ្រាមជាសម័យទមិឡ ជាសម័យមនុស្សព្រៃ ជាសម័យដែលមនុស្សគ្មានការអប់រំកាន់អំណាច ។ គ្រូបង្រៀនត្រូវគេតំរូវឱ្យជាប់កាតព្វកិច្ចចេញច្បាំង គ្រូបង្រៀនត្រូវគេយទៅវៃចោល គ្រូបង្រៀនត្រូវគេមើលងាយមើលថោក សាលារៀនត្រូវគេកំទេច ។ល។

សម័យសង្គ្រាមតំលៃគ្រូបង្រៀន និងវិស័យអប់រំសិក្សាធិការទាំងមូលមិនត្រូវបានគេយកចិត្តទុកដាក់ឡើយ ។ ហើយកាន់តែមិនយកចិត្តទុកដាក់ និងមើលងាយថែមទៀតនាប៉ុន្មានឆ្នាំចុងក្រោយនេះ ។ គ្រូបង្រៀនដ៏ច្រើនលើសលប់នៅក្នុងវិស័យអប់រំជាតិបានក្លាយទៅជាមនុស្សដែលមានតំលៃទាបបំផុតនៅក្នុងសង្គមកម្ពុជា ពិសេសតាមទីជនបទដាច់ស្រយាល ។ គ្រូបង្រៀនបានក្លាយជាសំណល់ចុងក្រោយនៃការជ្រើសរើសរបស់សង្គមខ្មែរ ទោះក្នុងការប្រកបការងារក្តី ក្នុងការកសាងសង្គមគ្រួសារក្តី ។ តំលៃនៃមន្ត្រីរាជការគ្រូបង្រៀនអន់ជាងអ្នកលក់សាច់ជ្រូកតាមផ្សារទៅទៀត ។ តើបញ្ហានេះវាកើតឡើងដោយសារអ្វី ?

រាជរដ្ឋាភិបាលហាក់ពុំបានអើពើ និងគិតគូរពីបញ្ហាគ្រូបង្រៀនឡើយ ពិសេសទាក់ទងរឿងជីវភាព ។ ប្រាក់ខែគ្រូបង្រៀនមានតិចតួចបំផុត ហើយវាមហាយ៉ាប់ថែមទៀតនៅតាមទីជនបទ ព្រោះថាប្រាក់ខែត្រូវបើកក្នុងរវាងថ្ងៃទី ១០_១៥ នៃខែថ្មី ឬក៏បើកួបក្នុងពីរ ឬបីខែតែម្តង ។ ចំនួនបៀវត្សសរុបទាំងកូន ទាំងប្រពន្ធទិញគុយទាវចិនបានប្រហែលតែ ៣០ចានប៉ុណ្ណឹង ។ ដូច្នោះបានន័យថាផលនៃការបង្រៀនមួយថ្ងៃ ដូរបានកំរៃជាគុយទាវមួយចាន ។ តើមានប្រាក់ណាសំរាប់ទិញសំលៀកបំពាក់ សំភារៈប្រើប្រាស់ខ្លួនឯង កូន ប្រពន្ធ_ប្តី ? តើមានប្រាក់ប៉ុន្មានសំរាប់ទិញថ្នាំព្យាបាលពេលធ្លាក់ខ្លួនឈឺ ? តើមានប្រាក់ឯណាសំរាប់ទិញត្រី សាច់ អង្ករច្រកឆ្នាំងចំអែតក្រពះ? នេះមិននិយាយដល់ការចំណាយកំប៉ុកកំប៉ុកផ្សេងៗ និងប្រាក់សំរាប់កូនរៀងផង ។ គ្រូខ្លះបង្រៀនតាំងពីជិះកង់ទៅបង្រៀនរហូតដល់ដើរទៅបង្រៀន ឬបង្រៀនតាំង ពីហូបបាយ រហូតដល់ហូបបបរ___។ល។ តើឱ្យគ្រូបង្រៀនរស់តាមរបៀបម៉េច ? មានតែគ្រូពុករលួយក្បត់វិជ្ជាជីវៈទៅច្របាច់កសិស្ស បង្ខំសិស្សឱ្យរៀនគួរ បង្ខំសិស្សឱ្យទិញស្លាបគ្រាប់ក្នុងថ្នាក់ លក់មេរៀន ហើយទីបំផុតគឺត្រូវស៊ីសំណូក ។ បើតាមទីជនបទវិញគ្រូត្រូវតែឆ្លៀតដាំបន្លែ ធ្វើស្រែ ធាក់រ៉ឺម៉ក រត់ម៉ូតូឌុប ឬជួញដូរកំប៉ុកកំប៉ុកតាមតែអាចឆ្លៀតទៅបាន ។ តើតំលៃនៃការបង្រៀនរបស់គ្រូវាយ៉ាងម៉េចទៅវិញ ? ហើយកំរិតនៃការសិក្សារបស់សិស្សវាយ៉ាងម៉េចទៅវិញ? គ្រូរវល់រកស៊ីចិញ្ចឹមជីវិតគ្មានពេលបង្រៀន គ្មានពេលស្រាវជ្រាវឯកសារបង្រៀន ឯសិស្សរវល់តែជួយធ្វើស្រែគ្រូ រវល់តែច្រូតស្មៅឱ្យគោក្របីរបស់គ្រូ ។ល។ ទាំងនេះវាជាគ្រោះថ្នាក់ដ៏ធំបំផុតចំពោះអនាគតនៃសង្គមកម្ពុជា ។

ប៉ុន្តែ សួរថាបើមិនឱ្យគ្រូធ្វើយ៉ាងនេះ ក្បត់វិជ្ជាជីវៈខ្លួន ផ្ទុយច្បាប់គរុកោសល្យ តើឱ្យគ្រូរស់យ៉ាងម៉េច ?

ក្នុងនាមជាគ្រូបង្រៀនម្នាក់ ខ្ញុំបានមើលឃើញថារដ្ឋាភិបាលសព្វថ្ងៃបានមើលងាយ វាយបន្ថោកតំលៃគ្រូបង្រៀនជាទីបំផុត ។ ពួកគេមិនបានគិតអើពើពីជីវភាពគ្រូបង្រៀនដល់តិចតួចឡើយ។ ពួកគេគិតតែពីជីវភាពរបស់ពួកខ្លួនមួយក្តាប់តូចខាងលើនោះឯង ។ ក្រៅពីបៀវត្សដ៏ខ្ពស់ហួសពពកជាច្រើនកន្លែងពួកគេនៅមានបន្ថែមរបបពិសេសយ៉ាងច្រើនទៀត ទាំងនេះមិនទាន់និយាយដល់ការធ្វើស្រែលើខ្នងរាស្ត្រ ស៊ីសំណូកសូកបាន់រាប់មិនឈ្នះដែលស្អុយរំលំពេញស្រុកខ្មែរផង ។ ល្មមៗ បានហើយប្រយ័ត្នងាប់តែហោងដូចតាជូជក់ ស្រុកខ្មែរមិនមែននំដែលអស់លោកដណ្តើមគ្នាមកធ្វើធំហើយហែកចែកគ្នាអង្កៀមនោះទេ ! ។ កុំចេះតែស្រែកថាអ្វីៗ ដង្ហែរតាមព្រះរាជមាតា ព្រះមហាក្សត្រ អ្វីៗ ដើរតាមសម័យសង្គមរាស្ត្រនិយមនោះ ។ បើស៊ីក៏ស៊ីទៅព្រោះក្រពះអស់លោកវាធំ តែសូមកុំស៊ីទាំងធ្មេចភ្នែកលើគំនរទុក្ខសោក និងគ្រោះទុរ្ភិក្សដែលកំពុងសង្កត់កប្រជារាស្ត្រនោះ ។

ដោយ ពិសេស_គតិយុត្តិ

និស្សិតយល់ឃើញ

- យើងយល់ឃើញថា សព្វថ្ងៃនេះអំពើពុករលួយហាក់បីដូចជាកំពុងចានរាយលុកយ៉ាងខ្លាំងក្លានៅកម្ពុជា។ ហើយឥទ្ធិពលនៃអំពើនេះ វាបានធ្វើឱ្យដំនើរការរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេសមានសភាពយឺតយ៉ាវបំផុត ធ្វើឱ្យដំនើរការអនុវត្តលទ្ធិប្រជាធិបតេយ្យមានវិបត្តិយ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យកងកំលាំងប្រដាប់អាវុធគ្មានសីលធម៌ និងក្លាយទៅជាកំលាំងសំរាប់ការពារឱ្យអំណាចផ្តាច់ការ ពិសេសធ្វើឱ្យតុលាការបាត់បង់កិត្តិយស និងសេចក្តីថ្លៃថ្នូរក្នុងវិជ្ជាជីវៈមួយដែលសំរាប់រកយុត្តិធម៌ជូនសង្គមជាតិ ។

- យើងយល់ថា ប្រសិនបើច្បាប់ប្រឆាំងនឹងអំពើពុករលួយ ឬច្បាប់ប្រកាសទ្រព្យសម្បត្តិ មានសភាពយឺតយ៉ាវនោះប្រទេសកម្ពុជាយើង នឹងទទួលរងនូវគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរក្នុងដំនើរការកសាងប្រទេសគ្រប់ផ្នែក គ្រប់វិស័យ ។ ពិសេសបើគ្មានច្បាប់នេះទេ នោះអ្វីៗទាំងអស់ដែលមាននៅកម្ពុជា រាប់ចាប់តាំងពីសាលារៀន មន្ទីរពេទ្យ ដីធ្លី ព្រៃឈើ ស្រែចំការ ប្រលាយទឹក ទំនប់ទឹក ផ្លូវថ្នល់ សួនច្បារ___នឹងក្លាយទៅកម្មសិទ្ធិរបស់អ្នកលោភអំណាច២_៣ នាក់ នោះតែប៉ុណ្ណោះ ។

- យើងយល់ទៀតថា បើគ្មានច្បាប់ខាងលើនេះទេ នោះការបោះឆ្នោតមេឃុំ ការបោះឆ្នោតនាឆ្នាំ ៩៨ និងការបោះឆ្នោតនានានៅកម្ពុជានាពេលអនាគត នឹងប្រាកដជាគ្មានភាពសេរី និងយុត្តិធម៌ស្របតាមឆន្ទៈរបស់ប្រជារាស្ត្រខ្មែរឡើយ ។ ព្រោះថាមិនទាន់ដល់ពេលឃោសនាបោះឆ្នោតផង មានគណបក្សមួយដែលកំពុងកាន់អំណាចនៅក្នុងរដ្ឋាភិបាលសព្វថ្ងៃនេះ ដើរទិញសន្លឹកឆ្នោតពីប្រជាពលរដ្ឋ ពិសេសនិស្សិតនៅតាមមហាវិទ្យាល័យមួយចំនួន ក្នុងតំលៃ ៣០០០០ រៀល តាមរយៈការធ្វើប័ណ្ណចូលជាសមាជិកគណបក្សរបស់គេ ។

- បញ្ហាការងារយុត្តិធម៌យើងយល់ថាកាលណាតុលាការគ្មានឯករាជ្យភាព ឬក៏មានឯករាជ្យក្នុងភាពអវិជ្ជមាន នោះតុលាការនោះឯងគឺជាប្រភពនាំប្រទេសឈានទៅរកភាពសំបូរបែបខាងសង្គ្រាម ការរំលោភសិទ្ធិមនុស្ស អំពើពុករលួយ ចោរកម្ម ភាពហឹង្សា___ជាពិសេសជាប្រភពធ្វើឱ្យសង្គមគ្មានការគោរពច្បាប់ទៅវិញទេ។ចុះចំណែកឯតុលាការកម្ពុជាវិញមានឯករាជ្យហើយឬនៅតើសក្តិសមទទួលឋានៈជាអ្វី? តើដល់ពេលណាទើបព្រមទទួលយកនូវភាពឯករាជ្យក្នុងភាពវិជ្ជមាន និងសេចក្តីថ្លៃថ្នូរ ដែលពោរពេញទៅដោយកិត្តិយសដូចតុលាការប្រទេសដទៃទៀត?

- ជាចុងក្រោយយើងយល់ថា ការចង់បញ្ចប់សង្គ្រាមនៅកម្ពុជា បើអ្នកដឹកនាំខ្មែរលោភអំណាចបច្ចុប្បន្នចង់បញ្ចប់វាជាករណីមួយងាយស្រួលបំផុត ។ ហើយអ្វីដែលងាយស្រួលក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជានោះ គឺបើរដ្ឋាភិបាលគ្មានសមត្ថភាពបំបាត់ខ្មែរក្រហមឱ្យអស់ទេ នោះមធ្យោបាយមានតែមួយគត់ គឺប្រជារាស្ត្រត្រូវធ្វើយ៉ាងណាសហ_ ការគ្នាផ្តួលរំលំគណបក្សកុំមុយនីស្ត និងសម្ព័ន្ធភាពដែលកំពុងនាំគ្នាលោភអំណាចមួយនោះ ឱ្យវាដួលទៅនោះសន្តិ_ ភាពប្រាកដជាមាននៅកម្ពុជា ។ ដើម្បីរកសន្តិភាពជូនប្រទេសកម្ពុជា រវាងខ្មែរក្រហម និងគណបក្សកុំមុយនីស្ត បើយើងកំចាត់អាមួយនៅក្នុងព្រៃមិនបាន គឺយើងនាំគ្នាងាកមកកំចាត់អានៅក្នុងស្រុកវិញនេះអ្វីៗដែលជាសេចក្តីប៉ងប្រាថ្នារបស់រាស្ត្រ នឹងបានមកដល់ដៃប្រជារាស្ត្រជាប្រាកដ ។

អ_ប_វ

អត្ថបទស្រាវជ្រាវៈ

អំពីចំនួនប្រជាជនក្នុងពិភពលោក

នៅពាក់កណ្តាលឆ្នាំ ១៩៩៤ ពិភពលោកទាំងមូលមានប្រជាជនសរុបទាំងអស់ចំនួន ៥,៦៦ កោដិនាក់ ហើយតួលេខនេះនឹងកើនឡើងដល់ ៦កោដិនាក់នៅឆ្នាំ ១៩៩៨។ ទោះបីថាមានអត្រាកំណើនប្រជាជនជាទូទៅនៅក្នុងពិភពលោកត្រូវធ្លាក់ចុះ ហើយកំណើនប្រជាជនប្រចាំឆ្នាំក្នុងពេលកន្លងមកនេះមាន ៩៤លាននាក់ក្នុងមួយឆ្នាំយ៉ាងណាក៏ដោយ ក៏វានៅតែបង្ហាញថា វាជាអត្រាកំណើនខ្ពស់បំផុតមួយនៅក្នុងប្រវត្តិសាស្ត្រមនុស្សលោកយើងនេះ ។ បន្ទាប់ពីឆ្នាំ ១៩៩៧ ទៅអត្រាកំណើនមនុស្សនឹងត្រូវបានចាប់ផ្តើមធ្លាក់ចុះមកវិញ ហើយនៅឆ្នាំ ២០២០ខាងមុខនេះ អត្រាកំណើនប្រជាជនប្រចាំឆ្នាំអាចមានត្រឹមតែ ៨៧លាននាក់ក្នុងមួយឆ្នាំតែប៉ុណ្ណោះ ។

អត្រាកំណើនប្រជាជន ពិភពលោកនេះភាគច្រើនមាននៅក្នុងទ្វីបអាស៊ី ទ្វីបអាហ្វ្រិក និងអាមេរិកឡាទីន ហើយជាងពាក់កណ្តាលនៃ កំណើននេះ គឺមាននៅអាស៊ីខាងត្បូង និងនៅអាហ្វ្រិក និងនៅតាមបណ្តាប្រទេសដែលក្រីក្របំផុតជាច្រើនទៀត នៅក្នុងពិភពលោក ។ បើតាមរបាយការណ៍ចុងក្រោយបង្អស់របស់អង្គការសហប្រជាជាតិបានបង្ហាញពីការប៉ាន់ ប្រមាណរបស់ខ្លួនទៅលើចំនួនប្រជាជនពិភពលោកថាមាន ៨,៥កោដិនាក់ នៅឆ្នាំ ២០២៥ ហើយចំនួន ១០កោដិ នាក់នៅឆ្នាំ ២០៥០ ។ ការប៉ាន់ប្រមាណរយៈពេលវែងនេះដោយគិតទៅលើការបន្តការធ្លាក់ចុះនៃអត្រាកំណើន ប្រសិនបើគ្មានការធ្លាក់ចុះនេះទេ ចំនួនមនុស្សនឹងកើនច្រើនជាងនេះឆ្ងាយណាស់ សំរាប់ពាក់កណ្តាលដំបូងនៃសតវត្ស បន្ទាប់ទៅនេះ អាចមានរហូតដល់ទៅ ១២,៥កោដិនាក់នៅឆ្នាំ ២០៥០ ។

ភាពខុសគ្នានៃការប៉ាន់ស្មានរវាង អត្រាខ្ពស់ និងអត្រាមធ្យមនេះគឺ ២,៥កោដិនាក់ ដោយតួលេខនេះវាស្មើទៅនឹងតួលេខនៅឆ្នាំ ១៩៥០ ដូច្នោះដែរ ។ ប៉ុន្តែអត្រាចំនួនប្រជាជនក៏អាចមានទាបដែរដោយមានការប៉ាន់ប្រមាណទាបដែលគេសង្កេតឃើញ មានការធ្លាក់ចុះយ៉ាងលឿននៃអត្រាកំណើនប្រជាជន ហើយជាលទ្ធផលចំនួនប្រជាជនអាចមានត្រឹមតែ ៧,៨កោដិ នាក់នៅឆ្នាំ ២០៥០ ។ ភាពខុសគ្នានៃការប៉ាន់ស្មានរវាងអត្រាមធ្យម និងអត្រាទាបនេះគឺ ២,២កោដិនាក់ សំរាប់ឆ្នាំ ២០៥០ ។

អត្រាកំណើនប្រជាជនប្រចាំឆ្នាំនៃទ្វីបអាហ្វ្រិកមានរហូតដល់ទៅ ២,៩ភាគរយ វាបង្ហាញថាជាតំបន់នៃអត្រាកំណើនលឿនជាងគេនៅក្នុងពិភពលោក ។ ទ្វីបអាស៊ី និងទ្វីបអាមេរិកឡាទីនមានអត្រាកំណើននេះស្មើ ១,៨ ភាគរយក្នុងមួយឆ្នាំ អាមេរិកខាងជើងមានអត្រា ១,១ភាគរយក្នុងមួយឆ្នាំ អតីតសហភាពសូវៀតមានអត្រា០,៥ ភាគរយ ហើយនៅអឺរ៉ុបមានអត្រាទាបជាងគេបំផុតគឺ ០,៣ភាគរយ ។ កំរិតនៃអត្រាកំណើននេះបង្ហាញពីតួលេខនៃការបែងចែកចំនួនប្រជាជននៅលើពិភពលោកកាលពីឆ្នាំ ១៩៥០ ដែលនៅពេលនោះទ្វីបអាស៊ីមានប្រជាជនប្រមាណ ៥៥ ភាគរយនៃប្រជាជនទាំងអស់ ទ្វីបអឺរ៉ុបមានប្រជាជនប្រមាណ ១៦ ភាគរយ អាហ្វ្រិកមាន ៩ ភាគរយ ។ ដល់ ឆ្នាំ ១៩៩៣ ទ្វីបអាស៊ីមានប្រជាជនកើនឡើងដល់ទៅ ៦០ភាគរយនៃប្រជាជនពិភពលោក ដែលក្នុងពេលនោះទ្វីបអាហ្វ្រិកបានមកជំនួសទ្វីបអឺរ៉ុបវិញ គឺនៅជួរទី ២ បន្ទាប់ពីទ្វីបអាស៊ី ។

ដំណើរការនេះ ហាក់ដូចជាកំពុងតែបន្តរហូតដល់ឆ្នាំ ២០១៥ ដែលនៅពេលនោះទ្វីបអាហ្វ្រិកត្រូវគេរំពឹងថានឹងមានប្រជាជនសរុប ចំនួន ១៩ភាគរយវិញ ហើយទ្វីបអឺរ៉ុបនឹងក្លាយមកនៅត្រឹមតែ ៦ភាគរយតែប៉ុណ្ណោះ ។ ការផ្លាស់ប្តូរនេះវាទាក់ ទងយ៉ាងសំខាន់ទៅនឹងនយោបាយជាសាធារណៈនៅក្នុងគ្រប់ប្រទេសទាំងអស់ ដោយប្រទេសទាំងអស់មានការ ផ្លាស់ប្តូរលើតុល្យភាពនៃការពឹងពាក់គ្នាទៅវិញទៅមក ការផ្លាស់ប្តូរនៃសេចក្តីត្រូវការលើបទដ្ឋានគំរូសំរាប់ការស្នាក់នៅ ការអប់រំ សុខុមាលភាព និងបញ្ហាសេវាកម្មផ្សេងទៀត ។ ក្នុងករណីពិសេសខ្លះ វានឹងមានឥទ្ធិពលទៅលើ បញ្ហាការងារ និងបញ្ហកំលាំងពលកម្ម ដែលគេបានរំពឹងថានិងមានកំលាំងពលករចំនួន ១,៣កោដិនាក់ដែលត្រូវ បន្ថែមទៅលើកំលាំងដែលមានស្រាប់នៅក្នុងទ្វីបអាស៊ី ទ្វីបអាហ្វ្រិក និងទ្វីបអាមេរិកឡាទីន នៅក្នុងរវាងឆ្នាំ ១៩៩៥ ទៅឆ្នាំ២០២០ ហើយបន្ទាប់មកទៀតសេចក្តីត្រូវការសំរាប់ការងារថ្មីនឹងត្រូវធ្លាក់ចុះ ។ ម្យ៉ាងវិញទៀត សំរាប់ប្រទេសដែលមានការអភិវឌ្ឍន៍ពេលបច្ចុប្បន្ននេះ សមាមាត្រនៃប្រជាជនដែលមានអាយុពី ៦៥ និងលើស ពីនេះ នឹងត្រូវកើនឡើងថេរចាប់ពី ១២.៧ ភាគរយ ទៅ ១៨.៤ ភាគរយ នៅឆ្នាំ ២០២៥ ។

ទោះបីជាយ៉ាងណាក៏ដោយ ការធ្លាក់ចុះនៃអត្រាកំណើនប្រជាជនសំរាប់ផ្នែកខ្លះនៃសតវត្សខាងមុខនេះ វាអាចកាត់បន្ថយនូវសម្ពាធសង្គមជាច្រើននៅក្នុងតំបន់ទាំងនោះ ដោយវាអាចនឹងផ្តល់នូវពេលវេលា គ្រប់គ្រាន់សំរាប់ស្វែងរកនូវដំណោះស្រាយផ្សេងៗ ។ សំរាប់ប្រទេសជាច្រើនដែលបានគិតគូរទៅដល់ភាពខុសប្លែក ធ្លាក្នុងរយៈពេលមួយទសវត្សមកនេះនៃការធ្វើអោយអត្រាកំណើនប្រជាជននៅទាប គឺវាបានជះឥទ្ធិពលទៅដល់គុណភាពនៃជីវិត ជាឧទាហរណ៍ក្នុងការផ្តល់នូវការសិក្សាអប់រំ គុណភាពនៃការថែរក្សាសុខុមាលភាព និងឱកាសនៃការផ្តល់ការងារធ្វើ ។ល។

ខាងក្រោមនេះគឺជាតារាងប្រជាជននៃប្រទេសនីមួយៗក្នុងពិភពលោក :

ឈ្មោះប្រទេសនានា	ប្រជាជនគិតជាលាន ឆ្នាំ៩៤	ប្រជាជនឆ្នាំ ២០២៥	កំនើនមធ្យម ៩០_៩៥	អត្រាកំនើតភាគ ‰ ៩០_៩៥	អត្រាមរណៈ ភាគ‰៩០_៩៥	ជីវិតជាមធ្យម
ប្រជាជនសរុប	៥,៦៦	៨ ៤៧២,៤	១,៧	២៦	៩	៦៥
សំរាប់តំបន់អភិវឌ្ឍន៍ខ្ពស់	១ ២៣៧,៦	១ ៤០៣,៣	០,៥	១៤	១០	៧៥
សំរាប់តំបន់អភិវឌ្ឍន៍ទាប	៤ ៤២៧,៩	៧ ០៦៩,២	២,០	២៩	៩	៦២
A- ទ្វីបអាហ្វ្រិក	៦៨១,៧	១ ៥៨២,៥	២,៩	៤៣	១៤	៥៣
a-អាហ្វ្រិកខាងកើត	២០៧,៤	៥១៦,០	៣,១	៤៨	១៦	៤៩
_ ប៊ូរុនឌី	៦,០	១៣,៤	២,៩	៤៦	១៧	៤៨
_ អេត្យូពី	៥១,៣	១៣០,៧	៣,១	៤៩	១៨	៤៧
_ កេនយ៉ា	២៦,១	៦៣,៨	៣,៤	៤៤	១០	៥៩

_ ម៉ាដាហ្គាស្កា	១៣.៣	៣៣.៧	៣.៣	៤៥	១៣	៥៥
_ ម៉ាឡាវី	១០.៧	២៤.៩	៣.៣	៥៤	២១	៤៤
_ ម៉ូរីទូស	១.១	១.៤	១.០	១៨	៧	៧០
_ ម៉ូហ្សំប៊ិក	១៥.៣	៣៦.៣	២.៨	៤៥	១៨	៤៦
_ រវ៉ាន់ដា	៧.៨	២០.៦	៣.៤	៥២	១៨	៤៦
_ សូម៉ាលី	៩.៥	២៣.៤	៣.២	៥០	១៩	៤៧
_ យូហ្គាន់ដា	១៩.២	៤៥.៩	៣.០	៥១	២១	៤២
_ តង់ហ្សានី	២៨.៨	៧៤.២	៣.៤	៤៨	១៥	៥១
_ ហ្សំប៊ី	៨.៩	២១.០	២.៨	៤៦	១៨	៤៤
_ ហ្ស៊ីមបាវ៉េ	១០.៩	២២.៩	៣.០	៤១	១១	៥៦
b- អាហ្វ្រិកកណ្ដាល	៧៥.១	១៩០.០	៣.១	៤៦	១៥	៥១
_ អង់ហ្គោឡា	១០.៣	២៦.៦	៣.៧	៥១	១៩	៤៦
_ កាម៉េរ៉ូន	១២.៥	២៩.៣	២.៨	៤១	១២	៥៦
_ អាហ្វ្រិកកណ្ដាល	៣.៣	៧.០	២.៦	៤៤	១៨	៤៧
_ ឆាដ	៦.០	១២.៩	២.៧	៤៤	១៨	៤៨
_ កុងហ្គោ	២.៤	៥.៨	៣.០	៤៥	១៥	៥២
_ ហ្គាបុង	១.៣	២.៩	៣.៣	៤៣	១៦	៥៤
_ ហ្សាអៀរ	៤១.២	១០៤.៥	៣.២	៤៧	១៥	៥២
c- អាហ្វ្រិកខាងជើង	១៤៧.៧	២៨០.៤	២.៥	៣៤	៩	៦១
_ អាល់ហ្សេរី	២៧.១	៥១.៨	២.៧	៣៤	៧	៦៦
_ អេហ្ស៊ីប	៥៦.១	៩៣.៥	២.២	៣១	៩	៦២
_ លីប៊ីយ៉េន អារ៉ាប់	៥.៥	១២.៩	៣.៥	៤២	៨	៦៣
_ ម៉ារ៉ុក	២៧.០	៤៧.៥	២.៤	៣២	៨	៦៣
_ ស៊ូដង់	២៧.៤	៦០.៦	២.៨	៤២	១៤	៥២
_ ទុយណេស៊ី	៨.៦	១៣.៤	២.១	២៧	៦	៦៨
d- អាហ្វ្រិកខាងត្បូង	៤៥.៣	៨៥.៣	២.៤	៣២	៩	៦៣
_ បុតស្វាណា	១.៤	២.៩	២.៩	៣៨	៩	៦១
_ ឡេសូតូ	១.៩	៣.៨	២.៥	៣៤	១០	៦១
_ ណាមីប៊ី	១.៦	៣.៨	៣.២	៤៣	១១	៥៩

- អាហ្វ្រិកខាងត្បូង	៤០,៨	៧៣,២	២,៤	៣១	៩	៦៣
ខ- អាហ្វ្រិកខាងលិច	២០៦,២	៥១០,៨	៣,១	៤៦	១៥	៥១
- បេណាំង	៥,១	១២,៤	៣,១	៤៩	១៨	៤៦
- បៀគីណាហ្វាសូ	៩,៨	២២,៦	២,៨	៤៧	១៨	៤៨
- កូដ ឌីវ័រ	១៣,៤	៣៧,៩	៣,៧	៥០	១៥	៥២
- ហ្គាណា	១៦,៤	៣៨,០	៣,០	៤២	១២	៥៦
- ហ្គីណេ	៦,៣	១៥,១	៣,០	៥១	២០	៤៥
- ហ្គីណេ ប៊ីសូ	១,០	២,០	២,១	៤៣	២១	៤៤
- លីបេរី	២,៨	៧,២	៣,៣	៤៧	១៤	៥៥
- ម៉ាលី	១០,១	២៤,៦	៣,២	៥១	១៩	៤៦
- ម៉ូរីតានីញ៉ា	២,២	៥,០	២,៩	៤៦	១៨	៤៨
- នីហ្សេ	៨,៥	២១,៣	៣,៣	៥១	១៩	៤៧
- នីហ្សេរីយ៉ា	១១៩,៣	២៨៥,៨	៣,១	៤៥	១៤	៥៣
- សេណេហ្គាល់	៧,៩	១៧,១	២,៧	៤៣	១៦	៤៩
- សេរ៉ា ឡេអូន	៤,៥	៩,៨	២,៧	៤៨	២២	៤៣
- តូហ្គោ	៣,៩	៩,៤	៣,២	៤៥	១៣	៥៥

(នៅមានត)

ស្រាវជ្រាវដោយ សេខ សុផាលីន

ទំព័រកំណាព្យ ៖

អនិច្ចាជីវិតជនពិការ

១_ អស់ ឱកុលបុត្រខ្មែរទាំងអស់ គួរគិតឱ្យស្មោះអស់ពីចិត្ត
ជនខ្មែរពិការគួរអាណិត មិនអាចភ្លេចពិតណាថ្លើមថ្លៃ ។
២_ មួយជាតិក្លាយជាជនពិការ សែនអនិច្ចាជីវិតក្រៃ
ស៊ូទ្រាំត្រាំទ្រូងរាល់យប់ថ្ងៃ សោកសៅអាល័យក្រៃអាណិត ។
៣_ សែនអនិច្ចាជនពិការ ចុកចាប់ឱរ៉ាចារជាប់ចិត្ត
ឈាមខ្មែរជោរជាំត្រាំជីវិត យុគខ្មៅងងឹតឥតមេត្តា ។
៤_ រស់នៅសព្វថ្ងៃសែនខ្វល់ខ្វាយ បាត់បង់រាងកាយស្ពាយវាសនា
មិនគួរណាខ្លួនធ្លាក់ពិការ តឹងទ្រូងខ្លោចផ្សារសីរងរៃ ។
៥_ អ្នកខ្លះកំព្រាព្រាត់ម៉ែឪ ក្រៀមក្រោះអាស្រូវឥតប្រណី
ស្ពុះស្ពាប់អាប់អោនគ្មានទីទៃ គោលដៅឥតន័យរស់ខ្សត់ក្រៃ ។
៦_ អង្គកាយអាចរស់ព្រោះនឹងទាន កាត់កេរ្តិ៍ខ្មាស់អៀនកណ្ដាលថ្ងៃ
អួសត្អូញរំកិលផ្សាស្ទើរក្ស័យ ចិត្តខំសំចៃយ៉ាងឃ្លាតខ្មី ។
៧_ អនិច្ចាពិការគ្រប់កន្លែង កណ្ដោចកណ្ដែងទាំងប្រុសស្រី
ត្រដាបត្រដួសគ្មានសេរី វឹកវរភិតភ័យសែនខ្លោចផ្សា
៨_ ជើងដៃខ្ទេចខ្ទាំទាំងក្មេងចាស់ វេទនាខ្លាំងណាស់ខ្ទាក់នេត្រា
ខំដើរស្ទាបស្ទង់ក្នុងទីផ្សារ ជ្រៀតជ្រែកដួលផ្ងារក្រាបលើដី ។
៩_ ហាលភ្លៀងភក់ជ្រាំទ្រាំរងា គ្រប់កាលវេលាមិនហ៊ានស្ដី
ឱ្យតែបានរស់អរពេកក្រៃ ធ្វើម្ដេចសព្វថ្ងៃខ្លួនពិការ ។
១០_ សែនអនិច្ចារាប់រយដង ទុក្ខទោសកន្លងក្នុងលោកា
ដាច់ដោចជើងដៃក្ស័យស្នេហា ឱជនពិការសែនអភ័ព្វ ។
១១_ ជីវិតកូនខ្មែរពុំដែលលោះ ជួបតែរងគ្រោះដោយសារគ្រាប់
បំផ្លិចបំផ្លាញកិតគៀកជាប់ សង្គ្រាមច្បាមចាប់ជាតិខេមរា ។
១២_ ភ្លើងភ្នំសង្គ្រាមឈាមឆ្អិនឆ្អៅ ដក់ជាប់ចារដៅក្នុងសាវតារ
ធ្វើឱ្យកូនខ្មែរខូចវាសនា ក្លាយជាពិការមួយជីវិត ៕

ដោយ ហែម សាទិន
និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ ឆ្នាំទី ២

ទំព័រកំសាន្តចិត្ត :

ខ្ញុំធ្លាប់ប៉ះគាត់ញយ

បវេសនកាលបានចូលមកដល់ ។ ដោយសារភាពធុញទ្រាន់ ឬក៏ដោយសារភាពសាំ ក្នុងការរៀនជាមួយគ្រូដដែលៗ កូនសិស្សក៏នាំគ្នាចង់ប្តូរថ្នាក់ និងគ្រូបង្រៀន ។

_ សុខ : សៅឯងដឹងទេថា តើគ្រូណាមួយដែលស្រួលជាងគេ ? _

_ សៅ : អូ ! គ្នានឹកឃើញហើយសុខ គឺអ្នកគ្រូក្រមុំម្នាក់ដែលគ្នាធ្លាប់និយាយប្រាប់ឯងនោះណា

_ សុខ : សៅ ធ្វើយ៉ាងម៉េចបានជាឯងដឹងថា អ្នកគ្រូក្រមុំម្នាក់នោះស្លូតបូរាស ?

_ សៅ : រឿងអីគ្នាមិនដឹង បើកាលពីរៀនឆ្នាំទៅ គ្នាធ្លាប់ប៉ះគាត់ញយដងណាស់ គាត់មិនដែលហ៊ានមាត់ម៉ាអឹះឱ្យគ្នាទេ ដល់អីចឹងទៅគ្នាចូលចិត្តប៉ះគាត់ណាស់ ។

និយាយដល់ត្រឹមនេះស្រាប់តែអ្នកគ្រូក្រមុំនោះក៏មកដល់ ហើយក៏ស្តីបន្ទោសឱ្យសៅម៉ារយៗតែម្តង---

_ អ្នកគ្រូ : ឯងថាម៉េចសៅ ? តើឯងដែលធ្លាប់ប៉ះខ្ញុំពីកាលណា ឯងចង់ដើរសំអុយឈ្មោះខ្ញុំឬ ?

_ សៅ : ហេតុម៉េច បានជាអ្នកគ្រូមកចោទប្រកាន់ខ្ញុំទាំងទទឹងទិសដូចនេះ អ្នកគ្រូមានរឿងអីឬ ?

_ អ្នកគ្រូ : ខ្ញុំមិនចោទប្រកាន់ឯងទេ ខ្ញុំស្តាប់លឺឯងនិយាយគ្នាអស់ហើយ គឺឯងចង់មើលងាយខ្ញុំ ។ ខ្ញុំសូមប្រាប់ឯងថា ខ្ញុំមិនមែនក្រមុំចេះតែដើរឱ្យគេឯងប៉ះងាយៗដោយមិនមាត់ម៉ាអឹះនោះទេ ដូចឯងថានោះទេ ។

_ សុខ និងសៅ : អ្នកគ្រូ មិនមែនខ្ញុំច្រលំទេ គឺអ្នកគ្រូទេតើដែលច្រលំ តាមពិតខ្ញុំចង់និយាយថាកាលពីឆ្នាំទៅ ខ្ញុំធ្លាប់រៀនប៉ះចំម៉ោងអ្នកគ្រូបង្រៀនទេតើ ---

_ អ្នកគ្រូ : អូ ឥញ្ចឹងទេ ? ខ្ញុំស្មានតែឯងចង់ថាខ្ញុំ---

ដោយអ_ប_រ